


# សិទ្ធិមនុស្សនៅកម្ពុជា៖
# យុត្តិធម៌គ្មានភាពប្រាកដនិយម

របាយការណ៍ លីកាដូ
ខែធ្នូ ឆ្នាំ២០០៧

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

Cambodian League for the
Promotion and Defense of Human Rights

# សិទ្ធិមនុស្សនៅកម្ពុជា:

# យុត្តិធម៌គ្មានភាពប្រាកដនិយម

---

## របាយការណ៍លីកាដូ

## ខែធ្នូ ឆ្នាំ២០០៧

សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា នឹងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ នឹងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**លីកាដូ កំពុងបន្តសកម្មភាពរបស់ខ្លួនតាមរយៈការិយាល័យកម្មវិធីទាំង៦ របស់ខ្លួន ដូចខាងក្រោមៈ**

- **ការិយាល័យឯកសារ និងធនធានព័ត៌មាន** គឺជាការិយាល័យដែលរក្សាចងក្រងសំណុំរឿងទៅក្នុងទិន្នន័យដើម្បីងាយស្រួលក្នុងការរកឯកសារនឹងវិភាគឱ្យបានឆាប់រហ័ស។
- **ការិយាល័យស៊ើបអង្កេត** គឺជាការិយាល័យដែលមានតួនាទីជាអ្នកស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស នឹងជួយជនរងគ្រោះនានាក្នុងដំណើរការបណ្តឹងដែលពាក់ព័ន្ធខាងផ្នែកច្បាប់។ បុគ្គលិក ដែលមានការហ្វឹកហ្វឺនជំនាញត្រឹមត្រូវក៏បានឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីវាយតម្លៃស្ថានភាពពន្ធនាគារ ព្រមទាំងជួយឱ្យពិរុទ្ធជនទាំងឡាយទទួលបាននូវតំណាងផ្នែកច្បាប់ទៀតផង។
- **ការិយាល័យពេទ្យ** គឺជាការិយាល័យដែលផ្តល់សេវាវេជ្ជសាស្ត្រដល់ពិរុទ្ធជន ទណ្ឌិត និងមន្ត្រីពន្ធនាគារនៅតាមពន្ធនាគារចំនួន ១៨ កន្លែង។ ក្រៅពីនេះ ក៏បានផ្តល់សេវាវេជ្ជសាស្ត្រនឹងជួយបញ្ជូនជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សទៅមន្ទីរពេទ្យផងដែរ។
- **កម្មវិធីប្រឆាំងនឹងទារុណកម្ម** ជាការិយាល័យផ្តល់សេវាកម្មស្តារលទ្ធភាពទូទៅដល់ជនរងគ្រោះដោយអំពើទារុណកម្ម នឹងធ្វើការតស៊ូមតិប្រឆាំងនឹងអំពើទារុណកម្ម។
- **ការិយាល័យសិទ្ធិកុមារ** ជាការិយាល័យដែលផ្តល់ការអប់រំសិទ្ធិកុមារដល់សាធារណៈជនទូទៅ ស្ថាបនាបណ្តាញការពារកុមារនៅតាមមូលដ្ឋាននានា នឹងស៊ើបអង្កេតការរំលោភសិទ្ធិកុមារ ។
- **ការិយាល័យសិទ្ធិស្ត្រី** ជាការិយាល័យអប់រំសិទ្ធិស្ត្រីដល់សាធារណៈជនទូទៅ ស៊ើបអង្កេតការរំលោភសិទ្ធិស្ត្រី នឹងធ្វើការតស៊ូមតិ ដើម្បីឱ្យមានការផ្លាស់ប្តូរផ្នែកច្បាប់ និងសង្គម។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:**

លោកស្រី វេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦, ផ្លូវលេខ ៩៩, រាជធានីភ្នំពេញ, កម្ពុជា

ទូរស័ព្ទ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ៣៦៤៩០១

ទូរសារ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១៧ ៦២៦

អ៊ីម៉ែល: contact@licadho.org

គេហទំព័រ: http://www.licadho.org/

# មាតិកា


**១.** **បុព្វកថា** ~~~~~~~~~~~~~~~~~~~~ ១

**២.** **តុលាការ និងនយោបាយ** ~~~~~~~~~~~~~~~~~~~~ ៣

ព្រឹត្តិការណ៍: នយោបាយ និងការផ្តន្ទាទោស -------------------- ៧

ការសុំអភ័យទោស: អ្នកនយោបាយនៅមុខតុលាការ -------------------- ៨

**៣.** **តុលាការ និងសេរីភាពក្នុងការបញ្ចេញមតិ** ~~~~~~~~~~~~~~~~~~~~ ១១

**៤.** **តុលាការ និងនិទ្ទណ្ឌភាព** ~~~~~~~~~~~~~~~~~~~~ ១៤

និទ្ទណ្ឌភាព : ឧទាហរណ៍ករណីនានាចាប់តាំងពីឆ្នាំ២០០៦ -------------------- ១៧

សវនាការសាលាឧទ្ធរណ៍ ករណី ប៊ិន សំណាង និងសុខ សំអឿន -------------------- ២៥

**៥.** **តុលាការ និងផលប្រយោជន៍សេដ្ឋកិច្ច** ~~~~~~~~~~~~~~~~~~~~ ២៩

ជម្លោះដីធ្លីនៅតំបន់បឹងប្រាំ -------------------- ៣៣

**៦.** **តុលាការ និងអំពើពុករលួយ** -------------------- ៣៦

**៧.** **តុលាការ និងការឃុំឃាំង** ~~~~~~~~~~~~~~~~~~~~ ៣៨

**៨.** **សាលាក្តីខ្មែរក្រហម: តុលាការគំរូ?** ~~~~~~~~~~~~~~~~~~~~ ៤០

**៩.** **តុលាការ និងកំណែទម្រង់** ~~~~~~~~~~~~~~~~~~~~ ៤៤

**១០.** **អនុសាសន៍** ~~~~~~~~~~~~~~~~~~~~ ៤៧

# ១. បុព្វកថា

ប្រព័ន្ធយុត្តិធម៌កម្ពុជាបានបរាជ័យ។ ទោះបីអ៊ុនតាក់បានជួយអន្តរាគមន៍ ហើយមានជំនួយដើម្បីកែទម្រង់អស់រយៈពេល ១៥ ឆ្នាំកន្លងមកក្តី ក៏មកដល់ឆ្នាំ ២០០៧ នេះ តុលាការនៅតែមានតួនាទីត្រឹមជាអ្នក៖

- ផ្តន្ទាទោសអ្នកនយោបាយ និងអ្នករិះគន់រដ្ឋាភិបាលសំខាន់ៗ
- ពាក់ព័ន្ធជាមួយអំពើនិទ្ទណ្ឌភាពសម្រាប់ភ្នាក់ងាររដ្ឋសំខាន់ៗ និងបក្សពួករបស់គេ
- ការពារផលប្រយោជន៍សេដ្ឋកិច្ចឱ្យពួកអ្នកមាន និងអ្នកមានអំណាច

អំឡុងពេលទស្សនៈកិច្ចនៅកម្ពុជាឆ្នាំមុន លោកស្រីឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស លូី អាប័រ បានពិពណ៌អំពីការកែទម្រង់តុលាការកម្ពុជាថាជា "វិស័យសំខាន់បំផុតតែមួយគត់" ដែលប្រទេសនេះត្រូវធ្វើឱ្យមានការរីកចំរើនទៅមុខ។ ប៉ុន្តែ ទោះបីជាមានការសន្យាជាសាធារណៈម្តងហើយម្តងទៀត អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែទម្រង់ច្បាប់ និងតុលាការ នឹងដោយការវិនិយោគច្រើនលានដុល្លារពីម្ចាស់អ្នកផ្តល់ជំនួយបរទេសនៅក្នុងកម្មវិធីកែទម្រង់ចាប់តាំងពីឆ្នាំ១៩៩២ក៏ដោយ នៅតែពុំមានការរីកចំរើននៅឡើយនៅក្នុងការកែទម្រង់ជាវិស័យដ៏សំខាន់បំផុត ដែលមានឥទ្ធិពលលើតុលាការ- កង្វះឯករាជ្យភាពដោយសារឥទ្ធិពលនយោបាយ និងហិរញ្ញវត្ថុ ។

ពុំមានហេតុផលណាដែលអាចជឿថា រដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ក្នុងការកែលំអតុលាការឡើយ ប្រសិនបើក្រឡេកមើលការកែលំអដ៏យឺតយ៉ាវបំផុតនៅក្នុងរយៈពេល ១៥ឆ្នាំ កន្លងមក។ មើលទៅទំនងជាគ្មានការកែទម្រង់ប្រកបដោយអត្ថន័យនឹងកើតឡើងដោយគ្មានការខិតខំប្រឹងប្រែងរបស់អ្នកផ្តល់ជំនួយនៅកម្ពុជា ដើម្បីធ្វើឱ្យរដ្ឋាភិបាលគោរពការសន្យារបស់ខ្លួនទេ ។

នៅពេលដែលការកែទម្រង់តុលាការ និងច្បាប់ ដែលជាផ្នែកមួយដ៏សំខាន់របស់អ្នកផ្តល់ជំនួយជួយគាំទ្រដល់កម្ពុជាមិនត្រូវបានផ្លាស់ប្តូរ សហគមន៍អ្នកផ្តល់ជំនួយនៅតែផ្តោតការយកចិត្តទុកដាក់ទៅលើសុច្ចនករីកចំរើនរយៈពេលខ្លីដដែល។ សហគមន៍អ្នកផ្តល់ជំនួយទាំងនោះ តែងតែមើលរំលងនូវអ្វីដែលកំពុងតែកើតឡើងពិតប្រាកដនៅក្នុងតុលាការកម្ពុជា ដែលគេតែងតែបំភ្លេចចោលនូវច្បាប់ដែលមានស្រាប់ ហើយតែងតែបំភ្លេចចោលនូវវគ្គហ្វឹកហ្វឺននានានៅពេលដែលមានឥទ្ធិពលនយោបាយ ឬហិរញ្ញវត្ថុចូលមកជ្រៀតជ្រែក។

សហគមន៍អ្នកផ្តល់ជំនួយត្រូវភ្ញាក់រឭកឡើង។ គេត្រូវតែទទួលស្គាល់ថាការកែទម្រង់តុលាការ គឺជាឧត្តមប្រយោជន៍របស់ប្រជាពលរដ្ឋកម្ពុជា មិនត្រូវឱ្យរដ្ឋាភិបាលគិតតែអំពីឧត្តមប្រយោជន៍របស់ខ្លួនឡើយ។ សហគមន៍

(២) របាយការណ៍ លីកាដូ


តុលាការខេត្តកំពង់ឆ្នាំង

អ្នកផ្តល់ជំនួយ ត្រូវឈប់វាស់វែងភាពជោគជ័យតាមរយៈការអនុម័តច្បាប់ ការបើកវគ្គហ្វឹកហ្វឺន និងការជួសជុលកែលំអអគារតុលាការតទៅទៀត ហើយត្រូវចាប់ផ្តើមវាស់វែងពីភាពជោគជ័យតាមរយៈសកម្មភាពរបស់តុលាការ ក្នុងការអនុវត្តន៍នីតិរដ្ឋប្រចាំថ្ងៃវិញ។

ការពង្រឹងនីតិរដ្ឋ គឺជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងលទ្ធិប្រជាធិបតេយ្យ ហើយគួរតែត្រូវឃើញផ្ទាល់ដោយសហគមន៍អ្នកផ្តល់ជំនួយ។ ការពុំបានធ្វើឱ្យមានការរីកចំរើននៅក្នុងការកែទម្រង់នេះ គឺជាការផ្ទុយនឹងប្រសិទ្ធិភាពរបស់កម្មវិធីផ្តល់ជំនួយទាំងមូល និងស្របលើគោលបំណងរបស់ពួកគេក្នុងវិស័យ សុខភាព អប់រំ ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍសេដ្ឋកិច្ច និងស្ថេរភាពនយោបាយថែមទៀត។

របាយការណ៍នេះ គឺជារបាយការណ៍មួយ ដែលពិនិត្យមើលនូវការអនុវត្តន៍របស់តុលាការកម្ពុជាចាប់តាំងពីកិច្ចប្រជុំពិគ្រោះយោបល់របស់សហគមន៍អ្នកផ្តល់ជំនួយកាលពីថ្ងៃទី២-៣ ខែមិនា ឆ្នាំ២០០៦ កន្លងទៅ។ របាយការណ៍នេះ មានគោលបំណងចង្អុលបង្ហាញនូវទិដ្ឋភាពនៃភាពអយុត្តិធម៌ និងនិទ្ទណ្ឌភាព ព្រមទាំងបង្ហាញនូវភាពខ្វះខាតក្នុងការអនុវត្តន៍សកម្មភាពជាក់ស្តែងរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់នីតិរដ្ឋ ហើយជំរុញឱ្យសហគមន៍អន្តរជាតិរៀបចំយុទ្ធសាស្ត្ររបស់ខ្លួនសារឡើងវិញក្នុងការជួយកែទម្រង់ច្បាប់ និងតុលាការ។

□□□

# ២. តុលាការ និងនយោបាយ

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៦ ប្រធានគណបក្សប្រឆាំង លោក សម រង្ស៊ី បានត្រឡប់មកដល់ កម្ពុជាវិញ បន្ទាប់ពីនិរទេសខ្លួនអស់រយៈពេលមួយឆ្នាំ ។ ប្រាំថ្ងៃមុនពេលមកដល់ គាត់ត្រូវបានលើកលែងពីការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១៨ខែ ដោយតុលាការក្រុងភ្នំពេញក្រោមបទចោទប្រកាន់ថា បានបរិហារកេរ្តិ៍លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានគណៈបក្សហ៊្វុនស៊ីនប៉ិច ។ អនុប្រធានរបស់គាត់ លោក ជាម ចន្នី ក៏ត្រូវបានលើកលែងទោសផងដែរ បន្ទាប់ពីត្រូវបានតុលាការយោធាឃុំខ្លួនក្នុងពន្ធនាគារដោយខុសច្បាប់អស់រយៈពេលមួយឆ្នាំ[១] ហើយបន្ទាប់មកសកម្មជនសិទ្ធិមនុស្សប្រាំនាក់ទៀត ក៏ត្រូវបានដោះលែងនៅក្រៅឃុំពីរបីសប្តាហ៍មុនកាលកំណត់ផងដែរ។ លោក សម រង្ស៊ី បានអបអរសាទរការដោះលែងនេះថាជា *"សករាជថ្មីនៃប្រវត្តិសាស្ត្រកម្ពុជា"* ហើយពេលនោះសហគមន៍អន្តរជាតិបានពោលសរសើរដល់ចំណាត់ការរបស់លោកនាយករដ្ឋមន្ត្រីព្រមៗគ្នា ហើយបានបដិសេធថាការដោះលែងនេះ ពុំមែនជាប់ទាក់ទងជាមួយនិងកិច្ចប្រជុំពិគ្រោះយោបល់នៃក្រុមប្រទេសអ្នកផ្តល់ជំនួយ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២-៣ ខែមិនា ឆ្នាំ២០០៦ ទេ។ ដូចឯកអគ្គរដ្ឋទូតអាមេរិក ចូសែហ្វ មូសសូមេលី បានលើកឡើងថា"ហ៊ុន សែន ពុំអាចធ្វើល្អ នឹងបង្ហាញនូវប្រជាធិបតេយ្យតែចំពោះមុខក្រុមពិភាក្សាពិគ្រោះផ្តល់ជំនួយទេ តែពីរបីខែក្រោយមក គាត់វិលត្រឡប់ទៅរកភាពដើមវិញជាដដែល។[២]

ការពិតមានត្រឹមតែពីរបីសប្តាហ៍តែប៉ុណ្ណោះ ។

ការទំនាក់ទំនងរវាងលោកនាយករដ្ឋមន្ត្រី មកលើគណបក្សប្រជាជនកម្ពុជា និងប្រធានគណបក្សហ៊្វុនស៊ីនប៉ិចត្រូវបានប្រេះស្រាំភ្លាមៗ ក្រោយពីលោក សម រង្ស៊ី បានវិលត្រឡប់មកដល់កម្ពុជាវិញ។ ការអំពាវនាវរួមដោយគណបក្សប្រជាជនកម្ពុជា និងគណបក្ស សម រង្ស៊ី ដើម្បីបន្ថយតម្រូវការសម្លេងពីរភាគបី ដើម្បីបង្កើតរដ្ឋាភិបាលត្រូវបានអបអរសាទរតិចតួចបំផុតពីសំណាក់ហ៊្វុនស៊ីនប៉ិច ដែលជាដៃគូភាគតិចនៅក្នុងរដ្ឋាភិបាលចម្រុះ ដែលត្រូវបាត់បង់អំណាចស្ទើរតែទាំងស្រុង។ នៅក្នុងសន្ទរកថាមួយថ្លែងកាលពីថ្ងៃទី២៦ ខែកុម្ភៈ សម្តេច ហ៊ុន សែន បានបើកការវាយប្រហារយ៉ាងធ្ងន់ៗលើគណបក្សហ៊្វុនស៊ីនប៉ិច មុននឹងចាប់ផ្តើមគំរាមបោសសំអាតមន្ត្រីធំៗមួយចំនួន

---

[១] ក្រុមការងាររបស់អង្គការសហប្រជាជាតិ ស្តីពីការឃុំខ្លួនតាមអំពើចិត្តបានរកឃើញថាតាមច្បាប់ជាតិ និងអន្តរជាតិ តុលាការយោធាពុំមានយុត្តាធិការវិនិច្ឆ័យលោក ជាម ចន្នី ដែលជាជនស៊ីវិលទេ ។ សូមអានបទប្បញ្ញត្តិរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការឃុំឃាំងលោក ជាម ចន្នី- ដោយ FIDH ថ្ងៃទី១២ ខែមករា ឆ្នាំ២០០៦ ។

[២] ឆាល ម៉ាក់ឌឺមីត ក្លាហានក្នុងការលាតត្រដាងនយោបាយពិភពលោកថ្មី - ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៤ ខែកុម្ភៈ ដល់ ថ្ងៃទី៩ ខែមិនា ឆ្នាំ២០០៦។

ដោយមិនបានបញ្ចេញឈ្មោះ ដែលបានចំណាយថវិការខ្ជះខ្ជាយជាមួយស្រីកំណាន់ ។ គាត់បាននិយាយថា គណបក្សប្រជាជនកម្ពុជាកំពុងតែធ្វើសេចក្តីព្រាងច្បាប់ ដើម្បីផ្តន្ទាទោសមន្ត្រីបែបនេះ ហើយបានបន្ថែមថា រដ្ឋមន្ត្រីក្រសួងកិច្ចការនារីរបស់គណបក្សហ៊្វុនស៊ិនប៉ិច មិនហ៊ានធ្វើសេចក្តីព្រាងច្បាប់នេះទេ ដោយខ្លាចមន្ត្រីមួយចំនួននៅក្នុងគណបក្សរបស់ខ្លួនខឹង។ ចេតនាលោកនាយករដ្ឋមន្ត្រីដែលបានលើកឡើង គឺដើម្បី "លុបបំបាត់" ស្រីកំណាន់"ដូចជាការទះកំភ្លៀង"[៣]។ ក្រោយមក លោកនាយករដ្ឋមន្ត្រី បានបដិសេធចំពោះទ្រង់នរោត្តមរណឫទ្ធិថា ការលើកឡើងនោះគឺជាការលើកឡើងផ្ទាល់ខ្លួនតែប៉ុណ្ណោះ[៤] ប៉ុន្តែបញ្ហានេះ ជាសញ្ញាបង្ហាញឱ្យឃើញនូវការចាប់ផ្តើមការផ្តន្ទាទោសដោយហេតុផលនយោបាយមួយបែបថ្មីទៀត។

ខណៈដែលកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការផ្តល់ជំនួយឆ្នាំ២០០៦ បានចាប់ផ្តើមនៅថ្ងៃទី២ ខែមិនា រដ្ឋសភាជាតិបានអនុម័តវិសោធនកម្មរដ្ឋធម្មនុញ្ញដើម្បីបង្កើតរូបមន្ត ៥០ បូក ១ សម្រាប់បង្កើតរដ្ឋាភិបាល ហើយលោក ហ៊ុន សែន បានដកតំណែងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ដែលជាមន្ត្រីកូតារបស់ហ៊្វុនស៊ិនប៉ិច។ មួយរយៈខ្លីក្រោយមក សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ បានលាលែងពីតំណែងប្រធានរដ្ឋសភាជាតិ ហើយខែក្រោយៗមកទៀត មន្ត្រីហ៊្វុនស៊ិនប៉ិចជាច្រើន ត្រូវបានដកហូតតចេញពីណែង ខណៈនោះលោកនាយរដ្ឋមន្ត្រីនៅតែបន្តវាយប្រហារ ចំពោះការរិះគន់ជាសាធារណៈមកលើគណបក្ស និងអ្នកដឹកនាំរបស់ខ្លួន។

នៅថ្ងៃទី១ ខែកញ្ញា រដ្ឋសភាជាតិបានអនុម័តច្បាប់ ដោយដាក់អំពើសាហាយស្មន់ជាអំពើខុសច្បាប់ ដែលបានកំណត់ផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១ឆ្នាំ ចំពោះពលរដ្ឋកម្ពុជាណាដែលលបលួចមានសាហាយស្មន់។ ប្រធានរដ្ឋសភានៃគណបក្សប្រជាជនកម្ពុជា សម្តេច ហេង សំរិន បានការពារច្បាប់នោះថា ជាច្បាប់ដែលមានគោលបំណង ដើម្បី " ការពារ រួបរួម ពង្រឹងសុភមង្គល និងការគោរពគ្នាទៅវិញទៅមករវាងគូរស្វាមីភរិយា"[៥]។ ការអនុម័តនេះគឺផ្ទុយទៅនិងអ្វីដែលនាយករដ្ឋមន្ត្រីបានលើកឡើងថា ការប្រកាសនេះ គឺសំដៅលើមន្ត្រីសាធារណៈតែប៉ុណ្ណោះ។

ជាមួយនឹងភស្តុតាងបំបែកហ៊្វុនស៊ិនប៉ិចយ៉ាងលឿន សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ត្រូវបានទម្លាក់ពីតំណែងជាប្រធានគណបក្សកាលពីថ្ងៃទី១៨ ខែតុលា ។ មួយខែក្រោយមក ទ្រង់បានប្រកាសបើកគណបក្សថ្មី គឺគណបក្សនរោត្តមរណឫទ្ធិ ។ មួយខែក្រោយមក ទ្រង់នៅតែត្រូវបានជាប់ចោទពីបទរំលោភលើសេចក្តីទុកចិត្ត ដោយតុលាការក្រុងភ្នំពេញដែលទាក់ទងទៅនិងការលក់អតីតស្នាក់ការគណបក្សហ៊្វុនស៊ិនប៉ិចខុសច្បាប់។ ស្នាក់ការ

---

[៣] យុន សាមាន និងសាមាន់ថា មេឡាមេដ - នាយករដ្ឋមន្ត្រីបានគំរាមលុបបំបាត់ចោលស្រីកំណាន់ -កាសែតឌឹខេមបូឌាដេលី ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៦។

[៤] យុន សាមាន - នាយករដ្ឋមន្ត្រីបានទូរស័ព្ទទៅព្រះអង្គម្ចាស់ ដោយមានប្រសាសន៍ថា ការវាយប្រហារពុំមែនផ្ទាល់ខ្លួនទេ - កាសែតរស្មីកម្ពុជា ថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០៦។

[៥] យុន សាមាន — រដ្ឋសភាអាចធ្វើឱ្យអំពើសាយស្មន់ជាអំពើខុសច្បាប់នៅថ្ងៃនេះ - កាសែតឌឹខេមបូឌាដេលី ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦។

នោះ ត្រូវបានលក់កាលពីឆ្នាំ២០០៥ ទៅឱ្យកូនប្រសាររបស់មន្ត្រីអ្នកនាំពាក្យគណបក្សប្រជាជន និងសមាជិកការិយាល័យនយោបាយ ជាម យៀប ។[៦]

នៅថ្ងៃទី១៣ ខែមិនា ឆ្នាំ២០០៧ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ត្រូវបានកាត់ទោសកំបាំងមុខ ដោយតុលាការក្រុងភ្នំពេញ ដោយកំណត់ទោសដាក់ពន្ធនាគារ ១៨ខែ ដែលជាការកំណត់ទោសស្មើនឹងឯកឧត្តម សម រង្ស៊ី កាលពីរយៈពេល ១៥ ខែកន្លងទៅដែរ (ប៉ុន្តែ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ត្រូវបានផាកពិន័យជាប្រាក់ចំនួន ១៥០.០០០ ដុល្លារ ដែលលោក សម រង្ស៊ី ត្រឹមតែ ១៤០.០០០ ដុល្លារតែប៉ុណ្ណោះ)។ នៅក្នុងការកាត់ក្តីនេះ ចៅក្រម សៅ មៀច ត្រូវទទួលរងការរិះគន់យ៉ាងច្រើន ចំពោះការមិនបានអនុញ្ញាតឱ្យភាគីចុងចោទផ្តល់ភស្តុតាង នឹងសួរដេញដោលសាក្សីដោះបន្ទុក ព្រមទាំងការចេញសាលក្រមក្នុងកំឡុង ១០នាទីប៉ុណ្ណោះ ក្រោយពីការសម្រាកពិចារណាដើម្បីកំណត់ទោស។ នៅក្នុងសវនាការនោះ គេបានឃើញមានអ្នកសង្កេតការណ៍យ៉ាងច្រើនកុះកររួមទាំងឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ដែលបានសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងអំពីយុត្តិធម៌នៃសវនាការនោះ។[៧]

ការកាត់ទោសសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ត្រូវបានធ្វើឡើង ៣ ថ្ងៃ មុនចាប់ផ្តើមយុទ្ធនាការឃោសនារកសម្លេងឆ្នោត នៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់តែប៉ុណ្ណោះ ដែលនាំឱ្យគណបក្សនរោត្តមរណឫទ្ធិ មានការខកចិត្តយ៉ាងខ្លាំងដោយសារការអវត្តមានរបស់ប្រធានគណបក្សរបស់ខ្លួន ក៏ដូចជាការវាយប្រហារដោយច្បាប់ថែមទៀត។ នៅថ្ងៃចុងក្រោយនៃយុទ្ធនាការ ប្រធានស្តីទីនៃគណបក្សនរោត្តមរណឫទ្ធិ គឺព្រះអង្គម្ចាស់ នរោត្តម ចក្រពង្ស ត្រូវបានតុលាការក្រុងភ្នំពេញកោះហៅ ដើម្បីសាកសួរអំពីបញ្ហាបំណុលដែលទ្រង់បានជំពាក់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ បីថ្ងៃក្រោយមក តុលាការក៏បានប្រកាសថា ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ត្រូវបានចោទប្រកាន់ពីបទសាហាយស្មន់ថែមទៀត។[៨] ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ គឺជាមនុស្សដំបូងគេបង្អស់ ដែលត្រូវបានចោទប្រកាន់ក្រោមច្បាប់ឯកព័ន្ធភាព ហើយវាជាការលំបាកក្នុងការគេចឱ្យផុតពីការផ្តន្ទាទោសណាស់ ដោយសារតែគោលបំណងសំខាន់ក្នុងការអនុម័តច្បាប់នេះ គឺដើម្បីផ្តន្ទាទោសទ្រង់តែប៉ុណ្ណោះ។[៩] ក្នុងពេលជាមួយគ្នានេះដែរ ច្បាប់នេះក៏នឹងត្រូវប្រើប្រាស់ភ្លាមៗ ដើម្បីផ្តន្ទាទោសអ្នកនយោបាយណាដែលប្រឆាំងនឹងគណបក្សប្រជាជនកម្ពុជាពេលអនាគត។

---

[៦] យន់ សាមាន - ហ៊ុនស៊ីនប៊ិចបដិសេធមិនព្រមប្រគល់ស្នាក់ការ - កាសែតឌឹឃែមបូឌាដេលី-ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧។

[៧] យន់ សាមាន និង អេលីសាបេត តូមី -តុលាការបានកាត់ទោសទ្រង់ នរោត្តម រណឫទ្ធិ ឱ្យជាប់ពន្ធនាគារ ១៨ ខែ។ កាសែត ឌឹឃែមបូឌាដេលី ថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៧។

[៨] យន់ សាមាន -តុលាការបានចោទព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ពីបទសាហាយស្មន់។ កាសែត ឌឹឃែមបូឌាដេលី ថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៧។

[៩] នៅពេលកំពុងសរសេររបាយការណ៍នេះ ករណីសាហាយស្មន់របស់ទ្រង់ នរោត្តម រណឫទ្ធិពុំទាន់ត្រូវបានតុលាការកាត់ក្តីនៅឡើយទេ -កំពុងស្ថិតនៅក្នុងដំណើរការរបស់តុលាការនៅឡើយ ប៉ុន្តែអាចត្រូវគេបើកសវនាការជំនុំជម្រះថ្ងៃណាមួយក៏បាន។ បច្ចុប្បន្ននេះ អតីតលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិចលោក ខែក វ៉ាវី ជាព្រះញាតិនៃទ្រង់ នរោត្តម រណឫទ្ធិ បានក្លាយជាមនុស្សដំបូងគេបង្អស់ដែលត្រូវបានផ្តន្ទាទោស ក្រោមច្បាប់ឯកព័ន្ធភាពនេះ ។ សូមអានហ្វេកាល់ គីន និងឡាំបុប្ផ - ច្បាប់ឯកព័ន្ធភាពផ្តន្ទាទោសជាលើកដំបូង។ កាសែត ឌឹឃែមបូឌាដេលី ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ។

(៦) របាយការណ៍លីកាដូ

នៅពេលដែលគណបក្សទាំងពីរ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សនរោត្តម រណឫទ្ធិ ទទួលបានសម្លេងគាំទ្រតិចតួចជាទីបំផុត នៅក្នុងការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយគណបក្សនរោត្តម រណឫទ្ធិទទួលបានអាសនៈ ៤២៥ បើប្រៀបធៀបជាមួយហ៊្វុនស៊ិនប៉ិចទទួលបានត្រឹមតែ ២៧៤ អាសនៈតែប៉ុណ្ណោះ ដោយសារតែអវត្តមានសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ។ ក្រោយមក មានការភ្ញាក់ផ្អើលតិចតួចតែប៉ុណ្ណោះ ខណៈដែលគណបក្សហ៊្វុនស៊ិនប៉ិចបង្ហាញចេតនាចង់សុំព្រះរាជទានទោសថ្វាយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ប្រសិនបើទ្រង់យល់ព្រមរំលាយគណបក្សថ្មីចោល ហើយយាងមកចូលរួមដឹកនាំគណបក្សហ៊្វុនស៊ិនប៉ិចវិញ។ បញ្ហានេះត្រូវបានព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ បដិសេធ។[10] កាលពីខែតុលាកន្លងទៅ សាលាឧទ្ធរណ៍បានបដិសេធបណ្តឹងឧទ្ធរណ៍របស់ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលប្តឹងជំទាស់សាលក្រមរំលោភសេចក្តីទុកចិត្ត។ នៅក្នុងសវនាការព្រះរាជអាជ្ញា ង៉ែត សារ៉ាត បានបំភ្លេចចោលនូវមូលហេតុនយោបាយ ដែលស្ថិតនៅពីក្រោយករណីនេះ ដោយធ្វើការកត់សំគាល់ថា ប្រសិនបើគ្មានការបំបែកគណបក្សហ៊្វុនស៊ិនប៉ិចទេ នោះក៏គ្មានករណីបណ្តឹងដែរ។[11] ភ្លាមៗក្រោយពីការសម្រេចរបស់សាលាឧទ្ធរណ៍ ហ៊្វុនស៊ិនប៉ិចជាថ្មីម្តងទៀតបានបង្ហាញជំហរថា បញ្ហាករណីបណ្តឹងរបស់សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ នឹងត្រូវបានចប់ ប្រសិនបើទ្រង់យល់ព្រមយាងត្រឡប់មកចូលរួមដឹកនាំគណបក្សហ៊្វុនស៊ិនប៉ិចវិញ- អ្នកនាំពាក្យគណបក្សម្នាក់បានមានប្រសាសន៍ថា នៅពេលដែលទ្រង់យាងត្រលប់មកវិញ នោះបណ្តឹងនឹងត្រូវចប់ ។[12] មកដល់ពេលនេះ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ បានបដិសេធមិនព្រមបិទគណបក្សរបស់ព្រះអង្គ ហើយមិនព្រមយាងមកចូលរួមជាមួយហ៊្វុនស៊ិនប៉ិចជាថ្មីម្តងទៀតទេ ប៉ុន្តែ ទ្រង់នៅតែបន្តស្នើសុំព្រះរាជទានទោសដដែល។

ប្រវត្តិសាស្ត្រនយោបាយកម្ពុជាថ្មីៗនេះ ពោរពេញទៅដោយគំរូនៃការផ្តន្ទាទោសអ្នកនយោបាយជាន់ខ្ពស់នៅក្នុងការកាត់ក្តីដែលពេញទៅដោយការសង្ស័យយ៉ាងខ្លាំង ហើយមានតែការស្នើសុំព្រះរាជទានទោសនៅពេលក្រោយទេ ដែលជាផ្នែកមួយនៃដំណោះស្រាយនយោបាយ។ ការប្រើប្រាស់តុលាការម្តងហើយម្តងទៀតដើម្បីធ្វើជាឧបករណ៍គាបសង្កត់នយោបាយ ហើយការព្រះរាជទានទោស ឬ មិនមាននោះ ទាំងអស់នេះសុទ្ធតែផ្អែកលើការពិចារណាផ្នែកនយោបាយរបស់រដ្ឋាភិបាលទាំងអស់ នេះជាការផ្ញើសារឱ្យបានដឹងថា នីតិរដ្ឋគ្មានភាពប្រាកដនិយមទេទេសម្រាប់កម្ពុជា។

[10] យន់ សាមាន - ហ៊្វុនស៊ិនប៉ិចចង់ស្នើសុំព្រះរាជទានទោសថ្វាយព្រះម្ចាស់ នរោត្តម រណឫទ្ធិ -កាសែតឌឹខ្មែរបូឌាដេលី ថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០៧។

[11] យន់ សាមាន - សាលាឧទ្ធរណ៍តម្កល់សាលក្រមកាត់ទោសសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ -កាសែតឌឹខ្មែរបូឌាដេលី ថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៧។

[12] យន់ សាមាន សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ បានសុំព្រះរាជទានទោសពីព្រះមហាវិរៈក្សត្រ- កាសែត ឌឹខ្មែរបូឌាដេលី ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧។

## ព្រឹត្តិការណ៍: នយោបាយ និងការផ្តន្ទាទោស

- ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៥ លោក សម រង្ស៊ី ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ១៨ ខែពីបទបរិហាកេរ្តិ៍។
- ថ្ងៃទី០៥ ខែកុម្ភៈ លោក សម រង្ស៊ី ត្រូវបានតុលាការលើកលែងទោស។
- ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ហ៊ុន សែនបានបើកយុទ្ធនាការវាយប្រហារលើមន្ត្រីដែលមានស្រីកំណាន់។
- ថ្ងៃទី២-៣ ខែមិនា ឆ្នាំ២០០៦ កិច្ចប្រជុំពិគ្រោះយោបល់នៃក្រុមប្រទេសផ្តល់ជំនួយ។
- ថ្ងៃទី២-៣ ខែមិនា ឆ្នាំ២០០៦ វិសោធនកម្មរដ្ឋធម្មនុញ្ញ - រដ្ឋមន្ត្រីមកពីគណបក្សហ្វ៊ុនស៊ិនប៉ិចត្រូវបានបណ្តេញចេញពីតំណែង- សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ លាលែងពីតំណែងប្រធានរដ្ឋសភាជាតិ។
- ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៦ រដ្ឋសភាជាតិបានអនុម័តច្បាប់ដាក់អំពើសាហាយស្មន់ជាអំពើខុសច្បាប់។
- ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ បង្កើតគណបក្ស នរោត្តម រណឫទ្ធិ ប្រកាសថា ជា "គណបក្សប្រឆាំងថ្មី"។
- ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៦ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ត្រូវបានចោទប្រកាន់ពីបទរំលោភលើសេចក្តីទុកចិត្តហ្វ៊ុនស៊ិនប៉ិច ។
- ថ្ងៃទី១៣ ខែមិនា ឆ្នាំ២០០៧ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ត្រូវបានផ្តន្ទាទោសដាក់ពន្ធាគារ ១៨ខែ ពីបទរំលោភសេចក្តីទុកចិត្ត ។
- ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៧ ចាប់ផ្តើមយុទ្ធនាការឃោសនាបោះឆ្នោតឃុំ-សង្កាត់។
- ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០០៧ តុលាការបានប្រកាសថា សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ក៏ត្រូវបានចោទប្រកាន់ពីបទសាហាយស្មន់ដែរ ។
- ថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ បោះឆ្នោតឃុំ-សង្កាត់ គណបក្សនរោត្តម រណឫទ្ធិ ទទួលសម្លេងគាំទ្រច្រើនជាងហ្វ៊ុនស៊ិនប៉ិច ។
- ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៧ ហ្វ៊ុនស៊ិនប៉ិចមានចេតនាចង់ជួយស្នើសុំព្រះរាជទានទោសថ្វាយសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រសិនបើព្រះអង្គរំលាយគណបក្ស នរោត្តម រណឫទ្ធិចោល ។
- ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៧ សាលាឧទ្ធរណ៍តម្កល់សាលក្រមកាត់ទោសសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ក្រោមបទរំលោភសេចក្តីទុកចិត្ត ។

□□□

## ការសុំអភ័យទោស: អ្នកនយោបាយនៅមុខតុលាការ

| កាលបរិច្ឆេទ | ជនរងគ្រោះ | ការផ្តន្ទាទោស | អ្វីកើតឡើងក្រោយមក |
|---|---|---|---|
| **កុម្ភៈ ១៩៩៦** | ព្រះអង្គម្ចាស់ នរោត្តម សេរីវុឌ្ឍ អតីតអគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច។ | ព្រះអង្គម្ចាស់ នរោត្តម សេរីវុឌ្ឍ ត្រូវបានផ្តន្ទាទោសកំបាំងមុខដោយតុលាការក្រុងភ្នំពេញពីបទប៉ុនប៉ងធ្វើឃាដសម្តេច ហ៊ុន សែន ហើយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ១០ ឆ្នាំ ។ ទ្រង់ត្រូវបានចាប់ខ្លួនកាលពីខែវិច្ឆិកា ឆ្នាំ១៩៩៥ ប៉ុន្តែត្រូវបានអនុញ្ញាតឱ្យចាកចេញពីប្រទេស បន្ទាប់មកត្រូវរស់នៅនិរទេសព្រះកាយ មិនអនុញ្ញាតឱ្យចូលរួមធ្វើនយោបាយ និងចូលរួមចលនាណាមួយជាមួយលោក សម រង្ស៊ី។[១៣] | ព្រះអង្គម្ចាស់ ត្រូវបានលើកលែងទោសកាលពីខែវិច្ឆិកា ឆ្នាំ១៩៩៨ ជាផ្នែកមួយនៃការចរចារដោះស្រាយ ដើម្បីបង្កើតរដ្ឋាភិបាលចម្រុះរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច។<br>ទ្រង់បានត្រឡប់មកកម្ពុជាវិញនាឆ្នាំបន្ទាប់ ហើយត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ |
| **កញ្ញា ១៩៩៧** | លោក ស្រ៊ុន វង្សវណ្ណៈ ប្រធាន សន្តិសុខគណបក្សជាតិខ្មែរ (ក្រោយមកក្លាយជាគណបក្ស សម រង្ស៊ី) | លោក វណ្ណៈ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ១៣ ឆ្នាំ ដោយតុលាការក្រុងភ្នំពេញពីបទសម្លាប់លោក កូវ សាមុត ប្អូនថ្លៃ សម្តេច ហ៊ុន សែន។ គាត់ត្រូវបានចាប់ខ្លួនកាលពីខែកុម្ភៈ ឆ្នាំ១៩៩៧។ | លោក វណ្ណៈ ត្រូវបានលើកលែងទោសកាលពីខែកញ្ញា ឆ្នាំ១៩៩៨ ក្រោយពីជាប់ពន្ធនាគារអស់រយៈពេល ១ឆ្នាំកន្លះ ។ បច្ចុប្បន្ន គឺជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ។ |
| **មិនា ១៩៩៨** | សម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ កាលនោះជា | ទ្រង់រណឬទ្ធិ ត្រូវបានកាត់ទោសកំបាំងមុខផ្តន្ទាទោសដាក់ពន្ធនាគារ | ព្រះអង្គម្ចាស់ រណឬទ្ធិត្រូវបានលើកលែងទោស ៣ថ្ងៃ ក្រោយពីការកាត់ទោស។ |

[១៣] កម្ពុជា -ការគោរពសិទ្ធិមនុស្សដើរថយក្រោយ -អង្គការលើកលែងទោសអន្តរជាតិ - ខែឧសភា ឆ្នាំ១៩៩៦។

| | | | |
|---|---|---|---|
| | នាយរដ្ឋមន្ត្រី និងជាប្រធានគណបក្សហ៊្វុនស៊ីនប៉ិច ។ | រយៈពេល ៣០ ឆ្នាំ ដោយតុលាការយោធា ដោយចោទប្រកាន់ពីបទរួមគំនិតផ្តួលរំលំរដ្ឋាភិបាល ព្រមទាំងត្រូវបានពិន័យជាប្រាក់ចំនួន ៥៤ លាន ដុល្លារ ជាថ្នូរនឹងការខូចខាតនៅក្នុងរដ្ឋប្រហារផ្តួលរំលំទ្រង់កាលពីឆ្នាំមុន ។ | ព្រះអង្គបានយាងត្រឡប់មកកម្ពុជាវិញ ហើយដឹកនាំហ៊្វុនស៊ីនប៉ិចនៅក្នុងការបោះឆ្នោតជាតិឆ្នាំ១៩៩៨ រួចបានបង្កើតរដ្ឋាភិបាលចម្រុះជាមួយនឹងគណបក្ស ប្រជាជនកម្ពុជា ហើយត្រូវបានតែងតាំង ជាប្រធានរដ្ឋសភាជាតិ ។ |
| **មិនា ១៩៩៨** | ឧត្តមសេនីយ៍ គណបក្សហ៊្វុនស៊ីនប៉ិច លោក ញឹក ប៊ុនឆៃ សេរី កុសល និង ចៅ សម្បត្តិ (គាត់ត្រូវបានសម្លាប់ដោយខុសច្បាប់កាលពីខែកក្កដា ឆ្នាំ១៩៩៧ ។[១៤] | លោក ញឹក ប៊ុនឆៃ សេរី កុសល និងចៅ សម្បត្តិ ត្រូវបានកាត់ទោសកំបាំងមុខដោយតុលាការយោធាពីបទសមគំនិតក្នុងការផ្តួលរំលំរដ្ឋាភិបាល ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារម្នាក់ៗ ២០ ឆ្នាំ ។ | លោកញឹក ប៊ុនឆៃ និងសេរី កុសល ត្រូវបានលើកលែងទោសកាលពីខែវិច្ឆិកា ឆ្នាំ ១៩៩៨ ជាផ្នែកមួយនៃការចរចាបង្កើតរដ្ឋាភិបាលចម្រុះរវាងគណបក្សប្រជាជនកម្ពុជា និងហ៊្វុនស៊ីនប៉ិច ។ លោក ញឹក ប៊ុនឆៃ ក្រោយមកត្រូវបានតែងតាំងជាសហរដ្ឋមន្ត្រីការពារជាតិ ។ |
| **សីហា ២០០៥** | លោក ជាម ចន្នី សមាជិករដ្ឋសភារបស់គណបក្ស សម រង្ស៊ី ដែលលេចធ្លោជាងគេ ។ | លោក ជាម ចន្នី ត្រូវបានកាត់ទោស ដោយតុលាការយោធា ដាក់ពន្ធនាគារ ៧ ឆ្នាំ ពីបទបង្កើតកងកម្លាំងប្រដាប់អាវុធខុសច្បាប់ ។ | លោក ជាម ចន្នីត្រូវបានលើកលែងទោសកាលពី ខែកុម្ភៈ ឆ្នាំ២០០៦ ជាមួយ សម រង្ស៊ី (សូមមើលខាងក្រោម) គាត់បានត្រឡប់មកធ្វើនយោបាយវិញ ។ |
| **ធ្នូ ២០០៥** | លោក សម រង្ស៊ី ប្រធានគណបក្សសម រង្ស៊ី ។ | លោក សម រង្ស៊ី ត្រូវបានកាត់ទោសកំបាំងមុខ ឱ្យជាប់ពន្ធនាគារ ១៨ខែ ដោយតុលាការក្រុងភ្នំពេញ ពីបទបរិហារកេរ្តិ៍សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ។ | លោក សម រង្ស៊ី ត្រូវបានលើកលែងទោសកាលពីខែ កុម្ភៈ ២០០៦ បន្ទាប់ពីសរសេរសុំទោស នឹងសម្តែងការសោកស្តាយចំពោះកំហុសរបស់ខ្លួនផ្ញើជូនលោក ហ៊ុន សែន ហើយឈប់បន្តប្តឹងលោក ហ៊ុន សែន នៅអាមេរិកក្នុងករណីវាយប្រហារដោយ |

[១៤] តុលាការយោធាកោះហៅមនុស្សស្លាប់មកផ្តន្ទាទោស — អង្គការលើកលែងទោសអន្តរជាតិ ថ្ងៃទី១៧ ខែមិនា ឆ្នាំ១៩៩៨ ។

| | | | |
|---|---|---|---|
| | | | គ្រាប់បែកឆ្នាំ១៩៩៧ ។[១៥] មួយខែក្រោយ មក គណបក្សសម រង្ស៊ី បានគាំទ្រការធ្វើ វិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលធ្វើឱ្យមាន ការបាត់បង់ដល់តួនាទីរបស់ហ៊្វុនស៊ីនប៉ិច យ៉ាងខ្លាំងនៅក្នុងរដ្ឋាភិបាល ។ |
| **មិនា ២០០៧** | ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បច្ចុប្បន្នជាប្រធានគណបក្ស នរោត្តម រណឫទ្ធិ ដែលទើបតែបង្កើតថ្មី ។ | ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ត្រូវបានកាត់ទោសកំបាំងមុខ ផ្តន្ទាទោសដាក់ពន្ធនាគារ ១៨ខែ ដោយតុលាការក្រុងភ្នំពេញពីបទរំលោភលើសេចក្តីទុកចិត្ត ។ | ? |

□□□

[១៥] លោក សម រង្ស៊ី ប្តឹងនៅឆ្នាំ២០០៥ ជាមួយនិងដើមបណ្តឹងកម្ពុជាពីរនាក់ និងលោក រុន អាប៊ីនី ជនជាតិអាមេរិក ដែលរងរបួសដោយអំពើគប់គ្រាប់បែក ក្រោមច្បាប់ទាមទារទារុណ្ណកម្មបរទេស និងច្បាប់ការពារជនរងគ្រោះដោយអំពើទារុណ្ណកម្ម ។

# ៣. តុលាការ និងសេរីភាពក្នុងការបញ្ចេញមតិ

ក្រោយពីមានការប្រឆាំងតវ៉ាចំពោះការផ្តន្ទាទោស លោក សម រង្ស៊ី ពីបទបរិហារកេរ្តិ៍ និងការឃុំឃាំងសកម្មជនសិទ្ធិមនុស្សក្រោមការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងញុះញង់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់នូវចេតនាក្នុងការដកបទបរិហារកេរ្តិ៍ចេញពីទោសឧក្រិដ្ឋ មុននឹងកិច្ចប្រជុំពិគ្រោះយោបល់ក្រុមប្រទេសផ្តល់ជំនួយឈានចូលមកដល់នៅខែមិនា ឆ្នាំ២០០៦។[១៦] មកដល់ពេលនេះ បទបរិហារកេរ្តិ៍នៅតែមិនទាន់ត្រូវបានដកចេញពីបទឧក្រិដ្ឋនៅឡើយ ។ ទោះបីជារដ្ឋសភាជាតិបានបោះឆ្នោតគាំទ្រកាលពី ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦ កន្លងទៅ ដើម្បីដកបទបរិហារកេរ្តិ៍ចេញពីទោសជាប់ពន្ធនាគារក្តី ក៏វានៅតែជាបទល្មើសព្រហ្មទណ្ឌដដែល ដែលអ្នកបរិហារអាចត្រូវបានចាប់ខ្លួន ហើយពិន័យជាប្រាក់រហូតដល់ ២.៥០០ដុល្លារ ជាសំណងជម្ងឺចិត្ត។ បទបរិហារកេរ្តិ៍នៅតែបន្តនាំខ្លួន ចាប់ខ្លួន ហើយជនរងគ្រោះត្រូវបានឃុំឃាំង ហើយភាគច្រើន គឺជាករណីបរិហារកេរ្តិ៍ ឬជេរប្រមាថបុគ្គលដែលជិតដិតនឹងរដ្ឋាភិបាល។ ឧទាហរណ៍ -ចាប់តាំងពីខែ ខែមិនា ឆ្នាំ២០០៦ មករួមមាន:

- ជូលីយោ ជែលជ្រិស អ្នកសរសេរជីវប្រវត្តិរបស់ព្រះករុណាព្រះមហាវីរក្សត្រ នរោត្តម សីហនុ ត្រូវបានកាត់ទោសកំបាំងមុខដោយតុលាការក្រុងភ្នំពេញពីបទបរិហារកេរ្តិ៍លោក ហ៊ុន សែន កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៦ ។ តុលាការបានបញ្ជាឱ្យគាត់បង់ប្រាក់ពិន័យចំនួន២.០០០ដុល្លារ និងសងជម្ងឺចិត្ត ២.៥០០ដុល្លាផ្សេងទៀត។ ជែលជ្រិសត្រូវបានដកស្រង់សម្តីដោយកាសែតមួយដោយគាត់បាននិយាយថា "អ្នកឯងដឹងទេ នៅពេលណាដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គំរាមប្រាកដជាមានមនុស្សណាម្នាក់ស្លាប់ ឬរងរបួសដោយក្រុមជនពាលដែលមិនស្គាល់មុខជាមិនខាន" ។ មេធាវីរបស់គាត់បាននិយាយថា "ការដកស្រង់សម្តីនោះត្រូវបានផ្ញើតាមអ៊ីម៉ែល ហើយពុំបានផ្សព្វផ្សាយជាសាធារណៈទេ ។ ព្រះរាជអាជ្ញា សុខ រឿន បានបញ្ជាក់ថា ទោះជាផ្ញើតាមអ៊ីម៉ែលក្តី ក៏នៅតែជាបទបរិហារកេរ្តិ៍ដែរ ពីព្រោះវាត្រូវបានផ្ញើទៅមនុស្សច្រើននាក់។

- មន្ត្រីគយក្រុងព្រះសីហនុម្នាក់ឈ្មោះ ប្រាក់ ចន្ទី ត្រូវបានកាត់ទោសដោយតុលាការក្រុងភ្នំពេញដោយផ្តន្ទាទោសដាក់ពន្ធនាគារ ៨ ថ្ងៃ កាលពីខែ ឧសភា ២០០៧ (ដែលត្រូវបានជាប់ឃុំរួចហើយ) និងព្យួរទោសសាកល្បង៥ ខែ ដោយបាន"ជេរប្រមាថ"ប្រពន្ធលោក ឌិត មន្ទីរ ប្រធានតុលាការកំពូលកាលពីឆ្នាំ២០០២។ ការជេរប្រមាថនោះត្រូវបានធ្វើឡើងតាមរយៈការសន្ទនាតាមទូរស័ព្ទ

[១៦] យុន សាមាន : ហ៊ុន សែន : បទបរិហារកេរ្តិ៍គួរតែដកចេញពីបទព្រហ្មទណ្ឌ-កាសែតឌឹឃែមបូឌាដេលី ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៦។

រវាងភាគីទាំងពីរ ហើយករណីនេះ សូម្បីតែចៅក្រមជំនុំជម្រះក៏បានលើកឡើងថា គាត់មិនដឹងនិយាយាថាយ៉ាងម៉េចដែរ។ "ជេរប្រមាថ " មានចែងនៅក្នុងមាត្រានិយាយអំពីបទបរិហារកេរ្តិ៍នៃក្រមព្រហ្មទណ្ឌ។ [១៧]

- ម៉ូ រ៉ាវី នៅភ្នំពេញ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៧ ពីបទជេរប្រមាថសមាជិកសភាគណបក្សប្រជាជនកម្ពុជា ឯកឧត្តម នៃ ប៉េណា ។ នគរបាលបានឃុំខ្លួនគាត់អស់រយៈពេល ២ ថ្ងៃ ហើយក្រោយមកត្រូវបានសួរចម្លើយដោយតុលាការក្រុងភ្នំពេញ ហើយត្រូវឃុំបន្តមួយយប់ទៀត។ លោក នៃ ប៉េណា ប្រាប់អ្នកកាសែតថា នៅពេលដែល រ៉ាវី និងប្ដីរបស់នាងកំពុងជេរប្រមាថគាត់នៅក្នុងជម្លោះរវាងគ្រួសារមួយ គាត់បានហៅទូរស័ព្ទទៅឧត្តមសេនីយ៍ ហុក ឡុងឌី ដែលជាអគ្គនាយកនគរបាលជាតិ ដើម្បីឱ្យចាប់ពួកគេភ្លាម។ ក្រោយមកគាត់បាននិយាយថា មនុស្សពីរនាក់ប្ដីប្រពន្ធនោះ បានសម្ដែងនូវការសោកស្ដាយយ៉ាងខ្លាំងចំពោះការជេរប្រមាថនេះ ដោយពួកគេពុំដឹងថា ខ្ញុំជានរណា។ [១៨]

លើសពីនេះទៅទៀតអ្នកសង្កេតការណ៍មួយចំនួនបានសម្ដែងនូវការភ័យខ្លាចថា ការបន្ថយការផ្ដន្ទាទោសចំពោះបទបរិហារកេរ្តិ៍អាចបណ្ដាលឱ្យមានការកើនឡើងនៃការចោទប្រកាន់ចំពោះបទផ្ដល់ព័ត៌មានមិនពិតដែលយោងទៅតាមច្បាប់ដូចគ្នានេះ ដែលការផ្ដន្ទាទោសដាក់ពន្ធនាគាររហូតដល់ ៣ឆ្នាំ នៅតែត្រូវបានអនុវត្ត ។ ជាក់ស្ដែងនៅ វាបានកើតឡើងដូចដែលបានទស្សទាយទុកជាមុនមែន។

- សកម្មជនខ្មែរកម្ពុជាក្រោមបីនាក់ត្រូវបានឃុំខ្លួនកាលពីខែកញ្ញា ឆ្នាំ២០០៦ ដោយតុលាការក្រុងភ្នំពេញចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត ដោយបានចែកផ្សាយខិតប័ណ្ណរិះគន់លោក ហ៊ុន សែន ។ នៅខែកុម្ភៈ ឆ្នាំ២០០៧ ពួកគេទាំង បីនាក់ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារ ៦ខែ ដែលពួកគេបានជាប់នៅមុនពេលកាត់ក្ដីរួចហើយ ដូច្នេះតុលាការដោះលែងតែម្ដង។
- នៅក្នុងខែកញ្ញា ឆ្នាំ២០០៦ នោះដែរ លោក ដាំ សិទ្ធិ និពន្ធនាយកកាសែតមនសិការខ្មែរ ត្រូវបានកាត់ទោសកំបាំងមុខ ដោយតុលាការក្រុងភ្នំពេញ ពីបទចោទប្រកាន់ផ្សាយព័ត៌មានមិនពិត និងបរិហារកេរ្តិ៍ ក្រោយពីបានចេញផ្សាយអត្ថបទព័ត៌មានមួយចោទប្រកាន់ លោកឧបនាយករដ្ឋមន្ត្រី សុខ អានថា ជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ។ គាត់ត្រូវបានផាកពិន័យជាប្រាក់ចំនួន ២.០០០

[១៧] ប្រាក់ ចាន់ថុលៈ បុរសម្នាក់ត្រូវបានផ្ដន្ទាទោសពីបទជេរប្រមាថប្រពន្ធចៅក្រម -កាសែត ឌឹឃែមបូឌាដេលី ថ្ងៃទី៣ ខែមិនា ឆ្នាំ២០០៧។

[១៨] អ្នកតាក់តែងច្បាប់អះអាងថា ប្ដីប្រពន្ធមួយគូរជេរប្រមាថខ្លួន- គំរាមគាត់- កាសែតឌឹឃែមបូឌាដេលី ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ ។ ពីរនាក់ប្ដីប្រពន្ធបានសុំទោសជាសាធារណៈចំពោះការជេរប្រមាថមន្ត្រីរដ្ឋាភិបាល- កាសែតឌឹឃែមបូឌាដេលី ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧។

ដុល្លារ ចំពោះការផ្សាយព័ត៌មានមិនពិត នឹងបញ្ជាឱ្យសងជម្ងឺចិត្តលោក សុខ អាន ចំនួន២.៥០០ ដុល្លារទៀត ។ [១៩]

- ខែមិថុនា ឆ្នាំ២០០៦ លោក យូ សារារុធ និពន្ធនាយកកាសែតស្រឡាញ់ខ្មែរ ត្រូវបានលោក ហ៊ុន តូ ក្មួយប្រុសរបស់លោក ហ៊ុន សែន ប្តឹងពីបទផ្សាយព័ត៌មានមិនពិត ។ លោក យូ សារារុធ បានភៀសខ្លួនចេញពីប្រទេសកម្ពុជា ហើយដាក់ពាក្យសុំសិទ្ធិជ្រកកោននយោបាយ ក្រោយពីទទួលការគំរាមកំហែងដល់អាយុជីវិត ។ [២០] នៅខែកុម្ភៈ ឆ្នាំ២០០៧ និពន្ធនាយកថ្មីនៃកាសែតស្រឡាញ់ខ្មែរ ត្រូវបានកោះហៅដោយតុលាការក្រុងភ្នំពេញ ដើម្បីសួរចម្លើយអំពីការផ្សាយព័ត៌មានមិនពិត និងជេរប្រមាថលោក ជីវ កេង ប្រធានតុលាការក្រុងភ្នំពេញ ។ [២១]

- ការរំលោភច្បាប់ផ្សាយព័ត៌មានមិនពិតដ៏ធ្ងន់ធ្ងរបំផុតនៅក្នុងកំឡុងពេលនេះគឺ លោក ទៀង ណារិទ្ធិ សាស្ត្រាចារ្យច្បាប់ និងនយោបាយនៃពុទ្ធកសកលវិទ្យាល័យព្រះសីហនុរាជភ្នំពេញ ។ លោក ណារិទ្ធិ ត្រូវបានចាប់ខ្លួនដោយខុសច្បាប់កាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៦ ក្រោយពីបានបង្រៀនតាមសៀវភៅដែលសរសេរដោយខ្លួនឯង ដែលមានការរិះគន់លោក ហ៊ុន សែន និងរដ្ឋាភិបាលទាំងមូល ដោយចោទប្រកាន់ថា បានប្រព្រឹត្តបទឧក្រិដ្ឋជាច្រើន ។ ក្រោយពីមានការអះអាងថា លោក ណារិទ្ធិ ជាមនុស្សមានជម្ងឺសរសៃប្រសាទធ្ងន់ធ្ងរ តុលាការក្រុងភ្នំពេញបានស្នើឱ្យមានការវាយតម្លៃផ្នែកផ្លូវចិត្តចំពោះគាត់ ។ វេជ្ជបណ្ឌិត កា ស៊ុនបូណាត នាយកមហាវិទ្យាល័យវេជ្ជសាស្ត្រនៃសកលវិទ្យាល័យវិទ្យាសាស្ត្រសុខភាពភ្នំពេញ និងជាទីប្រឹក្សាជាន់ខ្ពស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភាជាតិ ជាអ្នកដឹកនាំក្រុមវាយតម្លៃ ។ លោក ស៊ុនបូណាត បាននិយាយថា គាត់បានធ្វើរបាយការណ៍ជូនក្រសួងសុខាភិបាល ដើម្បីផ្ញើបន្តទៅតុលាការ ប៉ុន្តែមេធាវីការពារក្តីរបស់លោក ណារិទ្ធិ នៅតែពុំអាចទទួលបានរបាយការណ៍នោះនៅឡើយ ហើយការស្នើសុំឱ្យមានការវាយតម្លៃជាលើកទីពីរត្រូវបានបដិសេធ ។ [២២] នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០០៧ ណារិទ្ធិ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ២ឆ្នាំ និង៦ខែ ព្រមទាំងពិន័យ ១.២៥០ ដុល្លារ ។ ហើយរបាយការណ៍ស្តីពីជម្ងឺផ្លូវចិត្តរបស់គាត់ នៅតែរកមិនឃើញដដែល ។ [២៣]

---

[១៩] កម្ពុជាៈ អ្នកកាសែតម្នាក់ត្រូវបានផ្តន្ទាទោសពីបទចុះផ្សាយអំពើពុករលួយរបស់ឧបនាយករដ្ឋមន្ត្រី -AHRC, ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៦ ។

[២០] និពន្ធនាយក-ភៀសខ្លួនដោយសារការគំរាមដល់អាយុជីវិត ដោយសារអត្ថបទរិះគន់- គាត់ត្រូវបានផ្តល់សិទ្ធិជ្រកកោននៅប្រទេសថៃ ។ សេចក្តីថ្លែងសារព័ត៌មានរបស់ SEAPA/IFEX ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៦ ។

[២១] ប្រាក់ ចាន់ថុលៈ និពន្ធនាយកនិយាយថា -តុលាការភ្នំពេញប្តឹងកាសែត -កាសែតឌឹខេមបូឌាលើ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៦ ។

[២២] ប្រាក់ ចាន់ថុលៈ ចៅក្រមបានបដិសេធការពិនិត្យរោគផ្លូវចិត្តសារជាថ្មីក្នុងករណីគ្រូបង្រៀន-កាសែត ឌឹខេមបូឌាដេលី ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៦ ។

[២៣] ប្រាក់ ចាន់ថុលៈ សាស្ត្រាចារ្យជាប់ពន្ធនាគារដោយបង្រៀនពីអត្ថបទរិះគន់រដ្ឋាភិបាល- កាសែតឌឹខេមបូ ឌាដេលី ថ្ងៃទី០១ ខែមិនា ឆ្នាំ២០០៧ ។

# ៤. តុលាការ និងនិទ្ទណ្ឌភាព

ពួកជនល្មើសដែលមានអំណាចតែងតែទទួលបាននិទ្ទណ្ឌភាពពីការប្រព្រឹត្តិនូវបទល្មើសធ្ងន់ធ្ងរ ហើយនេះជាបញ្ហាដ៏ធំមួយដែលប៉ះពាល់កម្ពុជាសព្វថ្ងៃនេះ។ ដូចដែលតំណាងពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបានសរសេរក្នុងរបាយការណ៍ឆ្នាំ២០០៦ ផ្ញើជូនក្រុមប្រឹក្សាសិទ្ធិមនុស្សថា" និទ្ទណ្ឌភាពមានន័យថាពលរដ្ឋកម្ពុជាមិនត្រូវបានការពារដោយច្បាប់ទេ"។ មាននិទ្ទណ្ឌភាព គ្មានកិច្ចការពារសិទ្ធិមនុស្សទេ ។ និទ្ទណ្ឌភាពគឺផ្ទុយនឹងការទទួលខុសត្រូវ និងជាប្រតិនិក្ខេបបទ (ផ្ទុយ)នឹងនីតិរដ្ឋ ។[២៤]

ការវាយប្រហារដោយគ្រាប់បែកទៅលើបាតុកម្មមួយដែលដឹកនាំដោយលោក សម រង្ស៊ី កាលពីថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៩៧ អាចជាគំរូនៃនិទ្ទណ្ឌភាព ដែលគួរឱ្យកត់សម្គាល់ជាទីបំផុតនៅកម្ពុជា ក្នុងសម័យក្រោយសង្គ្រាមនេះ ។ យ៉ាងហោចណាស់មនុស្ស ១៦នាក់ បានស្លាប់ និងមួយចំនួនធំទៀត ក្លាយជាមនុស្សពិការ។ អំពើវាយប្រហារនេះ ពុំមាននរណាម្នាក់ត្រូវបានផ្តន្ទាទោសឡើយ ដែលបញ្ហានេះបណ្តាលឱ្យកើតមានជាហូរហែរទៀត រហូតមកដល់សព្វថ្ងៃ។ លោក សម រង្ស៊ី និងមនុស្សបីនាក់ទៀត បានដាក់ពាក្យបណ្តឹងប្តឹងលោក ហ៊ុន សែន នៅតុលាការក្រុងញូវយ៉ក ហើយបណ្តឹងនេះត្រូវបានផ្អាកទៅវិញនៅពេលដែល លោក សម រង្ស៊ី ត្រូវបានលើកលែងពីការកាត់ទោសជាប់ពន្ធនាគារ ១៨ ខែ កាលពីខែកុម្ភៈ ឆ្នាំ២០០៦ កន្លងទៅនេះ។ ថ្មីៗនេះ សាលាក្រុងភ្នំពេញបានស្នើរុះរើចេតិយអនុស្សាវរីយ៍ចេញ ចេតិយនោះត្រូវបានកសាងនៅជិតកន្លែងដែលហេតុការណ៍នោះ បានកើតឡើងនៅខាងមុខរដ្ឋសភាជាតិចាស់ ដើម្បីធ្វើការ"ការអភិវឌ្ឍ"។[២៥] ប្រធានរដ្ឋសភាជាតិ លោក ហេង សំរិន បានមានប្រសាសន៍ថា ចេតិយនោះគួរតែរុះរើចេញ ពីព្រោះវានាំឱ្យប៉ះពាល់ដល់វិស័យ"ទេសចរណ៍"។[២៦]

ករណីឃាដកម្មជាច្រើនទៀតដែលកើតឡើងក្នុងឆ្នាំថ្មីៗនេះ នៅតែមិនទាន់ត្រូវបានផ្តន្ទាទោសជនល្មើសដដែល ឬផ្តន្ទាទោស ដែលមិនអាចទទួលយកបាន។ មានភស្តុតាងយ៉ាងច្រើនសម្បើមណាស់ដែលអាចបញ្ជាក់ថាបុរសពីរនាក់ដែលត្រូវបានផ្តន្ទាទោសពីបទធ្វើឃាដលោក ជា វិជ្ជា ប្រធានសហជីពសេរីកម្មករកាលពីខែមករា ឆ្នាំ២០០៤ កន្លងទៅ ជាមនុស្សគ្មានទោស (សូមអានទំព័រ២៥)។ ហើយក៏មានការបារម្ភយ៉ាងខ្លាំងចំពោះការផ្តន្ទាទោសនៅក្នុងករណីឃាដកម្មអ្នកនយោបាយគណបក្សហ៊្វុនស៊ិន លោក ឱម រ៉ាដ្ឋសាឌី កាលពីខែកុម្ភៈ ឆ្នាំ២០០៣

---

[២៤] យ៉ាសហ្គាយៈ របាយការណ៍តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា - A/HRC/៤.៣៦ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧។

[២៥] យុន សាមានៈ ចេតេយអនុស្សាវរីយ៍ដោយអំពើគប់គ្រាប់បែកមិនអាចជាផ្នែកមួយនៃសួនច្បារមុខរដ្ឋសភាតទៀតទេ។

[២៦] យុន សាមាន និង ឡោ ចាន់ដារ៉ាៈ រដ្ឋាភិបាលៈ ចេតេយអនុស្សាវរីយ៍ដោយអំពើគប់គ្រាប់បែក គួរតែរុះរើចេញ- កាសែតឌឹខេមបូឌា ដេលី ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៧។

កន្លងទៅ និងសកម្មជនសហជីព រស់ សុវណ្ណារ៉េត កាលពីខែឧសភា ឆ្នាំ២០០៤។ ហើយក៏នៅមានករណីឃាដកម្មធំៗជាច្រើនទៀត ដែលគ្មាននរណាម្នាក់ ត្រូវបានផ្តន្ទាទោសទាល់តែសោះ ដូចជាករណីឃាដកម្មលើអ្នកចម្រៀង ពិសិដ្ឋ ពីលិកា កាលពីខែកក្កដា ឆ្នាំ១៩៩៩ ព្រះសង្ឃព្រះនាម សំ ប៊ុនធឿន កាលពីខែកុម្ភៈ ឆ្នាំ២០០៣ អ្នកយកព័ត៌មានវិទ្យុ ដែលជិតស្និទ្ធជាមួយគណបក្សហ៊្វុនស៊ីនប៉ិច លោក ជូរ ជាតិថាវីរិទ្ធិ កាលពីខែតុលា ឆ្នាំ២០០៣ និងថ្មីៗបំផុតគឺអ្នកដឹកនាំសហជីព លោក ហ៊ី វុធី កាលពីខែកុម្ភៈ ឆ្នាំ២០០៧ កន្លងទៅនេះ។

និទ្ទណ្ឌភាពក៏អាចមើលឃើញយ៉ាងច្បាស់នៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់អ្នកមានអំណាចដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ហើយគេចពីការផ្តន្ទាទោស ភាគច្រើនគឺនៅក្រោយពេលសងជម្ងឺចិត្តទៅឱ្យជនរងគ្រោះ ឬគ្រួសារជនរងគ្រោះរួចហើយ។ ពេលសួរអំពីករណីបែបនេះ តុលាការ និងនគរបាលតែងតែឆ្លើយដាក់គ្នាទៅវិញទៅមក។ តុលាការច្រើនតែអះអាងថា ខ្លួនមិនអាចចាត់វិធានការដោយគ្មានរបាយការណ៍ពីនគរបាលទេ ឬបណ្តឹងពីជនរងគ្រោះឡើយ។ ប៉ុន្តែ តាមច្បាប់កម្ពុជា ព្រះរាជអាជ្ញាមានកាតព្វកិច្ចក្នុងការស៊ើបអង្កេតរាល់បទល្មើសដែលកើតឡើង ហើយខ្លួនបានទទួលព័ត៌មាន ទោះបីជានគរបាលពុំបានរាយការណ៍ ឬគ្មានបណ្តឹងផ្លូវការក៏ដោយ។[២៧]

ជាការពិត នេះពុំមែនទុកឱ្យនគរបាលដោះសារពុំទទួលខុសត្រូវទេ ។ ការឆ្លើយទៅនឹងករណីជាច្រើននៅក្នុងឆ្នាំ២០០៦-០៧ដែលសមាជិកនគរបាល និងកងប្រដាប់អាវុធមិនត្រូវបានផ្តន្ទាទោសចំពោះការប្រព្រឹត្តល្មើសនៅក្រៅភារកិច្ច - អ្នកនាំពាក្យក្រសួងមហាផ្ទៃ ឧត្តមសេនីយ៍ទោលោក ខៀវ សុភ័គ្គ បាននិយាយថា នៅពេលដែលបទល្មើសមួយមិនបណ្តាលឱ្យមានការបាត់បង់អាយុជីវិត ជនល្មើស និងជនរងគ្រោះជួនកាលជ្រើសរើសយក ដំណោះស្រាយដោយ "ការសម្របសម្រួល "។ នគរបាល នៅពេលដែលជនរងគ្រោះយល់ព្រម ( ដោះស្រាយតាមការសងជម្ងឺចិត្ត ) យើងមិនអាចជ្រៀតជ្រែកបានទេ" គាត់និយាយបន្ថែមទៀតថា ការផ្តន្ទាទោសជនល្មើស គឺជាការទទួលខុសត្រូវរបស់តុលាការ។[២៨] ការពិតតាមផ្លូវច្បាប់ បទល្មើសព្រហ្មទណ្ឌមិនត្រូវដោះស្រាយក្រៅប្រព័ន្ធតុលាការតាមរូបភាពណាមួយឡើយ។ ការមិនអនុវត្តតាមគោលការណ៍នេះ អាចចាត់ទុកថាជាការអនុវត្តន៍យុត្តិធម៌ខុសឆ្គង ហើយត្រូវដាក់វិន័យចំពោះអ្នកអនុវត្តខុស និងចាត់វិធានការព្រហ្មទណ្ឌចំពោះមន្ត្រីពាក់ព័ន្ធ។[២៩]

---

[២៧] ច្បាប់ស្តីពីនិតិវិធីព្រហ្មទណ្ឌ (១៩៩៣) មាត្រា ៥៦- សារាចររបស់ក្រសួងយុត្តិធម៌ផ្សព្វផ្សាយដល់ព្រះរាជអាជ្ញា (១៩៩៨) ។ មានលក្ខណៈស្រដៀងគ្នា ប៉ុន្តែមាត្រាថ្មីមានភាពមិនសូវច្បាស់លាស់នៅក្នុងសេចក្តីព្រាងច្បាប់ក្រមនីតិវិធីព្រហ្មទណ្ឌថ្មី (២០០៧) ដែលតម្រូវ (មាត្រា៤៤) ឱ្យព្រះរាជអាជ្ញាបើកការស៊ើបអង្កេតនៅក្នុងរាល់ករណីព្រហ្មទណ្ឌទាំងអស់។

[២៨] ឆាយ ចាន់នីដា និង អេលីហ្សាបេត ថូមី - អ្នកចម្រៀងរួចជីវិតពីការបាញ់ប្រហារ - នគរបាលមិនចាប់ខ្លួនជនណាម្នាក់ទេ- កាសែត ឌឹភៃមបូឌាដេលី ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧។

[២៩] ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (១៩៩៣) មាត្រា ៧។ ច្បាប់ស្តីពីនិតិវិធីព្រហ្មទណ្ឌថ្មី (២០០៧)នៅតែរក្សាគោលការណ៍នេះ ស្តីពី (មាត្រា ៧៥) ដែលចែងថា នគរបាលយុត្តិធម៌អាចមិនបិទករណីព្រហ្មទណ្ឌ ទោះបីជាមានការផ្សះផ្សាររវាងជនល្មើស និងជនរងគ្រោះ ឬបណ្តឹងត្រូវបានដកក៏ដោយ ។

(១៦) របាយការណ៍លីកាដូ

ក្នុងកំឡុងពេល ១៥ខែ កន្លងមកមានករណីតិចតួចបំផុត ដែលមន្ត្រីប្រព្រឹត្តខុសត្រូវបានផ្តន្ទាទោសប្រកបដោយជោគជ័យ។ ករណីមួយដែលគួរឱ្យកត់សំគាល់គឺ អតីតស្នងការនគរបាលរាជធានីភ្នំពេញលោក ហេង ពៅ និងសហការីគាត់ជាច្រើននាក់ទៀត ថ្មីៗនេះត្រូវបានផ្តន្ទាទោសដោយបានប្រព្រឹត្តបទឧក្រិដ្ឋជាច្រើន ដូចជាការសម្លាប់ចៅក្រម លោក សុខ សេដ្ឋាមុន្នី ក្នុងឆ្នាំ២០០៣។[៣០] ប្រសិនបើការចោទប្រកាន់ចំពោះលោក ហេង ពៅ និងសហការីរបស់គាត់ជាការពិត នោះការផ្តន្ទាទោសត្រូវបានស្វាគមន៍តែត្រូវបានអូសបន្លាយពេលវេលាយ៉ាងយូរ។ ប៉ុន្តែ គេអាចមើលឃើញយ៉ាងច្បាស់ថា ការផ្តន្ទាទោសនេះវាជាករណីលើកលែងច្រើនជាងការអនុវត្តន៍បទបញ្ជាដោយវាបង្ហាញនូវចេតនាក្នុងការបញ្ចប់និទ្ទណ្ឌភាពតិចតួចជាទីបំផុត ដោយអ្នកសង្កេតការណ៍ភាគច្រើនបានកត់សំគាល់ឃើញថា ហេង ពៅ ត្រូវបានផ្តន្ទាទោសបន្ទាប់ពីគាត់បានធ្លាក់ពីតំណែងក្នុងរដ្ឋាភិបាលតែប៉ុណ្ណោះ ដូច្នេះជាគោលការណ៍អ្នកដែលនៅមានតំណែងនៅឡើយតែងតែរួចខ្លួនជានិច្ច ។

ឧទាហរណ៍ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ សហការីរបស់ លោក ហេង ពៅ ៦ នាក់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារម្នាក់ៗ ១២ឆ្នាំ ក្រោមការចោទប្រកាន់ពីបទធ្វើទារុណ្ឌកម្មស្ត្រីម្នាក់រហូតដល់ស្លាប់នៅក្នុងមន្ទីរឃុំឃាំងរបស់នគរបាលកាលពីខែមិថុនា ឆ្នាំ២០០៥ ជាករណីមួយដែល ហេង ពៅ ក៏មានការពាក់ព័ន្ធផងដែរ ។[៣១] ប៉ុន្តែផ្ទុយទៅវិញ ការប៉ុនប៉ងម្តងហើយម្តងទៀតក្នុងការនាំខ្លួននគរបាលខេត្តព្រៃវែង បីនាក់ ដែលបានធ្វើទារុណ្ឌកម្មចោរម្នាក់ឈ្មោះ អ៊ិត អឿន រហូតដល់ស្លាប់កាលពីខែកក្កដា ឆ្នាំ២០០១ កន្លងទៅ នៅតែពុំទាន់បានជោគជ័យនៅឡើយ សវនាការដែលគ្រោងធ្វើកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៧ បែរជាត្រូវលើកពេលទៅវិញ ដោយជនសង្ស័យដែលកំពុងស្ថិតនៅក្នុងតំណែងរបស់ខ្លួននៅឡើយនោះ "ជាប់រវល់ភារកិច្ចច្រើនពេក" ហើយពុំអាចឆ្លៀតពេលចូលរួមសវនាការបាន។[៣២]

នេះគឺជាលក្ខណៈពិសេសនៃកម្ពុជាបច្ចុប្បន្ន ដែលមន្ត្រីសាធារណៈ សាច់ញាតិ និងមនុស្សផ្សេងៗជាច្រើនទៀតស្ថិតក្រោមកិច្ចការពាររបស់ពួកគេ ដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ហើយបានដឹងថា ពួកគេនឹងមិនត្រូវបានផ្តន្ទាទោសឡើយ។[៣៣]

---

[៣០] ទិត្យ សុធាៈ ហេង ពៅ ត្រូវបានកាត់ទោសកំបាំងមុខដាក់ពន្ធនាគារ ១៨ ឆ្នាំ -ព័ត៌មានសម្លេងសហរដ្ឋអាមេរិក ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៦។

[៣១] ខាត បាតថុនៈ នគរបាលវៀចវេរ ឬអ្នកផ្លុំកញ្ចែ -កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១១-២៤ ខែសីហា ឆ្នាំ២០០៦។

[៣២] តាមកាសែ្សតវីដេអូបង្ហាញនូវវត្តមាន លោក ហេង ពៅ ក្នុងពេលធ្វើទារុណ្ឌកម្ម អ្នកស្រី ដួង សុភាព មុននឹងស្លាប់ - កាសែតមនសិការខ្មែរ ថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៧ បកប្រែនៅក្នុងកញ្ចក់សង្គម ថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៧។

[៣៣] ប្រាក់ ចាន់ថុលៈ នគរបាលដែលជាប់ចោទពីករណីឃាដកម្ម "រវល់ពេក" ពុំអាចចូលរួមសវនាការបាន។ កាសែតឌឹឃែមបូឌាដេលី ថ្ងៃទី៩ ឆ្នាំកុម្ភៈ ឆ្នាំ២០០៧។

## និទ្ទណ្ឌភាព ៖ ឧទាហរណ៍ករណីនានាចាប់តាំងពីឆ្នាំ២០០៦

| កាលបរិច្ឆេទ | ព័ត៌មានពិស្តារ | ការផ្តន្ទាទោស |
|---|---|---|
| ១៧ មិនា ២០០៦ | ក្នុងពេលចូលរួមពិធីលៀងសាយភោជអាពាហ៍ពិពាហ៍មួយនៅភ្នំពេញ មន្ត្រីនគរបាលម្នាក់ឈ្មោះ គីម វណ្ណថុន បានបាញ់កូនកម្លោះចំដើមទ្រូងបណ្តាលឱ្យរបួសយ៉ាងធ្ងន់ធ្ងរ ដោយសារតែជម្លោះអំពីទឹកជ្រលក់ ។ ស្នងការនគរបាលរាជធានី លោក ទូច ណារ័ត្ន បាននិយាយថា ជនល្មើសនឹងត្រូវបានផ្តន្ទាទោសដោយការប្រើ "វិន័យនគរបាល" ដែលពុំបានបញ្ជាក់ឱ្យបានច្បាស់លាស់ថាវិន័យណាមួយទេ ។[៣៤] | គ្មាន |
| ២៩ មិនា ២០០៦ | ប្រជាពលរដ្ឋម្នាក់ឈ្មោះ ប៉ាវ រុំ បានស្លាប់នៅក្នុងមន្ទីរឃុំឃាំងរបស់នគរបាលដោយមានរបួសលើរាងកាយ ដែលអាចសន្និដ្ឋានបានថា រងទារុណកម្ម ។ ប៉ុន្តែរបាយការណ៍របស់គណកម្មការនគរបាលបានសរសេរថា ជននោះធ្វើអត្តឃាដ ប៉ុន្តែនៅលើរាងកាយពោរពេញទៅដោយស្នាមជាំ ស្នាមដុត និងរបួសខាងក្នុងជាច្រើនកន្លែង ។[៣៥] ក្រោយមកនគរបាលបានប្រាប់លីកាដូថា មន្ត្រីនគរបាល បីនាក់ត្រូវបាន" ដាក់វិន័យរដ្ឋបាល" ដែលពុំបានបញ្ជាក់ឱ្យបានច្បាស់ថា ជាវិន័យបែបណាឡើយ ។[៣៦] | គ្មាន |
| ២៩ មិនា ២០០៦ | ពលរដ្ឋខេត្តកណ្តាលម្នាក់ឈ្មោះ ខាត់ ធឿន ស្លាប់នៅក្នុងមន្ទីរឃុំឃាំងរបស់នគរបាលដោយមានរបួសជាច្រើន ដែលអាចសន្និដ្ឋានបានថាមានការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ ។ នគរបាលអះអាងថា ការស្លាប់នោះ គឺបណ្តាលមកពីការវាយដំដោយហ្វូងមហាជន ប៉ុន្តែសាក្សីជាច្រើនបាននិយាយថា គាត់ពុំមានរបួសធ្ងន់ធ្ងរទេ មុនពេល | ជនស៊ីវិលម្នាក់ត្រូវបានចាប់ខ្លួនក្នុងរយៈពេលខ្លី នៅក្នុងករណីឃាដកម្មនេះ ក្រោយមកត្រូវបានដោះលែងវិញ ។ ពុំបានដឹងអំពីការចាត់វិធាន |

[៣៤] សាំង សឿត រឹទ្ធិ - កូនកម្លោះត្រូវបានបាញ់ ក្រោយពីភ្ញៀវបដិសេធមិនទទួលទឹកជ្រលក់- កាសែតឌឹខេមបូ ឌាលើ ថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៦ ។

[៣៥] គុជ ណារ៉ែន ៖ ការស្លាប់មនុស្ស ២ នាក់នៅក្នុងមន្ទីរឃុំឃាំងនគរបាលត្រូវស៊ើបអង្កេត -កាសែតឌឹខេមបូឌាដេលី ថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៦ ។

[៣៦] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ មិនផ្សាយជាសាធារណៈ -ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៦ ។

| | | |
|---|---|---|
| | នគរបាលចាប់គាត់ ។[៣៧] នគរបាលនិយាយថា មន្ត្រីនគរបាលម្នាក់ត្រូវបានផ្ទេរឱ្យទៅធ្វើការនៅក្នុងការិយាល័យបុគ្គលិកវិញ ។[៣៨] | ការចំពោះមន្ត្រីនគរបាលណាម្នាក់ឡើយ ។ |
| **៣ មេសា ២០០៦** | ជនសង្ស័យជាចោរប្លន់ម្នាក់ដែលមានផ្ទៃពោះ ៨ ខែ ឈ្មោះ ខឹម នីម ត្រូវបានដាក់ខ្នោះ និងវាយទាត់ធាក់ចំមុខ និងពោះ ដោយមេប៉ុស្តិ៍នគរបាលម្នាក់ ។ ជនសង្ស័យត្រូវបានផ្ទេរទៅស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ ហើយករណីនេះមិនត្រូវបានស៊ើបអង្កេតឡើយ ។[៣៩] ក្រោយមកគេបានសងជម្ងឺចិត្តឱ្យជនរងគ្រោះចំនួន ៦២៥ ដុល្លារ ហើយសុំឱ្យគាត់ដកពាក្យបណ្តឹងវិញ ។[៤០] | ករណីនេះត្រូវបានបិទបន្ទាប់ពីជនរងគ្រោះបានដកពាក្យបណ្តឹង ។ |
| **១៣ មេសា ២០០៦** | មន្ត្រីយោធាមិនស្គាល់ឈ្មោះម្នាក់បានបាញ់ស្ត្រីអ្នកចម្រៀងខារ៉ាអូខេត្រូវចំដៃ នៅក្នុងហាងការ៉ាអូខេមួយនៅភ្នំពេញ ។ ក្រោយមកស្នងការនគរបាលរាជធានីភ្នំពេញ ទូច ណារ័ត្ន បានអះអាងថា កាំភ្លើងនោះបានផ្ទុះដោយខ្លួនឯង ក្នុងខណៈដែលមន្ត្រីនគរបាលកំពុងបង្វិលលេងដោយម្រាមដៃរបស់គាត់ ហើយថា មន្ត្រីនោះនឹងត្រូវទទួល "វិន័យ" ។ គេបានសងជម្ងឺចិត្តជនរងគ្រោះចំនួន ៣.៥០០ ដុល្លារ ។[៤១] | គ្មាន |
| **១៤ មេសា ២០០៦** | ទុយ សុភ័ក្ត្រ កូនប្រុសរបស់លោករដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ បានបង្កឱ្យមនុស្សពីរនាក់របួសជាទម្ងន់នៅក្នុងព្រឹត្តិការណ៍បុក-រត់គេចខ្លួន ហើយគាត់បានបើករថយន្ត SUV ដែលជារថយន្តរបស់រដ្ឋាភិបាលបន្តពីរគីឡូម៉ែត្រទៀតមុននឹងត្រូវគាំងទៅមុខលែងរួច ដោយសារតែម៉ូតូរបស់ជនរងគ្រោះជាប់នៅខាងក្រោមរថយន្តរបស់គាត់ ។ គាត់ត្រូវបានចាប់ឃុំខ្លួន អស់រយៈពេលមួយម៉ោង ហើយត្រូវបានដោះលែងវិញ ។ ក្រោយមក គាត់បានបង់ប្រាក់ចំនួន | គ្មាន |

[៣៧] ការស្លាប់ចោរលួចកង់ត្រូវបានស៊ើបអង្កេត -នគរបាលបានបដិសេធថា គ្មានទារុណកម្ម- កាសែតឌឹខេមបូឌាដេលី ថ្ងៃទី៧ ឆ្នាំមេសា ឆ្នាំ២០០៦ ។

[៣៨] របាយការណ៍ស៊ើបអង្កេតលីកាដូ មិនផ្សព្វផ្សាយ-ថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦ ។

[៣៩] ឡោ ចាន់ដារ៉ា-នាយនគរបាលត្រូវបានផ្ទេរភារកិច្ចខណៈមានការស៊ើបអង្កេតការវាយដំ-កាសែតឌឹខេមបូឌាដេលី ថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៦ ។

[៤០] របាយការណ៍ស៊ើបអង្កេតលីកាដូ មិនផ្សព្វផ្សាយ- ឆ្នាំ២០០៦ ។

[៤១] ប្រាក់ ចាន់ថុល និង ហ្វាយណឺ ក្លាសាចជី : មន្ត្រីមិនត្រូវបានចោទប្រកាន់ទេក្នុងករណីបាញ់ក្នុងហាងការ៉ាអូខេ- កាសែតឌឹខេមបូឌាដេលី-ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ។

| | | |
|---|---|---|
| | ១.៥០០ ដុល្លារ ។[៤២] | |
| **២៣ មេសា ២០០៦** | បុរសពីរនាក់ ដែលគេស្គាល់ថាជាអង្គរក្សសម្តេចនាយរដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានគេបាញ់ស្លាប់នៅខេត្តកណ្តាល ។ នគរបាលបានអះអាងថា បុរសទាំងពីរនាក់នេះត្រូវបានសម្លាប់ដោយអង្គរក្សគ្នាឯង ដោយឈ្លោះគ្នាដណ្តើមស្ត្រីលក់ស្រាបៀរ ។ ស្នងការនគរបាលខេត្តកណ្តាល លោក គឹម រិទ្ធ បានពន្យល់ថា "បុរសទាំងនោះគឺជាទាហានកងយោធពលខេមរភូមិន្ទ ហើយដូច្នេះ មេបញ្ជាការរបស់ជនរងគ្រោះនឹងដោះស្រាយបញ្ហានេះដោយខ្លួនគាត់ផ្ទាល់ ។[៤៣] | |
| **២៦ មេសា ២០០៦** | ទាហានកងវរសេនាធំលេខ ៧០ ពីរនាក់បានបាញ់ស្ត្រីលក់ស្រាបៀរម្នាក់ នៅភ្នំពេញត្រូវចំជើងដោយសារតែយកទឹកកកមកឱ្យពួកគេយឺតពេក ។ ទាហានទាំងពីរនាក់នោះ ត្រូវបានកងកម្លាំងកងរាជអាវុធហត្ថ ចាប់ខ្លួន ប៉ុន្តែត្រូវបានដោះលែងវិញ ប៉ុន្មានម៉ោងក្រោយដោយមេបញ្ជាការរបស់ពួកគេ ។ តំណាងមេបញ្ជាការនោះនិយាយថា អង្គភាពវរសេនាធំនឹងសងជម្ងឺចិត្តជនរងគ្រោះចំនួន ៥០០ ដុល្លារ ។[៤៤] | គ្មាន |
| **១០ ឧសភា ២០០៦** | រថយន្តដឹកជញ្ជូនដែលជាកម្មសិទ្ធិរបស់កងវរសេនាធំលេខ៧០ បានបង្ករឱ្យកុមារម្នាក់អាយុ ១២ ឆ្នាំ ស្លាប់បាត់បង់ជីវិត និងបណ្តាលឱ្យកុមារអាយុ ១០ឆ្នាំម្នាក់ទៀតរងរបួសជាទម្ងន់នៅក្នុងហេតុការណ៍បុក-រត់គេចខ្លួនមួយនៅខេត្តកំពង់ស្ពឺ ។ ក្រោយមកអង្គភាពកងវរសេនាធំបានសងជម្ងឺចិត្ត ៧០០ ដុល្លារ ដល់គ្រួសារកុមារស្លាប់ និង ៣០០ ដុល្លារដល់គ្រួសារកុមារដែលរងរបួស ។ លោករដ្ឋមន្ត្រីការពារជាតិ ទា បាញ់ បាននិយាយថា អ្នកបើកបរនឹងត្រូវទទួលទណ្ឌកម្ម "តាមបញ្ជារបស់យោធា" ។[៤៥] | គ្មាន |
| **២២ មិថុនា** | មន្ត្រីកងយោធពលខេមរភូមិន្ទម្នាក់ឈ្មោះ ស៊ីវ វុឌ្ឍី បានបើក | គ្មាន |

[៤២] យុន សាមាន : មន្ត្រីនិយាយថា គាត់មិនការពារកូនប្រុសដែលបុកគេហើយរត់ទេ-កាសែតឌឺខ្មែរ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ។

[៤៣] សាំង សឿត រិទ្ធិ : មេបញ្ជាការបដិសេធអំពីការស្លាប់របស់អង្គរក្សនាយករដ្ឋមន្ត្រី -កាសែតឌឺខ្មែរដេលី ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ ។

[៤៤] សាំង សឿតរិទ្ធិ : នគរបាល : អ្នកបម្រើក្នុងហាងត្រូវបានបាញ់ដោយសារយឺត-កាសែតឌឺខ្មែរដេលី ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៦ ។

[៤៥] សាំង សឿតរិទ្ធិ :រថយន្តដឹកជញ្ជូនកងយោធពលខេមរភូមិន្ទបុកក្មេងស្លាប់ហើយបើករត់-កាសែតឌឺខ្មែរដេលី ថ្ងៃ១២ ខែឧសភា ឆ្នាំ២០០៦ ។

| | | |
|---|---|---|
| **២០០៦** | រថយន្តបុកមនុស្សមួយហ្វូង នៅពេលដែលកំពុងស្រវឹងបណ្តាលឱ្យមនុស្សបីនាក់ស្លាប់ និងប្រាំមួយនាក់ទៀតរងរបួស ។ ជនសង្ស័យត្រូវបាននាំយកទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យឯកជនមួយ ប៉ុន្តែត្រូវបានគេរាយការណ៍មកថា បានចាកចេញផុត មុនពេលនគរបាលបានទៅដល់ ។ គ្រួសាររបស់គាត់បានយល់ព្រមចេញថ្លៃព្យាបាលឱ្យអ្នកនៅរស់ទាំងប្រាំមួយនាក់ ។[៤៦] | |
| **១៩ កក្កដា ២០០៦** | វរសេនីយទោនគរបាលរាជធានីភ្នំពេញម្នាក់ឈ្មោះ ជា បូរីទ្ធបានបាញ់និស្សិតម្នាក់អាយុ ២១ ឆ្នាំ ចំនួនបីគ្រាប់ ត្រូវចំខ្នង បន្ទាប់ពីនិស្សិតនោះ បានជិះម៉ូតូបុករថយន្តរបស់គាត់ ។ ជនល្មើសត្រូវបានចាប់ខ្លួនអស់រយៈពេល ១ ថ្ងៃ ហើយក៏ត្រូវបានដោះលែងវិញដោយពុំមានការចោទប្រកាន់ទាល់តែសោះ ។ គាត់បានសងជម្ងឺចិត្តដល់និស្សិតនោះចំនួន ១.៥០០ ដុល្លារ ។[៤៧] | គ្មាន |
| **២០ កញ្ញា ២០០៦** | តុលាការខេត្តពោធិ៍សាត់ដោះលែងមនុស្សបីនាក់ ដែលត្រូវបានចាប់ខ្លួនពីបទជួញដូរឆ្អឹង និងស្បែកខ្លាត្រីខ្មៅ និងសាច់រមាំង ៥គីឡូក្រាម ។ មន្ត្រីរដ្ឋបាលព្រៃឈើបានអះអាងថា បុរសទាំងបីនាក់ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន បន្ទាប់ពីចៅក្រម "ទទួលទូរស័ព្ទយ៉ាងច្រើនដងពីសំណាក់កងការពារមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល ពីជំនួយការ និងប្រពន្ធរបស់គាត់ ។[៤៨] | ពុំបានដឹងវិធានតទៅទៀត |
| **៤ វិច្ឆិកា ២០០៦** | ទាវ សារ៉ាក់ ជាកូនប្រុសរបស់ថៅកែហាងសាំងមួយកន្លែងនៅភ្នំពេញបានបាញ់បុរស បីនាក់បណ្តាលឱ្យរងរបួសក្នុងខណៈ ដែលបុរសទាំងបីនាក់ចូលមកដល់ក្នុងហាងសាំង និងបន្ទាប់ពីមានការឈ្លោះប្រកែកគ្នា ។ សន្តិសុខហាងសាំងម្នាក់ក៏ជាប់ពាក់ព័ន្ធក្នុងអំពើបាញ់នោះដែរ ។ ក្រោយមកគេបានសងជម្ងឺចិត្តជនរងគ្រោះពី | គ្មាន |

[៤៦] ពិន ស៊ីសុវណ្ណ: នគរបាលកំពុងស្វែងរកមន្ត្រីយោធាបុកមនុស្សស្លាប់ ៣ នាក់ហើយរត់ -កាសែតឌឹខែមបូឌាដេលី ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៦ ។

[៤៧] សាំង សឿតីរិទ្ធិ : នគរបាលសងជម្ងឺចិត្តបន្ទាប់ពីបាញ់ ៣ គ្រាប់ ។ កាសែតឌឹខែមបូឌាដេលី ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៦ ។

[៤៨] គុជ ណារ៉េន និង ចន មាឡុយ: ចៅក្រមបានដោះលែងបុរសជាប់ចោទពីបទជួញដូរសត្វព្រៃឱ្យនៅក្រៅឃុំ -កាសែតឌឹខែមបូឌាដេលី ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៦ ។

| | | |
|---|---|---|
| | ១.០០០ ដល់ ១.៧០០ ដុល្លារក្នុងម្នាក់ៗ ។[៤៩] | |
| **២៩ វិច្ឆិកា ២០០៦** | នគរបាលស្រុកម្នាក់ឈ្មោះ សោម ជា បានបាញ់សកម្មជនគណបក្ស សម រង្ស៊ី ពីរនាក់ របួសធ្ងន់ធ្ងរនៅខេត្តព្រៃវែងក្នុងជម្លោះដីធ្លីមួយ ។ កូនរបស់គាត់បានយកគ្រាប់បែកទៅគំរាមជនរងគ្រោះ ។ ទោះបីជាអំពើបាញ់នោះស្ថិតនៅជិតប៉ុស្តិ៍នគរបាលព្រំដែន ក៏ជនសង្ស័យ មិនត្រូវបានចាប់ខ្លួនដែរ ។[៥០] | តុលាការបានចាប់ផ្តើមស៊ើបអង្កេត ប៉ុន្តែជនសង្ស័យបានគេចខ្លួន ។ |
| **១១-១៣ វិច្ឆិកា ២០០៦** | នគរបាល បីនាក់ រួមជាមួយនឹងកូនប្រុសរបស់អភិបាលរងស្រុក ត្រូវបានចោទប្រកាន់ថាបានរំលោភកុមារីដែលមានជម្ងឺសរសៃប្រសាទជាច្រើនដងក្នុងរយៈពេល ៣ ថ្ងៃជាប់ៗគ្នា នៅក្នុងប៉ុស្តិ៍នគរបាលឃុំមួយនៃខេត្តសៀមរាប ។ អភិបាលរងស្រុកបានសារភាពថា កូនគាត់ប្រាកដជាមានពិរុទ្ធ ហើយថាគាត់បានសងជម្ងឺចិត្ត ៥០០ ដុល្លារ ដើម្បីកុំឱ្យកាត់ទោសកូនគាត់ ។[៥១] | ៤ ខែក្រោយមក តុលាការបានចេញដីកាចាប់ខ្លួន ។ ជនសង្ស័យបានគេចខ្លួនបាត់តាំងពីយូរមកហើយ ។ |
| **៣០ ធ្នូ ២០០៦** | ប្រជាពលរដ្ឋម្នាក់ ឈ្មោះ សួ ស្តើងត្រូវបានធ្វើទារុណ្ណកម្មរហូតដល់ស្លាប់ នៅក្នុងទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកំពង់ធំ ។ នគរបាលខេត្តបានអះអាងថា អំពើទារុណ្ណកម្មនោះប្រាកដជាបានកើតឡើងមែន ប៉ុន្តែគ្រួសារជនរងគ្រោះបានដកពាក្យបណ្តឹង បន្ទាប់ពីបានទទួលសំណងជម្ងឺចិត្ត ៧៥០ ដុល្លារ ។ ក្រោយមក មន្ត្រីរាជអាវុធហត្ថប្រាំនាក់ត្រូវបានផ្ទេរមកទីបញ្ជាការកងរាជអាវុធហត្ថខេត្ត ។[៥២] | នគរបាលបានអះអាងថា បានបញ្ជូនសំណុំរឿងទៅតុលាការ ដោយបានចោទប្រកាន់ជនសង្ស័យពីរនាក់ ។ តុលាការបាននិយាយថា ជនរងគ្រោះមិនឆ្លើយតបទៅនឹងដីកាកោះដើម្បីសាកសួរ/សម្ភាសន៍ទេ ។ |
| **២៩ កុម្ភៈ ២០០៧** | បុរសបួននាក់ ក្នុងនោះម្នាក់ជាកូនប្រុសរបស់ប្រធាននាយកដ្ឋានព្រំដែនគោកនៃក្រសួងមហាផ្ទៃ ត្រូវបានចាប់ខ្លួនពីបទមនុស្សឃាត សម្លាប់មន្ត្រីកងរាជអាវុធហត្ថម្នាក់ឈ្មោះ វៃ ភ័ក្តិ ។ នៅថ្ងៃទី២ | ពុំបានដឹងការចាត់វិធានការបន្ត ។ |

[៤៩] សាំង សឿតីរិទ្ធិ: អ្នកបាញ់ត្រូវបានចាប់ខ្លួនហើយជនរងគ្រោះទទួលយកសំណងជម្ងឺចិត្ត-កាសែតឌឹខេមបូឌាដេលី ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៦ ។

[៥០] សាំង សឿតីរិទ្ធិ: ជនសង្ស័យក្នុងអំពើបាញ់សកម្មជនគណបក្សសម រង្ស៊ី នៅតែមិនច្បាស់-កាសែតឌឹខេមបូឌាដេលី ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦ ។

[៥១] ឆាយ ចាន់នីដា: នគរបាលមិនទាន់រៀបចំបណ្តឹងករណីរំលោភកុមារទេ-កាសែតឌឹខេមបូឌាដេលី ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ ។

[៥២] កាសែតប្រចាំថ្ងៃ កម្ពុជាថ្មី: ថ្ងៃទី ៧-៨ ខែមករា ឆ្នាំ២០០៧ និង គុជ ណារ៉េន : នគរបាលសារភាពថា បុរសម្នាក់ត្រូវបានធ្វើទារុណ្ណកម្ម ហើយស្លាប់នៅក្នុងមន្ទីរឃុំឃាំងរបស់នគរបាល ។ គ្រួសារសុំសំណងថែមទៀត - កាសែតឌឹខេមបូឌាដេលី ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៧ ។

| | | |
|---|---|---|
| | ខែមេសា តុលាការបានប្តូរបទចោទមកជា "សមគំនិតនៅក្នុងអំពើឃាដកម្មដោយអចេតនា" ហើយបានដោះលែងបុរសទាំងបួននាក់នោះឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ដោយពុំតម្រូវឱ្យមានការធានាអ្វីសោះ ។ | |
| **១០ មិនា ២០០៧** | គ្រូបង្រៀនសាលាឯកជនពីរនាក់បានចាប់កុមារវិសេផ្លាស្ទិកម្នាក់អាយុ ១១ ឆ្នាំ កាត់ម្រាមដៃ ៣ចោលដោយសង្ស័យថា កុមារានេះបានលួចចុងផ្លាស្ទិកមួយ ។ បុរសទាំងពីរ ត្រូវបានចាប់ហើយឃុំខ្លួនរហូតដល់ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៧ ក្រោយមកពួកគេត្រូវបានដោះលែងដោយតុលាការក្រុងភ្នំពេញ បន្ទាប់ពីបានសងជម្ងឺចិត្ត ១.០០០ ដុល្លារ ។[៥៣] | គេជឿថា តុលាការលើកលែងការចោទប្រកាន់នៅថ្ងៃទី២៥ ខែមេសាឆ្នាំ២០០៧ ។ ព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ចំពោះការលើកលែងការចោទប្រកាន់នេះ ប៉ុន្តែគ្រូទាំងពីរនាក់នោះកំពុងមានសេរីភាពរង់ចាំសាលាឧទ្ធរណ៍បើកសវនាការ ។ |
| **២៤ មិនា ២០០៧** | នគរបាលប្រហែលម្ភៃនាក់ បានបាញ់រះលើប្រជាពលរដ្ឋមួយក្រុមដែលគេចោទប្រកាន់ថាកំពុងនេសាទខុសច្បាប់ (ដោយប្រើប្រាស់ឧបករណ៍អគ្គីសនីដើម្បីឆក់ត្រី) នៅក្នុងស្រុកចន្ទ្រា ខេត្តស្វាយរៀង ។ ប្រជាពលរដ្ឋបានរត់គេច ហើយនគរបាលបានបាញ់រះពីក្រោយពួកគេ ។ បុរសម្នាក់បានស្លាប់ និងម្នាក់ទៀតរងរបួស ។ នគរបាលម្នាក់ត្រូវបានចាប់ខ្លួនអស់មួយរយៈពេលយ៉ាងខ្លីក្រោមបទចោទប្រើប្រាស់កម្លាំង ដែលមិនចាំបាច់ត្រូវប្រើ ។[៥៤] | តុលាការនៅតែកំពុងស៊ើបអង្កេតហើយពុំមានការចោទប្រកាន់ណាមួយត្រូវបានចោទចំពោះមន្ត្រីណាម្នាក់ឡើយ ។ |
| **២ មេសា ២០០៧** | មន្ត្រីនគរបាលស្រុកកំពង់សៀម ខេត្តកំពង់ចាមម្នាក់បានបាញ់អ្នកនេសាទពីរនាក់ ដែលកំពុងបង់សំណាញ់នៅក្នុងប្រឡាយមួយ ត្រូវបុរសម្នាក់ចំក្បាល ហើយស្លាប់មួយរំពេច ។ នគរបាលនោះចោទប្រកាន់អ្នកនេសាទដែលនៅរស់ថា បានប្រើប្រាស់ប្រដាប់ឆក់ត្រី ប៉ុន្តែគាត់បានបដិសេធ ហើយក៏ដើរចេញទៅ ។ នគរបាលបានសងជម្ងឺចិត្ត ៣.០០០ ដុល្លារ ទៅគ្រួសារជនរងគ្រោះ ហើយមិនត្រូវ | គ្មាន |

[៥៣] តុលាការបានដោះលែងឧក្រិដ្ឋជនដែលកាត់ម្រាមដៃកុមាររើសផ្លាស្ទិច - រស្មីកម្ពុជា ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៧ ។

[៥៤] របាយការណ៍ស៊ើបអង្កេតលីកាដូមិនផ្សព្វផ្សាយ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៧ ។

| | | |
|---|---|---|
| | បានចាប់ខ្លួន និងចោទប្រកាន់ទេ ។[៥៥] | |
| ៤ មេសា ២០០៧ | ស៊ន ប៊ុនឈឿន ប្រធានមន្ទីរសង្គមកិច្ច និងការងារខេត្តរតនគីរី បានវាយស្ត្រីលក់ស្រាបៀរក្នុងខណៈដែលគាត់ស្រវឹងនៅក្នុងបន្ទប់ការ៉ាអូខេមួយ ។ គាត់បានបដិសេធការចោទប្រកាន់ ប៉ុន្តែគាត់បានសុំទោសជនរងគ្រោះ ហើយសងជម្ងឺចិត្ត ២៥០ ដុល្លា និងចេញចំណាយថ្លៃព្យាបាលឱ្យជនរងគ្រោះទាំងអស់ ។[៥៦] | គ្មាន |
| ១៤ មេសា ២០០៧ | បុរសកាន់កាំភ្លើង បួននាក់ ត្រូវបានចាប់ខ្លួន ។ បុរសទាំងបួននាក់នោះសុទ្ធតែជានគរបាល ប៉ុន្តែមិនស្ថិតក្នុងពេលបម្រើការងារទេ ។ ពួកគេត្រូវតូវបានចាប់ខ្លួននៅខេត្តកណ្ដាលពីបទបាញ់បុរសពីរនាក់ទៀត នៅក្នុងជម្លោះមួយក្នុងខណៈដែលពួកគេកំពុងស្រវឹង ។ អធិការស្រុកក្បៀនស្វាយ ប៉ា សំអិត និយាយថា នគរបាលទាំងបួននាក់ បានសងជម្ងឺចិត្តទៅជនរងគ្រោះចំនួន ១.៥០០ ដុល្លារ ហើយត្រូវ បានដោះលែងដោយពុំមានការចោទប្រកាន់បួនថ្ងៃក្រោយមក ។ | គ្មាន |
| ២៣ មេសា ២០០៧ | មន្ត្រីជលផលបួននាក់ បានបាញ់ជនជាតិវៀតណាមបីនាក់ស្លាប់ ក្នុងនោះម្នាក់ជាស្ត្រីមានផ្ទៃពោះ នៅខេត្តពោធិ៍សាត់ ។ មន្ត្រីជលផលបានអះអាងថា ពួកគេបាញ់ដើម្បីការពារខ្លួន ប៉ុន្តែសាក្សីដែលបានឃើញនិយាយថា ពួកគេបានបាញ់ដោយពុំមានមូលហេតុអ្វីឡើយ ។[៥៧] | គ្មានការចោទប្រកាន់មន្ត្រីជលផលណាម្នាក់ឡើយ ។ ប៉ុន្តែអ្នកជិតខាងជនរងគ្រោះប្រាំនាក់ត្រូវបានចាប់ខ្លួន នឹងចោទពីបទនេសាទខុសច្បាប់ ។ |
| ៣១ ឧសភា ២០០៧ | លោក ជា សម្បត្តិ កូនប្រុសរបស់ប្រធានការិយាល័យគយខេត្តកំពតឈ្មោះ សំ សុខា បានធ្វើឱ្យអ្នកបោសសំអាតផ្លូវម្នាក់រងរបួស ដោយបុក ហើយរត់គេចជាមួយនឹងរថយន្តឡង់គ្រឹះស័ររបស់ឪពុកគាត់នៅ | គ្មាន |

[៥៥] របាយការណ៍ស៊ើបអង្កេតលីកាដូមិនផ្សព្វផ្សាយ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៧ ។

[៥៦] ថេត សម្បត្តិ៖ ស្ត្រីលក់ស្រាបៀរតនគីរីទទួលសំណងជម្ងឺចិត្ត ២៥០ដុល្លារករណីវាយដំ- កាសែត ឌឹឃែមបូឌាដេលី ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៧ ។

[៥៧] ចន មាឡូយ និង ពិន ស៊ីសុវណ្ណៈ សាក្សីបានបដិសេធការមួលបង្កាច់ថាអ្នកនេសាទបង្កឱ្យមានការបាញ់ - កាសែតឌឹឃែមបូឌាដេលី ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧ ។ ប្រាក់ ចាន់ថុល ៖ ការមួលបង្កាច់នាំឱ្យមានការចាប់ខ្លួនអ្នកជិតខាងរបស់អ្នកនេសាទ ដោយចោទពីបទនេសាទខុសច្បាប់ ។ កាសែត ឌឹឃែមបូឌាដេលី ថ្ងៃទី២៨-២៩ ខែមេសា ឆ្នាំ២០០៧ ។

| | | |
|---|---|---|
| | ភ្នំពេញ ។ ស្នងការនគរបាលរាជធានីភ្នំពេញបាននិយាយថា ជនល្មើសនឹងមិនត្រូវបានចាប់ខ្លួនទេ ដោយសារតែគ្រួសាររបស់គាត់បានយល់ព្រមចេញការចំណាយព្យាបាលសម្រាប់ជនរងគ្រោះទាំងអស់ ។[៥៨] | |
| **២៨ សីហា ២០០៧** | មន្ត្រីនគរបាលពីរនាក់បានរំលោភកុមារីម្នាក់ អាយុ ១៥ ឆ្នាំ នៅខេត្តកំពង់ធំ ។ គ្រួសារជនរងគ្រោះបានប្ដឹងមកប្រធាននគរបាលប៉ុស្ដិ៍ ហើយប្រធាននគរបាលប៉ុស្ដិ៍នោះបានបញ្ចប់បញ្ហាដោយការសងជម្ងឺចិត្តចំនួន ៧៥០.០០០ រៀលប្រមាណ ១៨៧ ដុល្លារ ។ ដោយមិនព្រមជាមួយនឹងដំណោះស្រាយ គ្រួសារជនរងគ្រោះ បានបន្តប្ដឹងមកអង្គការសិទ្ធិមនុស្សមួយ -ពីរបីសប្ដាហ៍ក្រោយអង្គការសិទ្ធិមនុស្សបានជួយនាំគ្រួសារនោះទៅប្ដឹងតទៀត ។ បីសប្ដាហ៍ក្រោយពីករណីរំលោភកើតឡើង នគរបាលឃុំ នៅតែមិនបានបញ្ចប់របាយការណ៍ស៊ើបអង្កេតរបស់របស់ខ្លួននៅឡើយ ហើយជនសង្ស័យបានរត់គេចខ្លួនបាត់អស់ ។[៥៩] | ករណីនេះត្រូវបានបញ្ជូនទៅតុលាការ ប៉ុន្តែនគរបាលទាំងពីរបានគេចខ្លួនក្នុងខណៈនោះដែរ ។ |
| **៣០ សីហា ២០០៧** | ប្រធានភូមិម្នាក់ជាសមាជិកគណបក្សប្រជាជនកម្ពុជា នៅខេត្តសៀមរាប បានវាយសកម្មជនគណបក្សសម រង្ស៊ី ក្នុងពេលឈ្លោះប្រកែកគ្នាមួយ ។ ក្រោយមកប្រធានភូមិនោះបាននិយាយថា គាត់វាយនោះ គឺដើម្បីការពារខ្លួនតែប៉ុណ្ណោះ ប៉ុន្តែគាត់ទទួលស្គាល់ថាបានសងជម្ងឺចិត្ត ៣០០ ដុល្លារ ទៅឱ្យសកម្មជននោះដើម្បីបញ្ចប់រឿង ។[៦០] | គ្មាន |
| **២២ កញ្ញា ២០០៧** | មន្ត្រីរដ្ឋបាលព្រៃឈើបានបាញ់រថយន្តមួយគ្រឿងដែលគេចោទថាដឹកឈើខុសច្បាប់ បណ្ដាលឱ្យបុរសម្នាក់ស្លាប់ នៅខេត្ត ពោធិ៍សាត់ ។ តាមសាក្សីបានឱ្យដឹងថាមន្ត្រីរដ្ឋបាលព្រៃឈើ នោះបានបាញ់រថយន្តដែលកំពុងឈប់ស្ងៀមក្រោយពីដេញយ៉ាងលឿនបង្ខំឱ្យរថយន្តនោះឈប់ ។ មន្ត្រីរដ្ឋបាលព្រៃឈើប្រាំមួយនាក់ ត្រូវបានចោទប្រកាន់ពី | ការផ្ដន្ទាទោសនៅតែបន្ត ។ ក្នុងពេលសរសេររបាយការណ៍នេះ មានតែមន្ត្រីរដ្ឋបាលព្រៃឈើម្នាក់ប៉ុណ្ណោះដែលស្ថិតនៅក្នុងការឃុំឃាំង ក្នុងចំណោមមន្ត្រី |

[៥៨] កែ គឹមសុង: កម្មកររបោសសំអាតផ្លូវរងរបួសក្នុងការបុក-រត់ដោយកូនប្រុសរបស់មន្ត្រី-កាសែតឌឹខេមបូឌាដេលី ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៧ ។

[៥៩] កោះសន្តិភាព ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៧ ។

[៦០] ថេត សម្បត្តិ: ប្រធានភូមិបង់ ៣០០ ដុល្លារ ដើម្បីបញ្ចប់ករណីវាយតប់ - កាសែតឌឹខេមបូឌាដេលី ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៧ ។

| | | |
|---|---|---|
| | បទមនុស្សឃាដនេះ ប៉ុន្តែម្នាក់ក្នុងចំណោមពួកគេ-អ្នកមាន តួនាទីធំជាងគេ មិនត្រូវបានចាប់ និងឃុំខ្លួនទេ។ ព្រះរាជអាជ្ញា ប្រាប់ថា ប្រសិនបើទាំងប្រាំនាក់មានប្រាក់គ្រប់គ្រាន់ ដើម្បីសងជម្ងឺចិត្តដល់គ្រួសារជនរងគ្រោះ នោះពួកគេនឹងត្រូវបាន ដោះលែងឱ្យនៅក្រៅឃុំ។ អ្នកទី៤ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នកាលពីថ្ងៃទី១៦ ខែតុលា បន្ទាប់ពីមានអន្តរាគមន៍ពីលោក ទី សុគន្ធ ប្រធានរដ្ឋបាលព្រៃឈើ។[៦១] | រដ្ឋបាលព្រៃឈើទាំង ប្រាំមួយនាក់ ដែលត្រូវបានចោទប្រកាន់។ |

## សវនាការសាលាឧទ្ធរណ៍ ករណី ប៊ិន សំណាង និងសុខ សំអឿន

ការវិវឌ្ឍន៍ថ្មីចំពោះករណី ប៊ិន សំណាង និងសុខ សំអឿន បុរសទាំងពីរនាក់នេះត្រូវបានគេចោទខុសទាំងស្រុងថា បានសម្លាប់ប្រធានសហជីពសេរីកម្មករ ជា វិជ្ជា ដែលជាការបញ្ជាក់ពីឆន្ទៈរបស់តុលាការក្នុងការបន្តអនុវត្តផ្ទុយនឹងគោលការណ៍វិនិច្ឆ័យដោយយុត្តិធមិ និងនីតិរដ្ឋ ដ៏ឥតលាក់លៀម ដើម្បីបន្តនូវវប្បធមិនិទ្ទណ្ឌភាពតទៅ ទៀត។

ប៊ិន សំណាង និង សុខ សំអឿនត្រូវបានផ្តន្ទាទោសដោយតុលាការក្រុងភ្នំពេញកាលពី ខែសីហា ឆ្នាំ២០០៥ ចោទប្រកាន់ពីបទសម្លាប់លោក ជា វិជ្ជា សកម្មជនសិទ្ធិការងារដ៏មានប្រជាប្រិយភាពម្នាក់ ដែលមានទំនាក់ទំនងជាមួយគណបក្ស សម រង្ស៊ី កាលពីខែមករា ឆ្នាំ២០០៤ ។ អំពើឃាដកម្ម និងការចាប់ខ្លួនបុរសទាំងពីរបានបណ្តាលឱ្យមានការជំទាស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ដោយតាមមើលទៅការចាប់ខ្លួនបុរសទាំងពីរនេះ គឺជាការប្រឌិតឡើងភ្លាមៗ ដោយ លោក ហេង ពៅ ដែលកាលនោះជាស្នងការនគរបាលរាជធានីភ្នំពេញ។ ភស្តុតាងសំខាន់ៗរួមមានចម្លើយសារភាពរបស់ ប៊ិន សំណាង ដែលត្រូវបានសាម៉ីខ្លួនបដិសេធចោលភ្លាមៗវិញនោះ បានអះអាងថា គាត់ត្រូវបាននគរបាលវាយដំឱ្យឆ្លើយសារភាព។ សាក្សីឃើញផ្ទាល់ភ្នែកជាច្រើនបានបញ្ជាក់ថា ខណៈដែលឃាដកម្មកំពុងកើតឡើងនេះ ប៊ិន សំណាង កំពុងស្នាក់នៅក្នុងខេត្តមួយផ្សេងទៀតជាមួយពួកគេ ហើយភស្តុតាងដាក់បន្ទុកលើ សុខ សំអឿន តែមួយគត់គឺ ចម្លើយសារភាពទម្លាក់កំហុសលើគាត់ ដោយប៊ិន សំណាង ដែលត្រូវបាន ប៊ិន សំណាង បដិសេធចោលវិញភ្លាមៗ។

ចៅក្រមស៊ើបអង្កេត ហ៊ីង ធីរិទ្ធ បានលើកលែងការចោទប្រកាន់ករណីនេះ ដោយសំអាងថាគ្មានភស្តុតាង

[៦១] សាំង សឿតរិទ្ធ និងហ្វេហ្កាគីន : ឈ្មួញដឹកឈើត្រូវបាញ់សម្លាញ់នៅពោធិ៍សាត់- កាសែតឌឹឃែមបូឌាដេលី ថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៧។ រស្មីកម្ពុជា ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ ។ កោះសន្តិភាព ថ្ងៃទី២០-២១ ខែតុលា ឆ្នាំ២០០៧ ។

គ្រប់គ្រាន់។ ប៉ុន្មានថ្ងៃក្រោយមក ហ៊ីង ធីរិទ្ធ ត្រូវបានដកចេញពីតុលាការក្រុងភ្នំពេញ ហើយផ្ទេរឱ្យទៅខេត្តស្ទឹងត្រែងដែលជាខេត្តមួយដាច់ស្រយាលវិញ ហើយបទចោទប្រកាន់ត្រូវបានចោទសារជាថ្មីម្តងទៀតដោយចៅក្រមសាលាឧទ្ធរណ៍ ធូ មុន្នី។[៦២] ប៊ិន សំណាង និង សុខ សំអឿនត្រូវបានរងទុក្ខវេទនានៅក្នុងពន្ធនាគាររងចាំការកាត់ក្តីអស់រយៈពេលជាងមួយឆ្នាំ ដែលជាការឃុំឃាំងលើសនីតិវិធីច្បាប់បានកំណត់ ។ ការកាត់ក្តីជាយថាហេតុរបស់ពួកគេដោយចៅក្រមតុលាការក្រុង គង់ សែត ដែលត្រូវទទួលរងការរិះគន់ពីសំណាក់សហគមន៍អន្តរជាតិនិងក្រុមសិទ្ធិមនុស្សនានា ព្រមទាំងត្រូវបានតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាចាត់ទុកថាជា "អំពើអយុត្តិធម៌យ៉ាងខ្លាំង " ដែលពុំមានអ្វីមួយអាចជឿជាក់បានទាល់តែសោះ" និង"មិនអនុវត្តតាមគោលការណ៍វិនិច្ឆ័យប្រកបដោយយុត្តិធម៌ដូចជា គោលការណ៍កំណត់ថាគ្មានទោសមុនពេលកាត់ក្តី និងភាពលំអៀងរបស់តុលាការជាដើម" ។



ប៊ិន សំណាង និងសុខ សំអឿន ត្រូវបានគេនាំចេញបន្ទាប់ពីសវនការសាលាឧទ្ធរណ៍ដែលពួកគេរង់ចាំអស់រយៈពេលជាយូរ។

បុរសទាំងពីរនាក់ត្រូវរងចាំអស់ពេល ២០ខែ ទើបដល់ពេលតុលាការមួយទៀតបើកសវនាការ ហើយក្រោយពីបានកំណត់កម្មវិធីសវនាការនៅខែតុលា ឆ្នាំ២០០៦រួចមក កម្មវិធីនោះត្រូវបានលប់ចោលវិញ នៅប៉ុន្មាននាទីចុងក្រោយ អាស្រ័យដោយចៅក្រមម្នាក់មានជម្ងឺ ។ ក្នុងពេលជាមួយគ្នានេះ ក៏បានសង្កេតឃើញការ ធ្លាក់បុណ្យសក្តិរបស់ ហេង ពៅ ដែលមកដល់ ខែមេសា ឆ្នាំ២០០៧ គាត់ត្រូវបម្រើទោសក្នុងពន្ធនាគារយ៉ាងច្រើនករណី ក្រោមការចោទប្រកាន់ពីបទឧក្រិដ្ឋនានា ដែលបានប្រព្រឹត្តកាលពីគាត់ធ្វើជាស្នងការនគរបាលរាជធានីភ្នំពេញ។ ត្រង់ចំណុចនេះ សូម្បីតែ ហេង ពៅ ខ្លួនឯង ក៏បានប្រកាសជាសាធារណៈថា បុរសទាំង ពីរនាក់ "គ្មានជាប់ពាក់ព័ន្ធក្នុងអំពើឃាដកម្មនេះបន្តិចទាល់តែសោះ "។[៦៣] ទីបំផុតសវនាការសាលាឧទ្ធរណ៍ត្រូវបានធ្វើឡើង នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៧

---

[៦២] ធូ មុនី ក្រោយមកត្រូវបានតែតាំងជាចៅក្រមនៃសាលាក្តីខ្មែរក្រហម ដែលគាត់កំពុងបម្រើបច្ចុប្បន្ន។

[៦៣] ស៊ិលវេណ ប៉ាសគីយេៈ មុខរបរស្នោកគ្រោករបស់លោក ហ៊ុន សែន-ទស្សនាវដ្តីអ៊ិចប្រេស-ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៦។ ពេលបង្ហាញខ្លួនក្នុងតុលាការចំពោះករណីមួយដែលមិនពាក់ព័ន្ធក្នុងខែកក្កដា ឆ្នាំ២០០៧- ហេង ពៅ បានបញ្ជាក់ម្តងទៀតចំពោះភាពគ្មានទោសរបស់បុរសពីរនាក់ៈ ប្រាប់តុលាការថា "ប៊ិន សំណាង និងសុខ សំអឿន ពុំមែនជាអ្នកបាញ់ទេ" ។ សូមអានអត្ថបទរបស់ប្រាក់ ចាន់ថុល និងវណ្ណ រឿន -ប្រធាននគរបាលព្រហ្មទណ្ឌបដិសេធការចោទប្រកាន់ពីបទចាប់ជម្រឹតៈ កាសែតឌឹខេមបូឌាដេលី ថ្ងៃទី២០ ខែកក្កាដា ឆ្នាំ២០០៧ ។

[៦៤] នេះជាការរំលោភមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២ ដែលបានចែងថា : សាក្សីដែលបានលើកឡើងនៅក្នុងសំណុំរឿងរបស់នគរបាលរួមទាំងមន្ត្រីនគរបាលត្រូវតែបើកសវនាការនៅក្នុងតុលាការ ។ សាក្សីអាចត្រូវបានត្រួតពិនិត្យដោយភាគីអន្តរាគមន៍ជនជាប់ចោទ ឬទីប្រឹក្សារបស់គេរៀងៗខ្លួន ឬដោយព្រះរាជអាជ្ញា។

ដោយមានចៅក្រមបីរូបចូលរួមក្នុងសវនាការនោះ។ យ៉ាងតិចក៏មានចៅក្រមពីរនាក់ដែរ ដែលមានទំនាស់ផលប្រយោជន៍នៅក្នុងករណីនេះ ដោយធ្លាប់បានពាក់ព័ន្ធនៅក្នុងករណីនេះ ជាពិសេសលោក ធូ មុន្នី ចៅក្រមដែលបានចោទប្រកាន់ ប៊ិន សំណាង និងសុខ សំអឿនឡើងវិញកាលពីឆ្នាំ២០០៤ និងលោកសិរិទ្ធ សុផល ជាចៅក្រមដែលបានបដិសេធមិនឱ្យពួកគេទាំងពីរនាក់នៅក្រៅឃុំកាលពីដើមឆ្នាំ២០០៥។ ទោះបីជាមានវត្តមានអ្នកសង្កេតការណ៍ច្រើនចូលរួមដូចជាមន្ត្រីមកពីស្ថានទូតអាមេរិក និងកាណាដា សហព្រះរាជអាជ្ញាអន្តរជាតិនៃសាលាក្តីខ្មែរក្រហម និងនាយកឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាក៏ដោយ តែសវនាការសាលាឧទ្ធរណ៍នៅតែធ្វើជាគំរូយុត្តិធម៌កម្ពុជាដ៏អាក្រក់បំផុត។

ចៅក្រមបានប្រព្រឹត្តចំពោះចុងចោទ និងសាក្សីដោះបន្ទុកក្នុងលក្ខណៈខ្វះការគួរសម និងមើលស្រាលដោយសួរនាំតាមរបៀបមួយដែលធ្វើឱ្យមានការភាន់ច្រឡំ និងប្រើសំណួរនាំមុខ ហើយជាពិសេស ដើរតួធ្វើដូចជាព្រះរាជអាជ្ញា។ ផ្ទុយទៅវិញនៅត្រង់ចំណុចដែលត្រូវសួរដេញដោលសាក្សីឡើងវិញដោយមេធាវីចុងចោទចៅក្រម ហាក់ដូចជាធ្វើព្រងើយមិនយកចិត្តទុកដាក់ស្តាប់ទាល់តែសោះ។ លោកចៅក្រម សាលី ធារ៉ា និងធូមុន្នី ទាំងពីរនាក់ បាននិយាយទូរស័ព្ទពីរបីដងនៅក្នុងដំណើរការសវនាការនេះ ហើយត្រង់ចំណុចមួយខណៈដែលសាក្សីដោះបន្ទុកឡើងបកស្រាយនូវអ្វីដែលខ្លួនបានដឹង លោកចៅក្រមជំនុំជម្រះ សាលី ធារ៉ា បានដើរចេញពីបន្ទប់សវនាការអស់រយៈពេលពីរបីនាទី ដោយពុំមានការពន្យល់អំពីមូលហេតុបន្តិចទាល់តែសោះ ហើយដូច្នេះការបកស្រាយរបស់សាក្សីត្រូវបានធ្វើឡើងដោយពុំមានវត្តមានរបស់គាត់។

នៅពេលបិទសវនាការ ព្រះរាជអាជ្ញាលោក ប៉ាន់ គឹមលាន បានធ្វើសេចក្តីថ្លែងការណ៍ដ៏គួរឱ្យកត់សំគាល់ដោយទទួលស្គាល់ថាការស៊ើបអង្កេតរបស់នគរបាលក្នុងករណីនេះនៅមានការខ្វះចន្លោះ ហើយអំពាវនាវឱ្យមានការស៊ើបអង្កេតសារជាថ្មីឡើងវិញ ដើម្បីរក "ឃាដករពិត"។ ការទទួលស្គាល់ដោយព្រះរាជអាជ្ញនូវការបរាជ័យក្នុងការរកភស្តុតាង ដើម្បីបញ្ជាក់ករណីរបស់ខ្លួនបន្ទាប់ពីការស៊ើបអង្កេតអស់រយៈពេល ៣ឆ្នាំ នោះជាមូលដ្ឋានច្បាប់យ៉ាងច្បាស់ដែលអាចលើកលែងការចោទប្រកាន់ចំពោះជនទាំងពីរជាបន្ទាន់។ ហើយទីបំផុត សវនាការនោះត្រូវបានពន្យាពេល ៦ថ្ងៃទៀត។

នៅថ្ងៃទី១២ ខែមេសា ជាថ្ងៃចេញសាលដីកាចុងក្រោយ តុលាការត្រូវបានបើកមុនម៉ោង ៧.៣០នាទីព្រឹក ដែលជាម៉ោងកំណត់ ហើយបញ្ចប់នៅម៉ោង ៧.៤០ នាទី។ ទាំងជនរងគ្រោះ និងមេធាវីរបស់ពួកគេពុំមានវត្តមាននៅក្នុងពេលប្រកាសសាលដីកានោះទេ។ ទោះបីជាព្រះរាជអាជ្ញាទទួលស្គាល់ថា ពុំមានភស្តុតាមគ្រប់គ្រាន់ក៏ដោយ សាលដីការមានទោស នៅតែត្រូវបានតម្កល់ទុកដដែល។ ដូចដែលតុលាការក្រុងបានធ្វើកាលពីលើកមុនសាលាឧទ្ធរណ៍បានបដិសេធការបកស្រាយផ្ទុយរបស់សាក្សីដោះបន្ទុកជាច្រើននៅក្នុងតុលាការ ហើយបែរជាទទួលយក របាយការណ៍

សាក្សីដាក់បន្ទុកដែលបានសរសេរ ហើយមិនដែលមានមុខនៅក្នុងតុលាការទាល់តែសោះ ដែលជាការរំលោភច្បាប់កម្ពុជាមួយចំណុចទៀត[៦៤] ហើយបដិសេធមិនព្រមពិចារណាអំពីរបាយការណ៍សាក្សីដោះបន្ទុក ដែលជាសាក្សីឃើញផ្ទាល់ភ្នែកតែម្នាក់គត់ ដែលបានសរសេរថា បុរសពីរនាក់នេះពុំមែនជាឃាតករទេ។

មកដល់ខែវិច្ឆិកា ឆ្នាំ២០០៧នេះ ប៊ិន សំណាង និងសុខ សំអឿន នៅតែត្រូវជាប់ទោសក្នុងពន្ធនាគាររយៈពេល២០ឆ្នាំ ដដែលចំពោះបទឧក្រិដ្ឋដែលពួកគេពុំបានប្រព្រឹត្ត ហើយខណៈឃាតករសម្លាប់ជាវិជ្ជាពិតប្រាកដកំពុងតែបន្តទទួលនិទ្ទណ្ឌភាព។

□□□

# ៥_ តុលាការ និងផលប្រយោជន៍សេដ្ឋកិច្ច

តុលាការកំពុងតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារផលប្រយោជន៍សេដ្ឋកិច្ចរបស់អ្នកមានទ្រព្យ និងមានអំណាច ជាពិសេសពាក់ព័ន្ធជាមួយនឹងបញ្ហាដីធ្លី និងធនធានធម្មជាតិ។

ទោះបីជាមានការសន្យាយ៉ាងច្រើនដោយសម្តេច ហ៊ុន សែន ដើម្បីដោះលែងពលរដ្ឋទាំងឡាយដែលត្រូវបានឃុំខ្លួនក្នុងករណីជម្លោះដីធ្លីក៏ដោយ[៦៥] ការសន្យាប្រគល់ដីឱ្យជនក្រីក្រវិញ[៦៦] និងចាត់វិធានការចំពោះជនល្មើសក្នុងករណីដីធ្លី[៦៧]ក៏ដោយ ក៏តុលាការនៅតែចោទប្រកាន់ ឃុំខ្លួន និងផ្តន្ទាទោសប្រជាពលរដ្ឋចំពោះបទល្មើសដែលពាក់ព័ន្ធជាមួយបញ្ហាជម្លោះដីធ្លីជារឿយៗ គឺនៅពេលដែលបញ្ហាម្ចាស់កម្មសិទ្ធិដីមិនទាន់ត្រូវបានសម្រេចតាមច្បាប់នៅឡើយ។ ការបំភិតបំភ័យស្រដៀងគ្នានេះ គឺការប្រព្រឹត្តិរបស់តុលាការមកលើប្រជាពលរដ្ឋដែលពាក់ព័ន្ធនៅក្នុងជម្លោះធនធានធម្មជាតិ។ មានឧទាហរណ៍ជាច្រើនផ្សេងទៀតដែលពាក់ព័ន្ធនឹងបញ្ហានេះ ដូចជា :

ខែមិនា ឆ្នាំ២០០៦ សកម្មជនសហគមន៍ចំនួនប្រាំបួននាក់ ត្រូវបានឃុំខ្លួន ក្រោយពីបានធ្វើការតវ៉ាប្រឆាំងនឹងការរំលោភយកដីធ្លីដោយខុសច្បាប់មួយនៅប៉ៃលិន[៦៨] ហើយតំណាងសហគមន៍ម្នាក់ទៀត ត្រូវបានឃុំឃាំងនៅបន្ទាយមានជ័យ បន្ទាប់ពីគាត់បានដើរតួជាតំណាងប្រជាពលរដ្ឋ ១២៨ គ្រួសារ នៅក្នុងបញ្ហាទំនាស់ដីធ្លីមួយ ជាមួយនឹងមន្ត្រីយោធា។[៦៩]

ខែឧសភា ឆ្នាំ២០០៦ តំណាងសហគមន៍នៅខេត្តសៀមរាបម្នាក់ត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិបន្ទាប់ពីការតវ៉ាដោយសន្តិវិធីប្រឆាំងនឹងការរំលោភយកដីធ្លី ដែលត្រូវបានវាយបំបែកដោយនគរបាលពោរពេញដោយអំពើហិង្សា។ ភាគីម្ខាងក្នុងបញ្ហាទំនាស់ដីធ្លីនោះគឺជាព្រះសង្ឃមួយអង្គ ដែលគាំទ្រពីក្រោយដោយ

---

[៦៥] ពិន ស៊ីសុវណ្ណ:-គីម សុខា: នាយករដ្ឋមន្ត្រីនិយាយថាដោះលែងអ្នកទោសដែលជាប់ពន្ធនាគារដោយសារបញ្ហាដីធ្លី-កាសែតឌឹឃែមបូឌាដេលី ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៦។

[៦៦] ពិន ស៊ីសុវណ្ណ និងវ៉ាយណើ ក្វាសាចជឺ: នាយករដ្ឋមន្ត្រីសន្យាជាថ្មីម្តងទៀតថានឹងប្រគល់ដីឱ្យជនក្រីក្រវិញ-កាសែត ឌឹឃែមបូឌាដេលី ថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០៦។

[៦៧] កៃ គឹមសុង: នាយករដ្ឋមន្ត្រីស្តីបន្ទោសអំពីបញ្ហាការរំលោភដីធ្លី និងមន្ត្រីសមគំនិត- កាសែតឌឹឃែមឌាដេលី ថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៧។

[៦៨] របាយការណ៍ស៊ើបអង្កេតលីកាដូដែលមិនផ្សព្វផ្សាយ-ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៦។

[៦៩] របាយការណ៍ស៊ើបអង្កេតលីកាដូដែលមិនផ្សព្វផ្សាយ-ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៦ ។ សូមអានអត្ថបទដោយ ពិន ស៊ីសុវណ្ណ-ពិរុទ្ធជនពាក់ព័ន្ធ ករណីដីធ្លីបីនាក់ទៀត ត្រូវបានដោះលែង-កាសែតឌឹឃែមបូឌាដេលី ថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០៦។

សម្ដេចព្រះសង្ឃរាជ ទេព វង្ស ។[៧០] ក្នុងសវនាការកាលពីខែតុលា ឆ្នាំ២០០៧ តំណាងសហគមន៍ឈ្មោះ សូ សុជាតិ ត្រូវបានផ្ដន្ទាទោសពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងបង្ករបួសស្នាមទៅលើកងកម្លាំងនគរបាល ហើយត្រូវជាប់ពន្ធនាគាររយៈពេល ៨ ខែ។ ការចោទប្រកាន់នោះពុំមានភស្ដុតាងណាមួយបង្ហាញឱ្យឃើញទេ-តាមពិតនគរបាលដែលមានបញ្ហានោះ បានប្រាប់តុលាការថា នាងសុជាតិ ពុំមែនជាអ្នកបង្ករបួសស្នាមលើរូបរាងកាយគាត់ និងបំផ្លាញទ្រព្យសម្បត្តិគាត់ទេ។ ប៉ុន្ដែ ចៅក្រមនិយាយថា ពីព្រោះនាងជា" អ្នកដឹកនាំ"ការតវ៉ា ដូច្នេះ សុជាតិត្រូវតែទទួលខុសត្រូវចំពោះការចោទប្រកាន់ដែលអ្នកដទៃបានប្រព្រឹត្ត ។

ខែមិថុនា ឆ្នាំ២០០៦ តំណាងភូមិបីនាក់នៅប៉ោយប៉ែតត្រូវបានចោទប្រកាន់ពីបទញុះញង់បន្ទាប់ពីការតវ៉ាប្រឆាំងនឹងការរំលោភយកដីធ្លីដោយមេភូមិ។[៧១]

ខែសីហា ឆ្នាំ២០០៦ តំណាងសហគមន៍ម្នាក់នៅខេត្ត កំពង់ចាមត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ហើយត្រូវបានឃុំខ្លួនក្រោយពីបានតវ៉ាប្រឆាំងនឹងការកាប់ឆ្ការព្រៃនៅលើដីទំនាស់ដោយក្រុមហ៊ុនចម្ការកៅស៊ូ។[៧២] តំណាងសហគមន៍ម្នាក់នៅខេត្តកណ្ដាលត្រូវបានចោទប្រកាន់ពីបទរំលោភកម្មសិទ្ធិឯកជន ហើយត្រូវបានឃុំខ្លួនបន្ទាប់ពីបានតវ៉ាប្រឆាំងជាមួយក្រុមហ៊ុនដែលបានធ្វើរបងព័ទ្ធជុំវិញដីទំនាស់[៧៣] ហើយសកម្មជន ៤ នាក់ទៀត ត្រូវបានចោទប្រកាន់ពីបទរំលោភលើទ្រព្យសម្បត្តិឯកជន ហើយត្រូវបានឃុំខ្លួនក្រោយពីការបណ្ដេញចេញដោយប្រើអំពើហិង្សាពីលើដីទំនាស់ដោយមន្ត្រីយោធា។[៧៤]

ខែកញ្ញា ឆ្នាំ២០០៦ តំណាងសហគមន៍ម្នាក់នៅខេត្តរតនគីរីត្រូវបានចាប់ខ្លួន ហើយឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងពន្ធនាគារ ក្រោមការចោទប្រកាន់ពីបទលួចលក់ដីដែលជាកម្មសិទ្ធិរបស់គណបក្សប្រជាជនកម្ពុជា ទោះបីជាការសម្រេចអំពីកម្មសិទ្ធិដីមានទំនាស់កំពុងតែស្ថិតនៅក្នុងបណ្ដឹងឧទ្ធរណ៍ក៏ដោយ។[៧៥]

ខែវិច្ឆិកា ឆ្នាំ២០០៦ អតីតអ្នកភូមិ ១៤ សង្កាត់ទន្លេបាសាក់បីនាក់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ ក្រោមការចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។ ការផ្ដន្ទាទោសនោះ គឺផ្អែកលើសាក្សីដាក់

---

[៧០] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូដែលមិនផ្សព្វផ្សាយថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ - សូមអាចអត្ថបទដោយ គុជ ណារ៉ែន-ស្ត្រីម្នាក់ ត្រូវចាប់ខ្លួនចោទប្រកាន់ពីបទញុះញង់ឱ្យមានអំពើហិង្សានៅក្នុងវត្ត។ កាសែតឌឺឃែមបូឌា ដេលី ថ្ងៃទី៨ ខែមិនា ឆ្នាំ២០០៦។

[៧១] របាយការណ៍ស៊ើបអង្កេតលីកាដូមិនផ្សព្វផ្សាយជាសាធារណៈ- ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៦។

[៧២] របាយការណ៍ស៊ើបអង្កេតលីកាដូមិនផ្សព្វផ្សាយជាសាធារណៈ- ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៦។ សូមអានអត្ថបទដោយ ប្រាក់ ចាន់ថុល-អ្នកភូមិអំពាវនាវឱ្យដោះលែងតំណាងរបស់ខ្លួន- កាសែតឌឺឃែមបូឌាដេលី ថ្ងៃទី៥-៦ ខែសីហា ឆ្នាំ២០០៦ និងអត្ថបទបន្តបន្ទាប់មកទៀត។

[៧៣] របាយការណ៍ស៊ើបអង្កេតលីកាដូមិនផ្សព្វផ្សាយ- ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៦។

[៧៤] របាយការណ៍ស៊ើបអង្កេតលីកាដូមិនផ្សព្វផ្សាយ- ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៦។

[៧៥] សម្ភាសន៍ជាមួយក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា។ សូមអានអត្ថបទដោយ គុជ ណារ៉ែន - អ្នកភូមិ រតនគីរីត្រូវបានចោទពីបទ លក់ដីខុសច្បាប់ - កាសែតឌឺឃែមបូឌាដេលី ថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៦ ។

បន្ទុកម្នាក់តែប៉ុណ្ណោះ ដែលពុំហ៊ានចូលមកបំភ្លឺក្នុងតុលាការផង។ សាក្សីដោះបន្ទុកបួននាក់ មិនត្រូវបានកោះអញ្ជើញឱ្យមកចូលរួមបំភ្លឺក្នុងសវនាការទេ ។[៧៦]

ខែធ្នូ ឆ្នាំ២០០៦ អ្នកភូមិដប់ពីរនាក់នៅខេត្តកំពតត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររវាងពី ៦ ឆ្នាំ ទៅ ៨ ឆ្នាំម្នាក់ៗក្រោមការចោទប្រកាន់ពីបទត្រួសត្រាយព្រៃ និងរំលោភយកដីរដ្ឋ ។ មេធាវីរបស់ពួកគេបានអះអាងថា កូនក្តីរបស់គាត់បានទិញដីនោះដោយស្របច្បាប់នៅឆ្នាំ១៩៩៨ ហើយមិនបានជាប់ពាក់ព័ន្ធនៅក្នុងការត្រួសត្រាយព្រៃនោះទេ។[៧៧]

ខែធ្នូ ឆ្នាំ២០០៦ នោះដែរ កម្មករជ្រើសរើសជ័រកៅស៊ូប្រាំមួយនាក់នៅខេត្តរតនគីរីត្រូវបានចោទប្រកាន់ពីបទចោរកម្ម ហើយពីរនាក់ត្រូវបានចាប់ខ្លួនខណៈដែលគាត់បម្រុងលក់ជ័រកៅស៊ូតាមតម្លៃទីផ្សារដោយពុំព្រមលក់ឱ្យក្រុមហ៊ុនក្នុងតម្លៃមួយទាបជាងទីផ្សារដែលកំណត់ដោយប្រធានចម្ការកៅស៊ូ។[៧៨]

ខែមិនា ឆ្នាំ២០០៧ អ្នកភូមិបួននាក់ដែលពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយមន្ត្រីមូលដ្ឋានម្នាក់នៅខេត្តព្រៃវែងត្រូវបានកោះឱ្យចូលខ្លួននៅតុលាការខេត្ត ដើម្បីធ្វើការសាកសួរអំពីបញ្ហាប្រឈមមុខដាក់គ្នាកាលពីខែធ្នូ ជាមួយនឹងកម្លាំងនគរបាល ដែលកាលនោះនគរបាលបានបាញ់យុវជនអាយុ ១៧ ឆ្នាំ ម្នាក់ស្លាប់។ នគរបាលដែលបាញ់គេស្លាប់នោះមិនត្រូវបានតុលាការកោះហៅទេ។[៧៩]


អ្នកភូមិដប់បីនាក់ត្រូវគេនាំចូលទៅក្នុងតុលាការក្រុងព្រះសីហនុ។

ខែមេសា ឆ្នាំ២០០៧ អ្នកភូមិដប់បីនាក់ត្រូវបានចាប់ និង ឃុំខ្លួនក្រោមការចោទប្រកាន់ពីបទវាយដំបណ្តាលឱ្យមានរបួសស្នាមលើកម្លាំងនគរបាល ព្រមទាំងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់នគរបាល ក្រោយពីការបណ្តេញចេញពោរពេញដោយហិង្សាពីលើដីទំនាស់ ដោយកងកម្លាំងនគរបាលរាប់រយនាក់នៅក្រុងព្រះសីហនុ។[៨០] ក្នុងសវនាការ ៣ ខែ ក្រោយពីការចាប់ខ្លួនអ្នកភូមិ៥នាក់ ត្រូវបានដោះលែង ហើយប្រាំបីនាក់ផ្សេងទៀតត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររវាងពី ៧៥ ថ្ងៃ និង ៨ ខែ។ មនុស្សប្រាំបីនាក់ ដែលត្រូវបានផ្តន្ទាទោសនោះ

---

[៧៦] ប្រាក់ ចាន់ថុល និង ពិន ស៊ីសុវណ្ណៈ បុរស ៣ នាក់ត្រូវបានផ្តន្ទាទោសចោទពីបទញុះញង់ឱ្យមានកុប្បកម្ម នៅសង្កាត់ទន្លេបាសាក់។

[៧៧] ពិន ស៊ី សុវណ្ណៈ តុលាការកាត់ទោសអ្នកភូមិចំពោះការទាមទារយកដីរដ្ឋ - កាសែតឌឺខេមបូឌាដេលី ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៦។

[៧៨] គុជ ណាវែនៈ ចម្ការកៅស៊ូ និង មន្ត្រីមូលដ្ឋានឃប់ឃិតគ្នាជំទាស់កម្មករៈ អាដហុក-កាសែតឌឺខេមបូជាដេលី ថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៧។

[៧៩] ប្រាក់ ចាន់ថុល : អ្នកភូមិបួននាក់ត្រូវបានកោះហៅនៅក្នុងករណីរំលោភដីធ្លី- កាសែតឌឺខេមបូឌា ថ្ងៃទី៦ ខែមិនា ឆ្នាំ២០០៦ ។

[៨០] សាំង សឿតរិទ្ធ និង ជែម វែលៈ គ្រួសារពិរុទ្ធជនអះអាងជាការពារខ្លួនទល់នឹងនគរបាល-កាសែតឌឺខេមបូឌាដេលី ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧ ។

តាមពិតមន្ត្រីនគរបាលដែលឡើងធ្វើការបំភ្លឺ ដើម្បីផ្តន្ទាទោសពុំបានបញ្ជាក់ថា អ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងប្រាំបីនោះ បានប្រព្រឹត្តអំពើហិង្សាមកលើ ឬបំផ្លាញទ្រព្យសម្បត្តិរបស់ពួកគេទេ ។

ខែកក្កដា ឆ្នាំ២០០៧ តុលាការខេត្តកំពង់ឆ្នាំងបានផ្តន្ទាទោសពលរដ្ឋ បីនាក់ ដោយចោទពីបទរំលោភលើកម្មសិទ្ធិឯកជនដោយប្រើអំពីហិង្សា។ នៅក្នុងសវនាការតុលាការពុំមានភស្តុតាងណាមួយបង្ហាញថា ពលរដ្ឋទាំង៣បីនាក់នោះបានប្រើអំពើហិង្សាឡើយ។ ពលរដ្ឋទាំង បីនាក់ ម្នាក់ៗត្រូវបានកាត់ព្យួរទោស ៦ ខែ និង ពិន័យជាប្រាក់ ១.៥០០.០០០រៀល ហើយបានបាត់បង់ដីស្រែរបស់ខ្លួនដោយសារសាលក្រមតុលាការ។ តាមពិតប្រជា ពលរដ្ឋទាំង ៣នាក់នោះបានបង្កបង្កើនផលនៅលើដីដែលមានទំនាស់តាំងពីទសវត្សឆ្នាំ១៩៨០មក ហើយមានប័ណ្ណកម្មសិទ្ធិតាំងពីឆ្នាំ១៩៩៣ មានន័យថាពួកគាត់មានកម្មសិទ្ធិត្រឹមត្រូវតាមច្បាប់ដីធ្លីឆ្នាំ២០០១ ប៉ុន្តែតុលាការពុំបានពិចារណាចំណុចទាំងនេះឡើយ ។ អ្នកប្តឹងទាមទារដីនោះគឺជាមន្ត្រីស្រុកម្នាក់ដែលទើបតែធ្វើប័ណ្ណកម្មសិទ្ធិក្នុងឆ្នាំ២០០៥ ។ [៨១]

ហើយទោះបីជាមានការសន្យាថា នឹងដោះលែងពលរដ្ឋដែលត្រូវបានឃុំខ្លួនដោយករណីបែបនេះក៏ដោយ យ៉ាងហោចណាស់នៅមានពលរដ្ឋម្តៃពីរនាក់ទៀត កំពុងស្ថិតក្រោមការឃុំឃាំងនៅឡើយ ដោយពាក់ព័ន្ធនឹងបញ្ហាទំនាស់ដីធ្លីនេះ ហើយតុលាការបានចេញដីកាចាប់ខ្លួនម្ភៃបីនាក់ទៀត ដើម្បីតាមចាប់ប្រជាពលរដ្ឋដោយគិតត្រឹមពាក់កណ្តាល ឆ្នាំ២០០៧ នេះ។ [៨២]

---

[៨១] *ពលរដ្ឋកម្ពុជាបីនាក់ត្រូវបានផ្តន្ទាទោសក្រោយពីត្រូវបានរងគ្រោះពីការរំលោភយកដីធ្លី*- លីកាដូ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧។ សូមមើលវែបសាយ: http://www.licadho.org/articles/20070727/61/index.html

[៨២] របាយការណ៍ស៊ើបអង្កេតលីកាដូមិនផ្សព្វផ្សាយ- ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧។

# ជម្លោះដីធ្លីនៅតំបន់បឹងប្រាំ

ជម្លោះដីធ្លីដែលអូសបន្លាយដ៏យូរអង្វែងមួយនៅខេត្តបាត់ដំបងជាករណីមួយបែបដែលបញ្ជាក់អំពីវិធីសាស្ត្រដោះស្រាយបញ្ហារបស់តុលាការកម្ពុជាចំពោះករណីពាក់ព័ន្ធផលប្រយោជន៍សេដ្ឋកិច្ចរបស់អ្នកមានទ្រព្យ និងអំណាច។

ករណីនេះកើតឡើងនៅក្នុងភូមិបឹងប្រាំ ឃុំអំពិលប្រាំដើម ស្រុកបវិល ខេត្តបាត់ដំបង ដែលគ្រួសារប្រជាពលរដ្ឋជាអតីតទាហានគ្មានដីធ្លីបានចូលមករស់នៅ ដែលគេជឿជាក់ថាជាដីព្រៃរបស់រដ្ឋនៅទំនេរ។ ប៉ុន្តែមានឈ្មួញម្នាក់បានអះអាងថាគាត់បានទិញដីនោះពីឈ្មោះ ដេង យ៉ាន មេបញ្ជាការរងយោធាកងវរសេនាធំលេខ ៥៣ ឈរជើងនៅតំបន់នោះ។ នៅពេលដែល ដេង យ៉ាន លក់ដីនោះ គ្រួសារប្រជាពលរដ្ឋដែលរស់នៅបានជំទាស់ដោយពួកគាត់បានស្នើសុំឱ្យរដ្ឋាភិបាលផ្តល់ដីនោះឱ្យពួកគាត់តាមរូបភាពជាដីសម្បទានសង្គមកិច្ច ។



ការប្រមូលផ្តុំជាសាធារណៈមួយនៅខាងក្រៅពន្ធនាគារខេត្តបាត់ដំបង ដើម្បីអំពាវនាវឱ្យមានការដោះលែងសកម្មជនរឿងដីធ្លីនៅឆ្នាំ២០០៦

បន្ទាប់ពីមានបណ្តឹងដែលប្តឹងដោយឈ្មួញដែលបច្ចុប្បន្នអះអាងថាជាម្ចាស់ដីនោះ តំណាងសហគមន៍ឈ្មោះ ជា នី ត្រូវចាប់ខ្លួនកាលពីឆ្នាំ២០០៦ ហើយបញ្ជូនទៅពន្ធនាគារខេត្តបាត់ដំបង ហើយនៅខែកញ្ញាប្រជាពលរដ្ឋពីរនាក់ទៀតឈ្មោះ ហែម ឡាក់ និងមូ សាប់ ក៏ត្រូវបានចាប់ ហើយបញ្ជូនទៅពន្ធនាគារជាមួយ ជា នី ដែរ។ សកម្មជនពីរនាក់ទៀត រស់ សារឿន និងអឿន ម៉ៅ បានរត់គេចខ្លួនហើយមិនត្រូវបានចាប់ខ្លួនទេ ។ សកម្មជនទាំងប្រាំនាក់ត្រូវបានចោទប្រកាន់ពីបទរំលោភលើកម្មសិទ្ធិឯកជនតាមមាត្រា ២៥៣ នៃច្បាប់ដីធ្លីឆ្នាំ២០០១ ដែលចែងពីការផ្តន្ទាទោស ដាក់ពន្ធនាគារហូតដល់ ២ ឆ្នាំ និងពិន័យជាប្រាក់រហូតដល់ ២៥ លានរៀល។ ប៉ុន្តែ មាត្រានេះ អនុវត្តទៅលើករណីណាដែលមានការប្រើប្រាស់អំពើហិង្សាតែប៉ុណ្ណោះ ដូច្នេះពុំអាចប្រើចំពោះករណី ជា នី បានឡើយ។ ហេតុនេះ ករណី ជា នី អាចពាក់ព័ន្ធជាមួយ "មាត្រា ២៤៨" នៃច្បាប់ដីធ្លី ជាមាត្រាទូទៅដែលអនុវត្តចំពោះការកាន់កាប់ដីធ្លីខុសច្បាប់ដោយពុំប្រើហិង្សាហើយពុំមានការផ្តន្ទាទោសទេ ។ ពុំមានមូលដ្ឋានច្បាប់ចំពោះការពាក់ព័ន្ធបែបនេះឡើយ ហើយល្បិចបែបនេះត្រូវបានប្រើប្រាស់នៅក្នុងករណីផ្តន្ទាទោសខុសច្បាប់ជាច្រើនមកលើសកម្មជនទាមទារសិទ្ធិដីធ្លី ។

ជា នី ត្រូវបានចោទប្រកាន់ពីបទរំលោភសិទ្ធិឯកជនថែមទៀតតាមមាត្រា ៥៧ នៃក្រមព្រហ្មទណ្ឌអន្តរកាល។ មាត្រានេះគ្របដណ្តប់ទៅលើតែ "ភ្នាក់ងារសាធារណៈ រួមមាន ភ្នាក់ងារនគរបាល យោធា ដែលរំលោភលើសិទ្ធិអធិបតេយ្យភាពរាងកាយដោយកម្រោល និងរំលោភលើលំនៅដ្ឋានដែលមិនគួរប្រព្រឹត្ត "ហើយផ្តន្ទាទោសដាក់ពន្ធនាគារ

របហូតដល់ ២ឆ្នាំ ។ នីត្រូវបានចោទប្រកាន់ជាអតីតយោធា ដែលធ្លាប់មានឈ្មោះនៅក្នុងបញ្ជីកងទ័ពចាស់ លែងប្រើប្រាស់ទៅហើយ។ ដូច្នេះការចោទនេះជាការផ្ទុយទៅវិញដោយច្បាប់មួយសំរាប់ផ្តន្ទាទោសនិទណ្ឌភាព ដែលប្រព្រឹត្តដោយភ្នាក់ងាររដ្ឋ បែរជាយកមកកាត់ទោសសកម្មជនដែលត្រូវគំរាមដោយមន្ត្រីមានអំណាចទៅវិញ។ នៅថ្ងៃទី១៣ ខែវិច្ឆិកា សាលាឧទ្ធរណ៍បានបើកសវនាការជំនុំជំរះបណ្តឹងឧទ្ធរណ៍ករណី ជា នី ដែលប្តឹងស្នើសុំនៅក្រៅឃុំ។ នៅក្នុងការសម្រេចចិត្តដ៏គ្មានន័យទាល់តែសោះ តុលាការបានលើកឡើងថា គាត់គួរត្រូវបានដោះលែងនៅមុនសវនាការចំពោះការចោទប្រកាន់អំពីបទរំលោភសិទ្ធិបុគ្គល ប៉ុន្តែមិនអាចដោះលែងបានចំពោះករណីរំលោភកម្មសិទ្ធិបុគ្គលទេ ។

នៅក្នុងសវនាការកាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ តុលាការបានផ្តន្ទាទោសអ្នកភូមិទាំងប្រាំនាក់ពីបទរំលោភកម្មសិទ្ធិឯកជនអ្នកដទៃ ដោយប្រើប្រាស់អំពើហិង្សា ទោះបីជាគ្មានភស្តុតាងបង្ហាញនៅក្នុងសវនាការថាចុងចោទបានរំលោភដោយហិង្សាលើកម្មសិទ្ធិឯកជនក៏ដោយ។ ពេលនោះ ជា នី ពុំមានវត្តមាននៅក្នុងសវនាការទេដោយគាត់ត្រូវបានផ្ទេរមកពន្ធនាគារភ្នំពេញ ហើយមេធាវីរបស់គាត់បានស្នើជាច្រើនដងឱ្យបញ្ជូនគាត់មកបាត់ដំបងវិញដើម្បីចូលរួមក្នុងសវនាការ ប៉ុន្តែតុលាការបានព្រងើយកន្តើយចំពោះសំណើនោះ ។ នៅក្នុងសវនាការ ទាំងដើមបណ្តឹង និងសាក្សីដាក់បន្ទុកពុំមាននរណាម្នាក់ឡើងបំភ្លឺទេដោយតុលាការប៉ុនប៉ងទប់ស្កាត់កុំឱ្យមេធាវីចុងចោទសួរមនុស្សទាំងនោះ។

ទោះបីជាពុំមានភស្តុតាងគ្រប់គ្រាន់ ក៏ចៅក្រមជំនុំជំរះលោក ពេជ្រ ធឿត កាត់ទោស ជា នី ឱ្យជាប់ពន្ធនាគារមួយឆ្នាំ និងបញ្ជាឱ្យសងជម្ងឺចិត្ត ៤០០ ដុល្លាទៅដើមបណ្តឹង ។ ចំណែកឯ រស់ សារឿន និងអឿន ម៉ៅ ដែលនៅមានសេរីភាពនៅឡើយ ក៏ទទួលការផ្តន្ទាទោសដូចគ្នាដែរ។ ចុងចោទពីរនាក់ចុងក្រោយលោក ហែម ឡាក់ និងលោក មូ សាប់ អាយុ ៧៨ ឆ្នាំ ដែលបានចូលរួមក្នុងសវនាការត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៦ ខែ។

ការពិតកម្មសិទ្ធិដីធ្លីដែលមានជម្លោះមិនត្រូវបានដោះស្រាយដោយសវនាការតុលាការទេ។ មេធាវីដើមចោទបានទទួលស្គាល់ថា កូនក្តីរបស់គាត់ពុំមានប័ណ្ណកម្មសិទ្ធិលើដីដែលមានទំនាស់នោះទេ ហើយនៅក្នុងសាលក្រមរបស់គាត់ ចៅក្រមជំនុំជម្រះបានណែនាំឱ្យដើមចោទដាក់ពាក្យទៅគណកម្មាធិការសុរិយោដីដើម្បីស្នើសុំប័ណ្ណកម្មសិទ្ធិ។ ទោះបីជាមានការទទួលស្គាល់ថាបច្ចុប្បន្នដើមចោទពុំមានប័ណ្ណកម្មសិទ្ធិផ្លូវការក៏ដោយ តែចុងចោទនៅតែត្រូវផ្តន្ទាទោសពីបទរំលោភលើកម្មសិទ្ធិឯកជនដដែល។

បញ្ហាដែល ជា នី មិនបានចូលរួមក្នុងសវានការនោះ គាត់អាចមានសិទ្ធិសុំឱ្យតុលាការបើកសវនាការម្តងទៀត ហើយត្រូវបានធ្វើឡើងវិញនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៧។ មេធាវីរបស់គាត់បានផ្តល់ភស្តុតាងបន្ថែម ដើម្បីបង្ហាញថា ដីដែលមានទំនាស់នោះគឺជាដីសាធារណៈរបស់រដ្ឋ ពុំមែនជាដីកម្មសិទ្ធិឯកជនរបស់នរណាម្នាក់ទេ។ មេធាវីបានស្នើសុំឱ្យដោះលែងកូនក្តីរបស់គាត់ឱ្យនៅក្រៅឃុំ ដោយបានបញ្ជាក់អំពីការឃុំខ្លួនលើសនីតិវិធីច្បាប់កំណត់ កង្វះ

ការបកស្រាយបំភ្លឺអំពីកម្មសិទ្ធិលើដីធ្លី និងបញ្ជាក់អំពីការស៊ើបអង្កេតអំពីកម្មសិទ្ធិរបស់ផ្ទៃកសុរិយោដី កំពុងតែបន្តធ្វើនៅឡើយ ។ ប៉ុន្តែ តុលាការបដិសេធសំណើទាំងនោះ ។

នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ តុលាការបានប្រកាសសាលក្រម ហើយបទចោទត្រូវបានកែប្រែទៅជាបទចោទតែមួយវិញ ដោយចោទពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរដ្ឋសាធារណៈ ហើយការកាត់ទោសឱ្យជាប់ពន្ធនាគារមួយឆ្នាំបន្ថយមកត្រឹម ៩ ខែ និងព្យួរទោស ៣ ខែវិញ នេះមានន័យថា ជា នី សឹងតែអាចដើរចេញពីតុលាការដោយសេរីទៅហើយ ។ ប៉ុន្តែ នៅតែជាប់ឃុំឃាំងដដែលដោយប្រឈមនឹងការចោទជាច្រើនករណីទៀតលើគាត់ ។

□□□

# ៦. តុលាការ និងអំពើពុករលួយ

ទំហំអំពើពុករលួយនៅក្នុងតុលាការកម្ពុជាដែលមិនស្មោះត្រង់ដ៏ល្បីល្បាញ អាចជាការលំបាកក្នុងការបញ្ជាក់ និងវាយតម្លៃឱ្យបានត្រឹមត្រូវណាស់ ដោយទាំងអ្នកសូក និងអ្នកទទួលសំណូកមិនដែលសារភាពថាបានប្រព្រឹត្តទេ ។ បញ្ហានេះពុំបានរារាំងចៅក្រមមួយចំនួនពីការអនុញ្ញាតិឱ្យឆ្មាំរបស់គេឃ្លាំមើល នឹងទទួលប្រាក់កាសពីភាគីនៅក្នុងករណីដែលខ្លួនកាត់សេចក្តីឡើយ ។ ឧទាហរណ៍ នីល ណុន ប្រធានតុលាការខេត្តបាត់ដំបង និងជាចៅក្រមនៃសាលាក្តីខ្មែរក្រហមបានសារភាពថា បានទទួលប្រាក់សំណូកពីភាគីជម្លោះកាលពីឆ្នាំ២០០២ ។[៨៣] ហើយប្រធានតុលាការខេត្តតាកែវលោក ទិត្យ សុធី សារភាពថា បានទទួលប្រាក់កាស និងអំណោយផ្សេងៗកាលពីខ្លួនធ្វើជាប្រធានតុលាការខេត្តកំពង់ចាម ។ លោក ទិត្យ សុធី បាននិយាយថា "ប្រសិនបើចៅក្រមឆ្លាត" គេអាចរកប្រាក់កាសបានច្រើនណាស់ ។[៨៤]

ទោះបីជាប្រាក់ខែ ចៅក្រម និងព្រះរាជអាជ្ញាត្រូវបានដំឡើងយ៉ាងច្រើនកាលពីឆ្នាំ ២០០៣ ចាប់ពី ៣២៤ ដល់ ៦២៥ដុល្លារ ក្នុងមួយខែក៏ដោយយោងតាមឋានៈ[៨៥] ក៏បញ្ហានេះហាក់ដូចជាមានផលប៉ះពាល់តិចតួចបំផុតចំពោះភាពស្មោះត្រង់របស់តុលាការ ។ នៅក្នុងការសិក្សាស្រាវជ្រាវមួយកាលពីឆ្នាំ២០០២ ដែលសិក្សាទៅលើប្រជាពលរដ្ឋប្រមាណ ២០០០គ្រួសារ ទូទាំងកម្ពុជា ស្តីពីបញ្ហាមិនស្មោះត្រង់ តុលាការជាប់ចំណាត់ថ្នាក់ទី២ បន្ទាប់ពីគយ ព្រមទាំងផ្តល់សេវាអន់បំផុត ។[៨៦] នៅក្នុងការសិក្សាស្រាវជ្រាវមួយ ដែលសិក្សាទៅលើមុខរបរចំនួន ១២០០ ដែលធ្វើកាលពីឆ្នាំ២០០៦ តុលាការត្រូវបានគេរកឃើញថា ជាស្ថាប័នពុករលួយជាងគេបំផុតនៅកម្ពុជា ។[៨៧]

គេនៅមានការសង្ស័យតិចតួចដែរថា ចៅក្រមគ្រប់កន្លែងទាំងអស់នៅតែបន្តរកវិធីធ្វើយ៉ាងណារកប្រាក់កាសឱ្យបានច្រើន ។ ឧទាហរណ៍ ថ្វីត្បិតតែទទួលបានប្រាក់បៀវត្ស ៣២៥ដុល្លារក្តី ក៏ចៅក្រមតុលាការរាជធានីភ្នំពេញលោក គង់ សែត បានអះអាងកាលពីឆ្នាំ២០០៦ថា ថ្មីៗនេះទើបតែបានបញ្ចប់ការទិញដីជាច្រើនកន្លែងនៅខេត្តកំពត អស់ប្រាក់សរុបចំនួន ២៥០.០០០ ដុល្លារ ។[៨៨]

**" ប្រសិនបើចៅក្រមជាមនុស្សឆ្លាតអាចរកប្រាក់កាសបានយ៉ាងច្រើន "**

ទិត្យ សុធី

ប្រធានតុលាការខេត្តតាកែវ

[៨៣] Amanda Pike: PBS ខែតុលា ឆ្នាំ២០០២ សូមអាន: http://www.pbs.org/frontlineworld/stories/cambodia/diay04.html

[៨៤] ឃែលី អេរី និង ផាន់ អានណា-បញ្ហានៅក្នុងតុលាការ -កាសែតឌឺឃែមបូឌាដេលី ថ្ងៃទី៤-៥ ខែមិនា ឆ្នាំ២០០០ ។

[៨៥] អនុក្រិត្យស្តីពីប្រាក់ឧបត្ថម្ភសម្រាប់ចៅក្រម-រាជរដ្ឋាភិបាលកម្ពុជា- ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ។

[៨៦] អំពើពុករលួយ និង គ្រួសាកម្ពុជា: មជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម- ខែមិនា ឆ្នាំ២០០៥ ។

[៨៧] ការវាយតម្លៃអំពើពុករលួយនៅក្នុងផ្នែកឯកជនកម្ពុជា-វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា-ខែកក្កដា ឆ្នាំ២០០៦ ។

[៨៨] គុជ ណារ៉ែន: អ្នកភូមិរារាំងនគរបាលក្នុងការត្រួសត្រាយព្រៃលើដី: កាសែតឌឺឃែមបូឌាដេលី ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៦ ។

គេជឿជាក់ជាទូលំទូលាយថា ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី បានចំណាយថវិការ ដើម្បីទទួលបានតំណែងរបស់ពួកគេ ហើយជាទូទៅតុលាការ និងមន្ត្រីរដ្ឋាភិបាលនានា បានទទួលស្គាល់ជាលក្ខណៈបុគ្គលអំពីបញ្ហានេះ។ នៅពេលដែលពួកគេបានកាន់តំណែងរួចរាល់ ពួកគេ "ត្រូវខំប្រឹងរកចំណូលមកវិញ" នឹង" ចម្រាញ់ពីមនុស្សណាដែលចូលមកទំនាក់ទំនងជាមួយប្រព័ន្ធតុលាការ"។[៨៩]

ការផ្តួចផ្តើមដើម្បីផ្តន្ទាទោស និងដាក់ទណ្ឌកម្មចំពោះអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការត្រូវបានកែលំអជាបណ្តោះអាសន្ន។ នៅខែមិនា ឆ្នាំ២០០៥ លោកនាយករដ្ឋមន្ត្រីបានប្រកាសជាសាធារណៈអំពីយុទ្ធនាការ "កណ្តាប់ដៃដែក" ដើម្បីបោសសំអាតចៅក្រមពុករលួយ និងចាប់ជនឧក្រិដ្ឋជន ដែលពួកគេបានដោះលែងមកវិញ។ យុទ្ធនាការនោះ បានឈានដល់ចំណុចកំពូលរបស់ខ្លួន នៅក្នុងសវនាការតុលាការ ដែលមិនធ្លាប់មានពីមុនមកកាលពីខែធ្នូ ឆ្នាំ២០០៥ ដែលពេលនោះ ចៅក្រមបីនាក់ ព្រះរាជអាជ្ញាពីរនាក់ និងក្រឡាបញ្ជីពីរនាក់ នៃតុលាការរាជធានីភ្នំ-ពេញត្រូវបានកាត់ទោសដោយតុលាការខេត្តបាត់ដំបង ដោយចោទពីបទទទួលសំណូក ហើយផ្តន្ទាទោសដាក់ពន្ធនាគារម្នាក់ៗ ៤ ឆ្នាំ ប៉ុន្តែពុំមានអ្នកណាម្នាក់ត្រូវបានចាប់ខ្លួន ឬចូលរួមក្នុងសវនាការនោះទេ។[៩០] ប្រហែលជាពីរខែក្រោយពីកិច្ចប្រជុំពិគ្រោះយោបល់ក្រុមប្រទេសអ្នកផ្តល់ជំនួយនៅឆ្នាំ២០០៦ មនុស្សទាំងប្រាំពីនាក់នោះត្រូវបានលើកលែងការចោទប្រកាន់វិញ នៅក្នុងសវនាការដែលរៀបចំធ្វើឡើងជាលើកទីពីរ ។[៩១] មួយខែក្រោយមក ចៅ និងព្រះរាជអាជ្ញាប្រាំបីនាក់ ដែលត្រូវបានព្យួរការងារក្នុងកំឡុងពេលយុទ្ធនាការ "កណ្តាប់ដៃដែកនោះ" ដោយមិនដឹងថាបានប្រព្រឹត្តខុសអ្វីនោះ ត្រូវបានតែងតាំងឱ្យមានតួនាទីនៅក្នុងតុលាការឡើងវិញ។[៩២]

□□□

[៨៩] អ៊ុន យាងៈ ការបង្រួបបង្រួម រដ្ឋ សង្គម និង លទ្ធិប្រជាធិបតេយ្យៈ ករណីកម្ពុជា-កិច្ចការប៉ាស៊ីហ្វិក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦។

[៩០] ករណីអំពើពុករលួយ ២០០៦-មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ឆ្នាំ២០០៦ ។

[៩១] ប្រាក់ ចាន់ថុលៈ មន្ត្រី ៧ នាក់ដែលត្រូវបានកាត់ទោសក្រោមកណ្តាប់ "ដៃដែក" ត្រូវបានលើកលែង- កាសែត ឌឺឃែមបូឌាដេលី ថ្ងៃទី២២-២៣ ខែមេសា ឆ្នាំ២០០៦។

[៩២] ជាង សុខាៈ "កណ្តាប់ដៃដែក" របស់ហ៊ុន សែន លើកឡើងដូចជាការទះកំភ្លៀងៈ កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៣០ ខែមិថុនា - ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦។

# ៧_ តុលាការ និងការឃុំឃាំង

តាមច្បាប់បច្ចុប្បន្ន មនុស្សពេញវ័យអាចត្រូវបានឃុំឃាំងរហូត ៤ ខែ មុនពេលសវនការ ហើយនឹងត្រូវឃុំខ្លួនប្រសិនបើជននោះអាច "រត់គេច ឬ មិនបង្ហាញខ្លួន-ឬប្រសិនបើមានហេតុផលដែលអាចជឿជាក់ថា ជនសង្ស័យអាចប្រើឥទ្ធិពលទៅលើសាក្សី ឬ ទៅលើការស៊ើបអង្កេត"។ ប្រសិនបើចាំបាច់ នោះត្រូវឃុំឃាំងបន្ត ២ ខែទៀត "អាស្រ័យចៅក្រមជាអ្នកសម្រេច និងកំណត់ហេតុផល" ។[៩៣]

តាមពិតចៅក្រមកម្រគោរពច្បាប់នេះណាស់ ។ ជនសង្ស័យភាគច្រើនត្រូវបានឃុំឃាំងដោយពុំបានពិចារណាអំពីស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេឡើយ ហើយការឃុំឃាំងត្រូវបានបន្តរហូតដល់ ៦ ខែ ដោយពុំមានហេតុផលបញ្ជាក់ឱ្យច្បាស់ឡើយ។ អ្វីដែលអាក្រក់បំផុតនោះគឺ ពិរុទ្ធជនរាប់រយនាក់ត្រូវបានឃុំឃាំងបណ្ដោះអាសន្នលើសនីតិវិធីច្បាប់បានកំណត់ ៦ ខែ យ៉ាងច្រើន។ នៅក្នុងឆ្នាំ ២០០៦ លីកាដូបានកត់ត្រាករណីឃុំឃាំងលើសនីតិវិធីបែបនេះចំនួន ៣០៧ ករណីនៅក្នុងពន្ធនាគារ ១៨ ដែលអង្គការនេះបានឃ្លាំមើល។

គួរឱ្យមានការខ្វាយខ្វល់យ៉ាងខ្លាំង ចំពោះបញ្ហានេះដោយរដ្ឋាភិបាលបានបង្កើនរយៈពេលឃុំខ្លួនបណ្ដោះអាសន្នអតិបរមារហូតដល់ ១៨ ខែ ចំពោះបទល្មើសព្រហ្មទណ្ឌ នៅក្នុងនីតិវិធីព្រហ្មទណ្ឌថ្មី ដែលរដ្ឋសភាជាតិបានអនុម័តកាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៧ ជំនួសឱ្យការដោះស្រាយបញ្ហាមូលហេតុឃុំខ្លួនលើសនីតិវិធី ដែលបានគូសបញ្ជាក់ ឬតម្រូវឱ្យចៅក្រមគោរពច្បាប់ ហើយដោះលែងពិរុទ្ធជនដែលត្រូវបានឃុំខ្លួនលើសនីតិវិធីនោះទៅវិញ។ ដោយចៅក្រមត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់ចំពោះករណីនីមួយៗ ដែលត្រូវឃុំខ្លួន ៦ ខែ ហើយគ្មានហេតុផលណាដែលអាចជឿបានថា ចៅក្រមគោរពមាត្រានេះ ឬ គោរពរយៈពេលឃុំខ្លួនកំណត់ថ្មី ឱ្យលើសពីអ្វីដែលពួកគេកំពុងធ្វើនាពេលបច្ចុប្បន្ននេះឡើយ។

បញ្ហានេះកាន់តែធ្ងន់ធ្ងរថែមទៀតនៅក្នុងការអនុវត្តន៍ជាមួយអនីតិជន ដែលតាមច្បាប់ត្រូវឃុំខ្លួនបានត្រឹមតែមួយខែប៉ុណ្ណោះក្នុងករណីបទល្មើសកំរិតស្រាល និងពីរខែចំពោះករណីបទល្មើសព្រហ្មទណ្ឌកំរិតធ្ងន់។ ក្នុងពេលកំពុងសរសេររបាយការណ៍នេះ យ៉ាងតិចអនីតិជនចំនួន ១៧ នាក់ ដែលត្រូវបានឃុំខ្លួនលើសនីតិវិធីច្បាប់កំណត់នៅក្នុងមជ្ឈមណ្ឌលកែប្រែទី ២ ហើយក្នុងចំណោមអនីតិជនទាំងនោះ ម្នាក់ត្រូវបានឃុំឃាំងលើសនីតិវិធីយ៉ាងយូរជាងគេហូតដល់ ២២ ខែ។

---

[៩៣] ក្រមព្រហ្មទណ្ឌអន្តរកាល (១៩៩២) មាត្រា ១៤ ។

ការរស់នៅលើសចំណុះនៅក្នុងពន្ធនាគារកម្ពុជានានា ត្រូវបានរួមផ្សំដោយការអនុវត្តនីបន្តឃុំឃាំងពិរុទ្ធជន ខណៈដែលត្រូវរង់ចាំសវនាការសាលាឧទ្ធរណ៍ ។ ប្រសិនបើព្រះរាជអាជ្ញាប្ដឹងឧទ្ធរណ៍ជំទាស់នឹងសាលក្រមសាលាដំបូងនោះ ពិរុទ្ធជនត្រូវស្ថិតនៅក្នុងការឃុំឃាំងរហូតសាលាឧទ្ធរណ៍ជំនុំជម្រះករណីនោះ។ ជាផលវិបាក ពិរុទ្ធជនដែលត្រូវបានលើកលែងការចោទប្រកាន់ ឬអ្នកទោសដែលត្រូវបានបម្រើទោសនៅក្នុងពន្ធនាគាររួចហើយ អាចត្រូវនៅជាប់ឃុំឃាំងតទៀតអស់រយៈពេលជាច្រើនឆ្នាំ រង់ចាំការជំនុំជម្រះរបស់សាលាឧទ្ធរណ៍ ។ តាំងពីមុនគោលការណ៍ដែលមានចែងច្បាស់លាស់ គឺមានតែសេចក្ដីសម្រេចឆ្នាំ២០០៣ របស់ក្រសួងមហាផ្ទៃតែមួយគត់[៩៤] ហើយគួរឱ្យអាសូរនោះ គឺគេបានកំណត់យកការអនុវត្តន៍នេះឱ្យទៅជាផ្លូវការនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ។

ការកែប្រែទាំងពីរនៅក្នុងនីតិវិធីព្រហ្មទណ្ឌថ្មីនេះត្រូវបានគេលើកឡើងជាការចំអកដោយគេបាននិយាយអះអាងថាការព្រាងច្បាប់ថ្មីនេះ វាស្មើនិងការកែទម្រង់ ។ ហើយពុំបានកំណត់លក្ខខណ្ឌតឹងតែងជាងមុនចំពោះតុលាការដែលតែងតែមិនយកចិត្តទុកដាក់ចំពោះការកំណត់ថាគ្មានទោសជាមុននោះទេ នីតិវិធីព្រហ្មទណ្ឌថ្មីនេះបែរជាពន្យាពេលថែមទៀតដើម្បីឃុំមនុស្សគ្មានទោស និងមនុស្សដែលមិនសមនឹងទទួលទោសក្នុងមន្ទីរឃុំឃាំងក្នុងរយៈពេលមួយកាន់តែវែងជាងមុនថែមទៀត។

បញ្ហានេះជាបញ្ហាមួយធ្វើឱ្យមានការខ្វាយខ្វល់យ៉ាងខ្លាំង ដែលក្រមនីតិវិធីថ្មីនេះត្រូវបានព្រាងឡើង ដោយមានជំនួយបច្ចេកទេសពីមូលិធិបរទេសយ៉ាងច្រើន ហើយការអនុវត្តន៍របស់វាត្រូវបានទទួលស្គាល់ថាជាជំហ៊ានជឿនលឿនទៅមុខ ។

មូលនិធិបរទេស និងមូលនិធិដទៃទៀត ដែលចាត់ទុកច្បាប់ថ្មីថាជាសញ្ញានៃការជឿនលឿន គេគួរពិចារណាករណី ស៊ីវ តុង ដែលមានអាយុ ១២ ឆ្នាំ នៅពេលដែលគាត់ត្រូវបានចាប់ខ្លួននៅខេត្តរតនគីរី ដោយសង្ស័យថាជាចោរកាលពីខែកញ្ញា ឆ្នាំ២០០៦។ ទោះបីជាគាត់នៅវ័យក្មេងពេកដែលមិនអាចចោទពីបទព្រហ្មទណ្ឌបានក្ដី ក៏គាត់ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ។ បន្ទាប់ពីឃុំអស់រយៈពេល ៨ ខែ និង ៦ ថ្ងៃដោយខុសច្បាប់ គាត់ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគាររយៈពេល ៨ ខែ និង ១០ ថ្ងៃ ។ ប៉ុន្តែ បន្ទាប់ពីបញ្ចប់ថេរវេលានៅក្នុងការឃុំឃាំងក្នុងពន្ធនាគារដោយខុសច្បាប់- ៤ ថ្ងៃក្រោយមក គាត់នៅតែត្រូវបានឃុំឃាំងបន្តរង់ចាំសនវការរបស់សាលាឧទ្ធរណ៍ ដើម្បីវិនិច្ឆ័យទោសសារថ្មី។[៩៥]

□□□

[៩៤] ក្រសួងយុត្តិធម៌ -ការសម្រេចរបស់សន្និសិទ្ធតុលាការជាតិសម្រាប់ឆ្នាំ២០០២ ភ្នំពេញ ថ្ងៃទី៧ ខែមិនា ឆ្នាំ២០០៣ ។

[៩៥] ប្រាក់ ចាន់ថុល: កុមារា ១៣ ឆ្នាំ ជាប់នៅក្នុងពន្ធនាគារបន្ទាប់ពីមានការប្ដឹងឧទ្ធរណ៍-កាសែតឌឺឃែមបូឌាដេលី ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧។

# ៨. សាលាក្តីខ្មែរក្រហម: តុលាការគំរូ?

កាលពីថ្ងៃ ១២ ខែមិថុនា ឆ្នាំ២០០៧ ចៅក្រមជាតិ និងអន្តរជាតិនៃសាលាក្តីខ្មែរក្រហមបានឯកភាពជាស្ថាពរនូវបទបញ្ជាផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា បញ្ចប់នូវភាពទាល់ច្រកចុងក្រោយក្នុងបញ្ហាទារុណ្ណកម្ម ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះដែលត្រូវបានសម្លាប់ដោយខ្មែរក្រហម។ រាជរដ្ឋាបាលជប៉ុនដែលជាអ្នកផ្តល់ជំនួយច្រើនជាងគេតែមួយគត់ បានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនថា ការជំនុំជម្រះនឹងអាចផ្តល់នូវ " គំរូដ៏ល្អដើម្បីពង្រឹងប្រព័ន្ធតុលាការកម្ពុជា" ។[៩៦]

នេះពុំមែនជាលើកទីមួយទេ ដែលទស្សនៈបែបនេះត្រូវបានលើកឡើង។ កាលពីខែមិនា ឆ្នាំ២០០៦ អ្នកនាំពាក្យអង្គជុំនំជុំរះវិសាមញ្ញក្នុងតុលាការកម្ពុជា លោក រាជ សម្បត្តិ បានអះអាងថា "សាលាក្តីនេះនឹងបន្សល់ទុកនូវមេរៀនល្អៗជាច្រើនសម្រាប់កម្ពុជា ជាពិសេស តុលាការ "ចំណែកឯ ប្រធានកិច្ចការសាធារណៈនៃអង្គជំនុំជម្រះ អ្នកស្រី ហេឡែន ចារីស បាននិយាយថា សាលាក្តីនេះអាចជាគំរូមួយដែលផ្តល់នូវ " ឱកាសមិនធ្លាប់មានចំពោះការកែទម្រង់តុលាការ " ។[៩៧]

ផ្ទុយទៅវិញ ដូចជាលំបាកក្នុងការមើលឃើញថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាគំរូវិជ្ជមានសម្រាប់តុលាការកម្ពុជាណាស់ ដោយសង្កេតឃើញថា ដំណើរការមកដល់ពេលនេះជួបប្រទះបញ្ហាច្រើន។

កាលពីខែឧសភា ឆ្នាំ២០០៥ រដ្ឋាភិបាល បាននិយាយថាខ្លួនមានលទ្ធភាពជួយថវិកាដល់សាលាក្តីនេះត្រឹមតែ ១.៥ លាន ដុល្លារតែប៉ុណ្ណោះ ក្នុងចំនួនថវិកាដែលបានយល់ព្រមជួយ ១៣.៣ លាន ដុល្លារ ហើយបានស្នើឱ្យសហគមន៍អន្តរជាតិជួយបំពេញនូវចំនួនដែលនៅខ្វះ ។ ចំនួនថវិកាដែលនៅសល់ត្រូវបានជួយដោយរដ្ឋាភិបាលជប៉ុនតាមរយៈមូលនិធិជំនួយទ្វេរភាគីរបស់ខ្លួន។[៩៨] មួយឆ្នាំក្រោយមក រដ្ឋាភិបាលកម្ពុជាដ៏ក្រីក្រនេះបានចំណាយ ៥ លានដុល្លារ ដើម្បីទិញវិមានក្នុងទីក្រុងមួយសម្រាប់ឯកអគ្គរាជទូតរបស់ខ្លួនប្រចាំនៅអង្គការសហប្រជាជាតិនៅទីក្រុងម៉ានហាតថាន ។[៩៩]

---

[៩៦] សេចក្តីថ្លែងការណ៍ដោយលេខាធិការសាព័ត៌មាន/អគ្គនាយកសាព័ត៌មាន និងទំនាក់ទំនងសាធារណៈ ស្តីពីការអនុម័តបទបញ្ជាផ្ទៃក្នុងសម្រាប់អង្គជុំនំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ក្រសួងការបរទេសជប៉ុន ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៧។

[៩៧] ខាត បាត់ថុនៈ ការកាត់ទោសខ្មែរក្រហមជាការសន្យាក្នុងការកែទម្រង់តុលាការ-កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១០-២៣ ខែមិនា ២០០៦។

[៩៨] ខាត វ៉ូដសុំៈ កម្ពុជាទទួលយកសំណើជប៉ុនក្នុងការផ្តល់មូលនិធិឱ្យតុលាការខ្មែរក្រហម -ព័ត៌មានសម្លេង សហរដ្ឋអាមេរិក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ ។

[៩៩] អេរិក វ៉ាសុន និង ប្រាក់ ចាន់ថុលៈ រដ្ឋាភិបាលទិញវិមានតម្លៃ ៥ លាន ដុល្លានៅញូវយ៉ក-កាសែតឌឹឃែមបូឌា ដេលី ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦។

កាលពីខែឧសភា ឆ្នាំ២០០៦ ចៅក្រម និងព្រះរាជអាជ្ញាកម្ពុជាដែលបានចាត់តាំងឱ្យធ្វើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ភាគច្រើនត្រូវទទួលរងការរិះគន់យ៉ាងធ្ងន់ធ្ងរអំពីបញ្ហាឯករាជ្យភាព សមត្ថភាព និងគុណភាព។ ចៅក្រមដែលត្រូវបានចាត់តាំងទាំងនោះរួមមាន ឧត្តមសេនីយ៍ទោ នៃ ថុល ប្រធានតុលាការយោធា និងជាសមាជិកគណកម្មាធិការមជ្ឈិមនៃគណបក្សប្រជាជនកម្ពុជា ដែលជិតមួយឆ្នាំមុននេះ បានធ្វើជាចៅក្រមជំនុំជម្រះក្តីករណីសមាជិកសភាគណបក្សប្រឆាំងលោក ជាម ចន្នី ។ លោក នៃ ថុល ពុំមានសញ្ញាប័ត្រច្បាប់ទេ ប៉ុន្តែកំពុងរៀនផ្នែកវិទ្យាសាស្ត្រនយោបាយ ហើយគាត់ក៏ធ្លាប់ធ្វើជាចៅក្រមជំនុំជម្រះករណី សម្តេច ក្រុមព្រះ នរោត្តម រណឫទ្ធិ និងសការី ដែលជាករណីនយោបាយក្នុងឆ្នាំ១៩៩៨។ ចៅក្រមដែលត្រូវបានចាត់តាំងផ្សេងទៀតដូចជា លោក យ៉ា សាខន ដែលធ្លាប់ធ្វើជាចៅក្រមជំនុំជម្រះករណីមូលហេតុនយោបាយរបស់ព្រះអង្គម្ចាស់ នរោត្តម សិរីវុឌ្ឍកាលពីឆ្នាំ១៩៩៦ - ចៅក្រម ធូ មុន្នី ជាចៅក្រមដែលជំនុំជម្រះករណី ប៊ិន សំណាង និងសុខសំអឿនពីរ ដង ហើយដែលបានដោះលែងក្នុយលោក ហ៊ុន សែន ពីបទមនុស្សឃាតកាលពីឆ្នាំ២០០៤ កន្លងទៅក្នុងស្ថានភាពគួរឱ្យសង្ស័យមួយ-លោកចៅក្រម ថោង អុល ធ្លាប់បានដោះលែងមេបញ្ជាការខ្មែរក្រហម ឈូក រិន ដែលបានចោទប្រកាន់ពីបទមនុស្សឃាតក្នុងឆ្នាំ២០០០- លោក នីល ណុន ជាចៅក្រមដែលបានសារភាពថា ខ្លួនធ្លាប់ទទួលសំណូកពីមនុស្សជាច្រើនក្នុងករណីតុលាការ ហើយលោកចៅក្រម ប៉ែន ពេជ្រសាលី ជាមនុស្សមិនធ្លាប់ដែលធ្វើជាចៅក្រមពីមុនមក។ ការពារការចាត់តាំងចៅក្រមទាំងនោះ អ្នកនាំពាក្យអង្គជំនុំជម្រះវិសាមញ្ញលោក រាជ សម្បត្តិ បានអះអាងថា ការជំនុំជម្រះនឹងអាចផ្តល់ឱកាសឱ្យចៅក្រម "កសាងកេរ្តិ៍ឈ្មោះឡើងវិញ"[១០០] ចំណែកឯ លោក ហ៊ុន សែន បាននិយាយថា អ្នករិះគន់ស្តីពីការតែងតាំងគឺជា" សត្វ" ដែល" ចង់លួងលោមមេពួកគេតែប៉ុណ្ណោះ" ។[១០១]

ខែកុម្ភៈ ឆ្នាំ២០០៧ អង្គការផ្នែកច្បាប់អាមេរិកមួយបានធ្វើការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរថា បុគ្គលិកកម្ពុជានៃអង្គជំនុំជុំរះបានចំណាយថវិការឱ្យទៅថ្នាក់លើរបស់ពួកគេ ដើម្បីបានធ្វើការងារ។[១០២] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (ដែលផ្តល់មូលនិធិឱ្យអង្គជំនុំជម្រះវិសាមញ្ញ) បានធ្វើការត្រួតពិនិត្យបញ្ជីរបស់អង្គជំនុំជម្រះ ប៉ុន្តែជាច្រើនខែក្រោយមក បានបដិសេធមិនផ្សព្វផ្សាយនូវអ្វីដែលខ្លួនបានរកឃើញទេ ។ ក្រោយពីមានការថ្កោលទោសជាទូទៅអំពីបញ្ហាកង្វះតម្លាភាព ទីបំផុតរបាយការណ៍ត្រួតពិនិត្យក៏ត្រូវបានផ្សព្វផ្សាយ ។ អ្នកត្រួតពិនិត្យបាននិយាយថា ពួកគេ "ពុំបានរកឃើញ "នូវភស្តុតាងជាក់លាក់ណាមួយស្របជាមួយនឹង ការចោទប្រកាន់ទេ ហើយក្នុង

---

[១០០] ប្រាក់ ចាន់ថុល៖ ការកាត់ទោសខ្មែរក្រហមនឹងស្តារកេរ្តិ៍ឈ្មោះចៅក្រមឡើងវិញ- អ្នកនាំពាក្យ- កាសែតឌឹឃែមបូឌាដេលី ថ្ងៃទី៦-៧ ខែឧសភា ឆ្នាំ២០០៦។

[១០១] សន្ទរកថាថ្លែងដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងពិធីចែកសញ្ញាបត្រនៅសាលាភូមិន្ទរដ្ឋបាលភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៦។

[១០២] ការចោទប្រកាន់អំពីអំពើពុករលួយនៅតុលាការខ្មែរក្រហមត្រូវតែស៊ើបអង្កេតឱ្យបានហ្មត់ចត់-សេចក្តីប្រកាសព័ត៌មានរបស់អង្គការផ្តួចផ្តើមយុត្តិធម៌សង្គមចំហរ - ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧ ។

ពេលជាមួយគ្នានោះដែរ គេបានទទួលស្គាល់ថា គេពុំបានស៊ើបអង្កេតការចោទប្រកាន់ឱ្យបានហ្មត់ចត់ទេ។[១០៣] ប៉ុន្តែការត្រួតពិនិត្យបានលាតត្រដាងនូវ "ការខុសឆ្គង" យ៉ាងច្រើនក្នុងការជ្រើសរើសបុគ្គលិកកម្ពុជាឱ្យចូលបម្រើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ ហើយក៏បានផ្ដល់យោបល់ឱ្យអង្គជំនុំជម្រះលប់កិច្ចសន្យារបស់បុគ្គលិកទាំងនោះចោលទាំងអស់ ហើយជ្រើសរើសបុគ្គលិកសារជាថ្មី។ កន្លងមកក្រុមត្រួតពិនិត្យធ្លាប់បាននិយាយថា ប្រសិនបើភាគីកម្ពុជានៅក្នុងអង្គជំនុំជម្រះ មិនយល់ព្រមធ្វើការកែទម្រង់ដ៏សំខាន់នេះទេ នោះកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិនឹង "ធ្វើការពិចារណាយ៉ាងហ្មត់ចត់" ហើយអាចនឹងដកខ្លួនចេញពីអង្គជំនុំជម្រះវិញ ។[១០៤]

ក្នុងខែមិនា ឆ្នាំ២០០៧ លោក គី តិច ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដ៏ចម្រូងចម្រាស់ បានតម្រូវឱ្យមេធាវីបរទេសការពារក្ដីក្នុងអង្គជំនុំជម្រះវិសាមញ្ញបង់ប្រាក់ម្នាក់ ៤.៩០០ ដុល្លារ ក្នុងមួយឆ្នាំ ទោះបីជាមេធាវីណាការពារកូនក្ដីមិនទទួលយកប្រាក់ឈ្នួលក៏ត្រូវបង់ដែរ។ ចៅក្រមអន្តរជាតិបានបញ្ជាក់ថា "តម្លៃនេះអាចជាការ "កំរិតនូវសិទ្ធិរបស់ជនជាប់ចោទ និងជនរងគ្រោះយ៉ាងធ្ងន់ធ្ងរក្នុងការជ្រើសរើសទីប្រឹក្សាតាមចំណង់ចំណូលចិត្តរបស់ពួកគេ"[១០៥] ដូច្នេះអាចនាំឱ្យមានការសម្រុះសម្រួលដល់យុត្តិធម៌ក្នុងការវិនិច្ឆ័យ នឹងអាចផ្ដល់នូវមូលដ្ឋាននៃការប្ដឹងឧទ្ធរណ៍។ ក្រោយមកតម្លៃនោះត្រូវបានបន្ថយមកនៅត្រឹម ៥០០ ដុល្លារ ក្នុងមួយឆ្នាំវិញ បន្ទាប់ពីមានការពិភាក្សាជាមួយអ្នកការទូតមួយចំនួន និងរដ្ឋាភិបាលជប៉ុនដែលជាអ្នកផ្ដល់ជំនួយដល់គណៈមេធាវី។ ការបង់ថ្លៃដែលមិនអាចប្រកែកបាននោះ គឺជាការធានាដើម្បីឱ្យមានការអនុវត្តន៍សកម្មភាពដែលគ្មានមូលដ្ឋាននៅក្នុងច្បាប់ ឬកិច្ចសន្យាណាមួយសោះ ហើយដូច្នេះការបង់នេះត្រូវបានគេគិតថាជា " ការសូកប៉ាន់ " ទៅវិញ។

ក្រៅពីនោះ នៅមានបញ្ហាធ្ងន់ធ្ងរជាច្រើនទៀត ដូចជាការឃុំខ្លួនខុសច្បាប់ និងលើសនីតិវិធីកំណត់យ៉ាងយូរចំពោះមនុស្សដំបូងដែលសាលាក្ដីនេះបានចោទប្រកាន់ គឺ ប្រធានពន្ធនាគារខ្មែរក្រហម កាំង ហ្កិច អៀវ ហៅ "ឌុច" ។ គាត់ត្រូវបានឃុំខ្លួនដោយពុំមានការកាត់ទោសតាំងពីឆ្នាំ១៩៩៩ ហើយនេះជាការអនុវត្តន៍ផ្ទុយទៅនិងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ទោះបីជាការឃុំខ្លួននេះត្រូវបានធ្វើឡើងមុននឹងមានការបង្កើតអង្គជំនុំជម្រះវិសាមញ្ញជាផ្លូវការក្នុងឆ្នាំ ២០០៦ នោះក៏ការសម្រេចចិត្តរបស់អាជ្ញាធរកម្ពុជាក្នុងការរក្សាគាត់នៅក្នុងមន្ទីរឃុំឃាំងដោយពុំមានការកាត់ក្ដីគឺច្បាស់ជាពាក់ព័ន្ធជាមួយការពន្យាពេលនៃសាលាក្ដី។ ឌុចត្រូវបានឃុំឃាំងខុសច្បាប់ដោយប្រធានតុលាការយោធានៃ ថុល ដែលបច្ចុប្បន្នគឺជាចៅក្រមកម្ពុជាមួយរូបនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ នៅក្នុងខែកក្កដា ឆ្នាំ២០០៧ ឌុច

[១០៣] អ្នកត្រួតពិនិត្យអះអាងថា ការចោទប្រកាន់ -ពីព្រោះតែពាក់ព័ន្ធជាមួយបុគ្គលិកដែលតែងតាំងដោយរដ្ឋាភិបាលកម្ពុជា ពុំមែនអង្គការសហប្រជាជាតិ ដូច្នេះវាស្ថិតក្រៅសមត្ថកិច្ចនៃការស៊ើបអង្កេត។

[១០៤] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ-ការត្រួតពិនិត្យពិសេសអំពីការគ្រប់គ្រងធនធានមនុស្សនៅក្នុងអង្គជុំនំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា- ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៧ ។ សូមអានវែបសាយ: http://www.unakrt-online.org/Docs/Other/2007-06-04%20UNDP%20Special%20Audi%20ECCC%20HR.pdf

[១០៥] សេចក្ដីថ្លែងការណ៍ដោយគណកម្មការត្រួតពិនិត្យនៃអង្គជុំនំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៧។

ត្រូវអង្គជំនុំជម្រះចោទប្រកាន់ហើយផ្ទេរមកនៅក្រោមសមត្ថកិច្ចរបស់ខ្លួនវិញ។ ដោយគ្រាន់តែលើកឧទាហរណ៍តាមច្បាប់សាលាក្តីនេះត្រូវតែអនុវត្តតាមកតិ្តការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយដែលតម្រូវឱ្យនាំជនសង្ស័យក្នុងករណីព្រហ្មទណ្ឌយកទៅផ្តន្ទាទោសក្នុងកំឡុងពេលសមរម្យណាមួយ នោះការឃុំខ្លួនលើសនីតិវិធីច្បាប់កំណត់ដ៏យូរបែបនេះ តាមច្បាប់ជាមូលដ្ឋាន នោះគាត់អាចត្រូវបានរួចផុតពីការចោទប្រកាន់។ (មកដល់ខែវិច្ឆិកា ឆ្នាំ២០០៧ ករណីនេះត្រូវបាននាំមកចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញសម្រេចមុនពេលកាត់ក្តី។)

នេះជាបញ្ហាមួយដែលត្រូវខ្វាយខ្វល់យ៉ាងខ្លាំងគឺ មុននឹងជនសង្ស័យណាម្នាក់ត្រូវបាននាំមកដើម្បីជំនុំជម្រះអង្គជំនុំជម្រះវិសាមញ្ញត្រូវរងអាប់ឱនដោយការឃុំឃាំងជនសង្ស័យលើសនីតិវិធី ចោទប្រកាន់អំពីបញ្ហាអំពើពុករលួយ និង ការទាមទារឱ្យមានការបង់ប្រាក់ដែលមិនអាចប្រកែកបាន ខ្វះតម្លាភាព និងការចាត់តាំងចៅក្រមកម្ពុជាដែលមានប្រវត្តិលំអៀងផ្នែកនយោបាយយ៉ាងខ្លាំង ។ ឆ្ងាយពីតួនាទីជាតុលាការគំរូ កន្លងមកសាលាក្តីនេះគឺជាអ្នកពង្រឹង និងលើកទឹកចិត្តដល់ទិដ្ឋភាពដ៏អាក្រក់នៃប្រព័ន្ធតុលាការកម្ពុជាទៅវិញ។

□□□

# ៩. តុលាការ និងកំណែទម្រង់

កំណែទម្រង់តុលាការ និងច្បាប់ គឺជាអាទិភាពចម្បងដែលត្រូវបានប្រកាសដោយសហគមន៍អ្នកផ្តល់ជំនួយតាំងពីសម័យអ៊ុនតាក់ ហើយរាជរដ្ឋាភិបាលកម្ពុជាតែងតែប្រកាសជារឿយៗនូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការកែទម្រង់នេះ។ កន្លងមកគេបានបង្ហូរថវិការាប់លានដុល្លារចូលទៅក្នុងកម្មវិធីកែទម្រង់នេះ ជាពិសេសការងារស្រាវជ្រាវការព្រាងច្បាប់ ហ្វឹកហ្វឺនមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់នានា ទ្រទ្រង់ នឹងកែលំអរតុលាការ និងពន្ធនាគារជាដើម ។

***ប៉ុន្តែ តើថវិកាទាំងនេះបានជួយឬទេ?***

តុលាការមានលក្ខណៈល្អប្រសើរជាងមុនច្រើននៅក្នុងការគោរពច្បាប់ ចាប់តាំងពីឆ្នាំ ១៩៩២ ។ នៅក្នុងការវាយតម្លៃរបស់លោកបណ្ឌិត ឡៅ ម៉ុងហៃ លោកបានគូសបញ្ជាក់ថា:

- ចៅក្រម និងព្រះរាជអាជ្ញារបស់យើងជាទូទៅមានសមត្ថភាពជាងមុន
  - ពួកគេមានចំណេះ និងការយល់ដឹងផ្នែកច្បាប់ និងនីតិវិធីច្រើនជាងមុន
  - ពួកគេបានបញ្ចេញសម្លេង និងបានពិភាក្សាដោយចំហរជាងមុន នឹងមានឆន្ទៈចង់រៀនជាងមុន។
  - ពួកគេមានលក្ខណៈផ្អែកលើភស្តុងច្រើនជាងមុន
- ពួកគេអនុវត្តតាមច្បាប់ច្រើនជាងមុនៈ
  - អនុវត្តតាមនីតិវិធីច្បាប់ច្រើនជាងមុន
  - មានករណីតិចតួចដែលគេបានអះអាងច្រើនជាងមុនក្នុងការងារពាក់ព័ន្ធជាមួយនគរបាល
  - ចៅក្រមជំនុំជម្រះប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់គេ

ប៉ុន្តែ ផ្នែកដ៏សំខាន់បំផុតក្នុងចំណោមនានាដែលបានរៀបរាប់ខាងលើ ពុំមានការផ្លាស់ប្តូរអ្វីទាំងអស់។ ឥទ្ធិពលហិរញ្ញវត្ថុ និងនយោបាយមកលើតុលាការនៅតែខ្លាំងដូចមុនដដែល ហើយគ្មានអ្វីបង្ហាញថាបញ្ហានេះនឹងមានការផ្លាស់ប្តូរឡើយ ។

យោងតាមលោកបណ្ឌិត ឡៅ ម៉ុងហៃ "ក្នុងចំណោមកម្មវិធីកែទម្រង់ទាំងអស់រដ្ឋាភិបាលហាក់ដូចជាយកចិត្តទុកដាក់តិចតួចបំផុតចំពោះកម្មវិធីកែទម្រង់ច្បាប់ និងតុលាការហើយថែមទាំងកំពុងអូសបន្លាយថែមទៀត។"[១០៦] នៅក្នុងការវាយតម្លៃនេះពុំមែនគាត់តែម្នាក់ឯងទេ។ សូម្បីតែធនាគារពិភពលោក ក៏បានលើកគម្រោងផែនការកែទម្រង់តុលាការ និងច្បាប់ ដោយសារតែមាន "ការខ្វាយខ្វល់កាន់តែខ្លាំងឡើងៗ ក្នុងចំណោមធនាគារនានា ចំពោះបញ្ហាកង្វះមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលដើម្បីអនុវត្តនូវរបៀបវារៈកែទម្រង់ច្បាប់ និងតុលាការរួមគ្នានៅក្នុងសាខានៃស្ថាប័ននីតិប្រតិបត្តិ និងរដ្ឋាភិបាល" ។[១០៧]

**" សូម្បីតែការពិនិត្យមើលនូវធាតុពិតពីក្រោយសាលារសាស្ត្រដែលពុំបានត្រដាងទាំងខ្លឹមសារ និង ឆន្ទៈនយោបាយផង "** USAID

ប៉ុន្តែប្រទេសផ្តល់មូលនិធិមួយចំនួនក្នុងចំណោមសហគមន៍អន្តរជាតិនៅតែបន្តសន្យាផ្តល់មូលនិធិយ៉ាងច្រើនឱ្យកម្មវិធីកែទម្រង់ច្បាប់ និងតុលាការនៅក្នុងក្របខណ្ឌផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិរបស់រដ្ឋាភិបាល ទោះបីជាពុំមានការប្រសើរឡើងណាមួយគួរឱ្យកត់សំគាល់នៅក្នុងវិស័យយុត្តិធម៌ក៏ដោយ។ រដ្ឋាភិបាលបានបន្តធ្វើការសន្យាថែមទៀតដែលខ្លួនមិនអាចធ្វើទៅបាន ក្នុងខណៈដែលខំប្រឹងរក្សាការលួតលាស់តែសំបកក្រៅ។ ដូចដែលអង្គការមូលនិធិមួយបានធ្វើការកត់សំគាល់ថា រដ្ឋាភិបាលបានរៀបចំផែនការនិងបានបង្កើតក្រុមប្រឹក្សាយ៉ាងច្រើនស្តីពីបញ្ហាអភិបាលកិច្ចល្អ ។ ប៉ុន្តែ នៅស្ទើរតែគ្រប់ករណីទាំងអស់ ផែនការ និងក្រុមប្រឹក្សា គឺលើសពីគោលបំណងនៃការសិក្សាតែបន្តិចប៉ុណ្ណោះ ដើម្បីបង្ហាញដល់ប្រទេសផ្តល់មូលនិធិនូវអ្វីដែលគេចង់ឮ។ សូម្បីតែការពិនិត្យការពិតយ៉ាងប្រញាប់ប្រញាល់នៅពីក្រោយការអួតអាងដ៏ប៉ិនប្រសព្វក៏ពុំបានបង្ហាញនូវខ្លឹមសារនិងឆន្ទៈនយោបាយផង។[១០៨]

មួយផ្នែកដ៏សំខាន់នៃបញ្ហាគឺថាការពិតបច្ចុប្បន្ននេះពុំមានប្រព័ន្ធណាមួយសម្រាប់ប្រើ ដើម្បីកំណត់ថាតើកិច្ចខិតខំប្រឹងប្រែងក្នុងការកែទម្រង់ដែលចំណាយរាប់លានដុល្លានេះ មានផលប៉ះពាល់ជាវិជ្ជមានលើវិស័យយុត្តិធម៌កម្ពុជាដែរឬទេ។ កន្លងមក ជោគជ័យត្រូវបានវាស់វែងដោយផ្អែកទៅលើលទ្ធផលដែលទទួលបានក្នុងពេលបច្ចុប្បន្ន ដូចជាការអនុម័តច្បាប់ ចំនួនវគ្គហ្វឹកហ្វឺនដែលត្រូវបានបើក និងចំនួនអាគារដែលត្រូវបានកសាង។ ប៉ុន្តែនេះគឺជាការសន្និតខុសយ៉ាងធ្ងន់ធ្ងរដែលគិតដូច្នេះ ឧទាហរណ៍ដូចជាការអនុម័តច្បាប់ តើវាអាចនឹងនាំមកនូវយុត្តិធម៌ដែលមានគុណភាពប្រសើរជាងមុនដែរឬទេ ខណៈដែលតុលាការបង្ហាញឱ្យឃើញថា ពួកគេមិនទាំងចាប់អារម្មណ៍ជាមួយច្បាប់ដែលមានស្រាប់ផងនៅពេលដែលឥទ្ធិពលនយោបាយ និងហិរញ្ញវត្ថុចូលមកជ្រៀតជ្រែក។

---

[១០៦] លិខិតឆ្លើយឆ្លងជាមួយលីកាដូ ខែមិថុនា ឆ្នាំ២០០៧ ។

[១០៧] ព្រះរាជាណាចក្រកម្ពុជា របាយការណ៍សរុប ២០០៥ -ធនាគារពិភពលោក ថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០៥ ។

[១០៨] ការវាយតម្លៃអំពើពុករលួយនៅកម្ពុជា- USAID ខែសីហា ឆ្នាំ២០០៤ ។

អង្គការសង្គមស៊ីវិលកម្ពុជាបានបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីត្រួតពិនិត្យ និងរាយការណ៍អំពីការអនុវត្តន៍របស់តុលាការ ដូចជាគម្រោងឃ្លាំមើលតុលាការដែលបង្កើតឡើងដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ដែលបច្ចុប្បន្នកំពុងឃ្លាំមើលតុលាការចំនួន ៦ ប៉ុន្តែពុំបានឃ្លាំមើលអំពីបញ្ហាអំពើពុករលួយ និងការជ្រៀតជ្រែកដោយនយោបាយទេ។[១០៩] អង្គការសិទ្ធិមនុស្សមួយចំនួន រួមមាន លីកាដូ ក៏បានឃ្លាំមើលដំណើរការតុលាការទូទាំងកម្ពុជា ជាប្រចាំដែរ ហើយធ្វើការផ្សព្វផ្សាយនូវការសង្កេត និងវិភាគរបស់ពួកគេ ។ ទោះបីជាមានការទទួលស្គាល់ពីគម្រោងកែទម្រង់ការងារខ្លះក៏ដោយ តែនៅពុំទាន់មានចេតនាក្នុងការដាក់បញ្ចូលលទ្ធផលនៃការឃ្លាំមើលនេះទៅក្នុងកម្មវិធីកែទម្រង់យុត្តិធម៌ទូទៅនៅឡើយដែរ ។



តុលាការក្រុងព្រះសីហនុ

ការខកខានពុំបានបង្កើតនូវប្រព័ន្ធត្រួតពិនិត្យសម្រាប់ការកែទម្រង់តុលាការ ជាការបង្ហាញឱ្យឃើញថា ប្រទេសផ្តល់ជំនួយភាគច្រើន ហាក់ដូចជាពុំចង់ទទួលស្គាល់ថា ការផ្តួចផ្តើមរបស់ពួកគេបច្ចុប្បន្ន មិនដំណើរការ។ ហើយដូចដែលលោកស្រី លី្វ អាប៉រ បានគូសបញ្ជាក់ថា ការកែទម្រង់តុលាការ គឺជា "វិស័យសំខាន់បំផុតតែមួយគត់ ដែលកម្ពុជាត្រូវធ្វើឱ្យមានការជឿនលឿនទៅមុខ" ។ បរាជ័យក្នុងការកែទម្រង់តុលាការមានន័យថា បរាជ័យនៅក្នុងការកែទម្រង់លទ្ធិប្រជាធិបតេយ្យ បរាជ័យក្នុងការកែទម្រង់សេដ្ឋកិច្ច និងបរាជ័យក្នុងការកែទម្រង់សង្គម។ ប្រព័ន្ធត្រួតពិនិត្យសម្រាប់ជំនួយផ្នែកតុលាការត្រូវបង្កើតជាមូលដ្ឋាននៃជំនួយទាំងអស់ដែលផ្តល់ឱ្យកម្ពុជាមិនត្រឹមតែជំនួយផ្នែកតុលាការ និងការកែទម្រង់ច្បាប់ប៉ុណ្ណោះទេ ។

រដ្ឋាភិបាលទំនងជាមិនស្វាគមន៍នូវបទដ្ឋានគំរូដែលផ្អែកទៅលើការពិតនៃយុត្តិធម៌នៅកម្ពុជា ឬច្បាស់ណាស់គឺមិនស្វាគមន៍លក្ខខណ្ឌបន្ថែមណាមួយដែលដាក់មកលើជំនួយទេ។ ជាច្រើនលើកច្រើនសារ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសម្តែងនូវការសរសើររដ្ឋាភិបាលចិនជាសាធារណៈចំពោះការផ្តល់ជំនួយដែលពុំមានចំណង។[១១០] ប៉ុន្តែ សហគមន៍អ្នកផ្តល់ជំនួយមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋកម្ពុជានិងពលរដ្ឋរបស់គេដែលជាអ្នកបង់ពន្ធក្នុងករណីជំនួយទ្វេរភាគី ដើម្បីទាមទារភ្ជាប់ជំនួយផ្នែកតុលាការកម្ពុជានាពេលអនាគតទៅនឹងការត្រួតពិនិត្យដ៏ហ្មត់ចត់មួយ។

[១០៩] របាយការណ៍ប្រចាំឆ្នាំគម្រោងឃ្លាំមើលតុលាការ —មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម - ថ្ងៃទីកុម្ភៈ ឆ្នាំ២០០៧ ។

[១១០] យន់ សាមាន : ហ៊ុន សែន សារទរក្រុងប៉េកាំងជំនួយគ្មានចំណង-កាសែតឌឺឃែមបូឌាដេលី - ថ្ងៃទី១២ ខែមេសា ២០០៦ ។ យន់ សាមាន : ហ៊ុន សែន សរសើរចិនថា មិនភ្ជាប់លក្ខខណ្ឌជាមួយជំនួយ-កាសែតឌឺឃែមបូឌាដេលី ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៦ ។

# ១០_ អនុសាសន៍

ចំណុចសំខាន់ៗជាច្រើនដែលត្រូវធ្វើកំណែទម្រង់នៅក្នុងតុលាការកម្ពុជា ត្រូវបានក្រុមសិទ្ធិមនុស្សផ្តល់អនុសាសន៍លើកឡើងជាច្រើនលើកច្រើនសារ ។ លីកាដូនៅតែរក្សាទុកនូវសារសំខាន់នៃការកែទម្រង់ជាច្រើនបែបនេះ រួមទាំងការអនុម័ត "ច្បាប់សំខាន់ៗទាំងប្រាំពីរ" ដែលនៅមិនទាន់បានអនុម័តនៅឡើយ (ប្រសិនបើអនុម័តដោយអនុលោមទៅតាមការពិគ្រោះយោបល់ និងការពិចារណាត្រឹមត្រូវតាមបទដ្ឋានសិទ្ធិមនុស្ស) ការដាក់បញ្ចូលនូវក្រមសីលធម៌តុលាការទៅក្នុងច្បាប់ (ដោយមានការផ្តល់និយមន័យវិធានការទណ្ឌកម្មឱ្យបានច្បាស់លាស់ និងការអនុវត្តន៍ឱ្យបានហ្មត់ចត់) និងការសើរើរៀបចំឡើងវិញ និងលុបបំបាត់ឥទ្ធិពលនយោបាយឱ្យអស់ទាំងនៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាធម្មនុញ្ញ ។

ប៉ុន្តែ លីកាដូ ជឿជាក់ថា ការកែទម្រង់ពិតៗនឹងមិនអាចកើតឡើងដោយងាយៗដោយគ្រាន់តែអនុម័តច្បាប់ និងគោលនយោបាយថ្មីៗនោះទេ អ្វីដែលរដ្ឋាភិបាលកម្ពុជាអះអាងថា ខ្លួនបានធ្វើឱ្យមានភាពជឿនលឿនទៅមុខនៅក្នុងការកែទម្រង់នោះ ត្រូវតែវិនិច្ឆ័យដោយពិនិត្យទៅលើសកម្មភាពប្រចាំថ្ងៃជាក់ស្តែងរបស់តុលាការ ។ ប្រទេសដែលផ្តល់ជំនួយឱ្យកម្ពុជា ត្រូវតែមានការសម្របសម្រួលឱ្យបានច្រើនជាងមុននៅក្នុងវិធីសាស្ត្ររបស់ខ្លួនចំពោះការកែទម្រង់ច្បាប់ និងតុលាការ- ត្រូវកំណត់បទដ្ឋានគំរូឱ្យបានហ្មត់ចត់ដើម្បីវាស់វែងការរីកចម្រើន និងផ្ញើសាររួមមួយទៅរដ្ឋាភិបាល ដែលពូកែតែខាង "បញ្ចេញវោហារ និងអនុម័តច្បាប់ដែលមិនយកមកអនុវត្តនោះ មិនគ្រប់គ្រាន់ឡើយ" ។ [១១១] ដើម្បីទាមទារឱ្យមានការកែទម្រង់ប្រកបដោយអត្ថន័យដែលផ្តល់នូវលទ្ធផលល្អពិតៗដល់ពលរដ្ឋកម្ពុជា សហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិត្រូវយល់ច្បាស់ និងទទួលស្គាល់ការពិតនៅក្នុងវិស័យយុត្តិធម៌កម្ពុជា ។

លីកាដូ សំណូមពរឱ្យសហគមន៍អ្នកផ្តល់ជំនួយដល់កម្ពុជា បង្កើតគណកម្មការឯករាជ្យមួយដើម្បីត្រួតពិ-និត្យតុលាការកម្ពុជា ។
គណកម្មការនោះគួរតែ :

- មានគោលបំណងក្នុងការត្រួតពិនិត្យចំពោះតែតុលាការកម្ពុជាដោយឯករាជ្យ ។
- បង្កើតឡើងជាដៃគូរសមភាពដោយសមភាគីប្រទេសផ្តល់ជំនួយអន្តរជាតិដល់កម្ពុជា
- ជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពវិជ្ជាជីវៈជំនាញខ្ពស់

---
[១១១] ការវាយតម្លៃអំពើពុករលួយនៅកម្ពុជា USAID ថ្ងៃទីសីហា ឆ្នាំ២០០៤ ។

- ត្រូវមានស្វ័យភាពផ្នែកមូលនិធិទាំងស្រុង
- ឯករាជ្យទាំងស្រុងពីការជ្រៀតជ្រែកពីសំណាក់ប្រភពជាតិ និងអន្តរជាតិនានា ។
- ត្រូវមានតម្លាភាពពេញលេញក្នុងគ្រប់ផ្នែកទាំងអស់នៃការងាររបស់ខ្លួនហើយធានាធ្វើឱ្យមានការផ្សព្វផ្សាយជាបន្ទាន់នូវលទ្ធផលទទួលបាន ។
- ត្រូវផ្តល់សេរីភាពពេញលេញក្នុងការផ្សព្វផ្សាយនូវអ្វីដែលខ្លួនរកឃើញដោយពុំមានការភ័យខ្លាចក្នុងការសងសឹក ។
- ធ្វើជាដៃគូជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលកម្ពុជា និងអន្តរជាតិនានា ចូលរួមយ៉ាងសកម្មក្នុងការវាស់វែងបែបគុណភាព និងបរិមាណចំពោះការផ្តល់យុត្តិធម៌ ទទួលយកទិន្នន័យពីប្រភពពាក់ព័ន្ធនានា ហើយត្រួតពិនិត្យឡើងវិញឱ្យបានត្រឹមត្រូវ ។
- ប្រើប្រាស់គម្រោងត្រួតពិនិត្យ និងសិក្សាថ្មីនានាក្នុងករណីចាំបាច់ ។
- ត្រួតពិនិត្យប្រព័ន្ធតុលាការកម្ពុជាទាំងមូល រួមទាំងតុលាការខេត្ត និងក្រុងនានា តុលាការយោធា ព្រមទាំងតុលាការផ្សេងៗទៀតដែលត្រូវបង្កើតឡើង ដូចជាតុលាការពាណិជ្ជកម្ម ដែលកំពុងស្នើឡើងជាដើម ។
- មិនត្រូវពិចារណាតែករណីណាដែលត្រូវបានប្តឹងមកប្រព័ន្ធតុលាការតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែពិចារណាករណីទាំងឡាយណាដែលពុំបានប្តឹងផងដែរ ។
- មិនត្រូវជ្រៀតជ្រែកដំណើរការរបស់តុលាការតាមវិធីណាមួយ ។

ការបង្កើតគណកម្មការត្រូវតែជាការសន្យាយូរអង្វែង- សហគមន៍អ្នកផ្តល់ជំនួយត្រូវតែប្រើប្រាស់ទិន្នន័យដែលគណកម្មការនេះផ្តល់ឱ្យ ដើម្បីរៀបចំយុទ្ធសាស្រ្តយូរអង្វែងសម្រាប់ការកែទម្រង់ច្បាប់ និងតុលាការ ។

លីកាដូបានត្រៀមខ្លួនជាស្រេចដើម្បីជួយ និងផ្តល់យោបល់ដល់សហគមន៍អ្នកផ្តល់ជំនួយនៅក្នុងការបង្កើតអង្គការដ៏សំខាន់មួយនេះ និងសហការអស់ពីសមត្ថភាពជាមួយគណកម្មការឯករាជ្យពិតៗបែបនេះ ។

□□□

http://www.licadho.org/